# សេចក្តីវិភាគផ្នែកសិទ្ធិមនុស្សនៃសេចក្តីព្រាងច្បាប់
# ស្តីពីដីកសិកម្ម

## ការវិភាគលើ "សេចក្តីព្រាងច្បាប់" លើកទី៦
## របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦

រៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ប្រចាំកម្ពុជា
ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧

# មាតិកា


I. សេចក្តីផ្តើម......4

II. ការវិភាគផ្នែកសិទ្ធិមនុស្ស......7

ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ......7

*មាត្រា១ ច្បាប់នេះមានគោលបំណងកំណត់ក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងដីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា*......7

*មាត្រា២ ច្បាប់នេះមានគោលដៅ*......7

*មាត្រា៥*......8

*មាត្រា៧*......8

ជំពូកទី៣៖ និរន្តរភាពនៃធនធានដីកសិកម្ម......11

*មាត្រា៩*......11

ជំពូកទី៥៖ ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម......15

ផ្នែកទី១៖ វិធានដីកសិកម្ម......15

*មាត្រា២៤*......15

*មាត្រា២៦*......16

*មាត្រា២៨*......17

*មាត្រា៣៥*......18

ផ្នែកទី២៖ ដីកសិកម្មតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច......19

*មាត្រា៣៧*......19

*មាត្រា៣៨*......22

*មាត្រា៤០*......24

ផ្នែកទី៣៖ ដីកសិកម្មក្រោមតំបន់អភិវឌ្ឍន៍កសិកម្ម......25

*មាត្រា៤១*......25

*មាត្រា៤៣*......26

ផ្នែកទី៤៖ ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន......28

*មាត្រា៤៥*......28

*មាត្រា៤៧*......30

*មាត្រា៥០*......31

*មាត្រា៥១*......32

*មាត្រា៥២*......33

*មាត្រា៥៤*......34

ផ្នែកទី៥៖ ដីកសិកម្មក្រោមកតិសន្យាផល....35
*មាត្រា៥៧*....35
*មាត្រា៥៩*....36
*មាត្រា៦០*....41
*មាត្រា៦៤*....42
ជំពូកទី៦៖ ការអភិរក្សធនធានដីកសិកម្ម....44
ផ្នែកទី១៖ ការអភិរក្សគុណភាពដីកសិកម្ម....44
*មាត្រា៧៣*....44
ជំពូកទី៧៖ ការផ្ទេរដីកសិកម្ម....45
*មាត្រា៨៤*....45
*មាត្រា៨៥*....47
*មាត្រា៨៦*....48
ជំពូកទី៨៖ ការចូលរួមនិងការផ្សព្វផ្សាយអប់រំ....50
*មាត្រា៨៩*....50
*មាត្រា៩០*....51
ជំពូកទី១០៖ ភ្នាក់ងារដីកសិកម្ម និងការជម្រុញអនុវត្តន៍ច្បាប់....51
*មាត្រា៩៩*....51
ជំពូកទី១១៖ ទោសប្បញ្ញត្តិ....51
*មាត្រា១១២*....52
*មាត្រា១១៣*....54

**សេចក្តីបន្ថែមនៃច្បាប់ស្តីពីដីកសិកម្ម៖** អនុសាសន៍បន្ថែមសម្រាប់បញ្ចូលទៅក្នុងសន្ធានុក្រម....55
**ឧបសម្ព័ន្ធ.** បទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងដីសម្បទានដីសេដ្ឋកិច្ច....58
១.ច្បាប់ភូមិបាល ២០០១....58
២.អនុក្រឹតស្តីពីសម្បទានដីសេដ្ឋកិច្ច(No. 146/2005)....61
៣.អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការដាក់បញ្ញាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែងឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច....63
៤.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (2007)....64

## I-សេចក្តីផ្តើម

សេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម បង្ហាញពីជំហ៊ានដ៏សំខាន់មួយ ឆ្ពោះទៅបង្កើតនូវប្រព័ន្ធគ្រប់គ្រងដីទូលំទូលាយចំពោះដីកសិកម្មដែលប្រើប្រាស់គ្រប់ទំរង់ទាំងអស់ រាប់ទាំងដីកសិកម្មដែលប្រើប្រាស់ដោយម្ចាស់ដីឯកជន អ្នកជួល សម្បទានិក និងសហគ្រាសដទៃផ្សេងទៀត ហើយនិងជនជាតិដើមភាគតិច។ ការបញ្ចេញសេចក្តីព្រាងច្បាប់នេះបានទាន់ពេលវេលា អនុញ្ញាតឲ្យភាគីពាក់ព័ន្ធទាំងឡាយ ផ្តល់មតិយោបល់របស់ខ្លួន ដែលនេះគឺជាមធ្យោបាយមួយដ៏សំខាន់ ដែលតាមរយៈនេះ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈនឹងសម្រេចបាន។ ការិយាល័យOHCHR មានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមចំណែកក្នុងដំណើរការនេះ តាមរយៈការផ្តល់សេចក្តីវិភាគផ្អែកសិទ្ធិមនុស្សលើសេចក្តីព្រាងច្បាប់នេះ។

សេចក្តីវិភាគរបស់ការិយាល័យOHCHR ផ្អែកលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធ ជាពិសេសទាញចេញមកពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច គោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលចងកាតព្វកិច្ចច្បាប់ជាច្រើនទៀតដែលកម្ពុជាគឺជារដ្ឋភាគី។

សិទ្ធិមនុស្សស្ទើរតែទាំងអស់ស្ថិតក្នុងហានិភ័យ នៅពេលដែលដីកសិកម្មមិនត្រូវបានចាត់ចែងឲ្យបានត្រឹមត្រូវ ជាពិសេសសម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាកសិករ ជនជាតិដើមភាគតិច បុគ្គល និងក្រុមជនងាយរងគ្រោះផ្សេងទៀត។ ករណីជនជាតិដើមភាគតិចដែលវប្បធម៌ និងសាសនារបស់ពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងដីធ្លីរបស់ខ្លួន សិទ្ធិសេរីភាពរបស់ពួកគេខាងជំនឿសាសនា និងការប្រតិបត្តិវប្បធម៌របស់ខ្លួនផ្ទាល់នឹងត្រូវទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរ ដែលពេលខ្លះ អាចនឹងត្រូវបាត់បង់ជារៀងរហូត។ នៅពេលមានការតវ៉ាចំពោះការរំលោភបំពានសិទ្ធិរបស់ខ្លួន ពួកគេត្រូវតែទទួលបាននូវការគោរពយ៉ាងពេញលេញចំពោះសិទ្ធិពលរដ្ឋនិងសិទ្ធនយោបាយរបស់ពួកគេ រាប់ទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម សិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ដ៏ប្រសិទ្ធភាពដែលធានាការពារសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌និងដោយមានដំណោះស្រាយប្រសិទ្ធភាព។ កម្មវត្ថុដែលបានលើកឡើងតាមរយៈសេចក្តីព្រាងច្បាប់នេះគឺ ការគ្រប់គ្រងដីកសិកម្ម ជាការបង្ហាញជាថ្មីម្តងទៀតអំពីភាពមិនអាចញែកដាច់ចេញពីគ្នាបាន និងការពឹងអាស្រ័យគ្នាទៅវិញទៅមក រវាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

សេចក្តីវិភាគនេះបង្ហាញថា ផលវិបាកជាទូទៅនៃសេចក្តីព្រាងច្បាប់នេះ អាចជាការអនុញ្ញាតឲ្យមានការប្រមូលផ្តុំដីកសិកម្មតូចៗទៅជាដីកសិកម្មទំហំធំមួយឬច្រើន តាមឆន្ទានុសិទ្ធិរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម ធ្វើឡើងដោយគ្មានជម្រើសខាងនីតិវិធីត្រឹមត្រូវនិងយុត្តិធម៌។ ការិយាល័យOHCHR មិនជំទាស់នឹងភាពចាំបាច់នៃការធ្វើទំនើបភាវូបនីយកម្មវិស័យកសិកម្មទេ ហើយថាការប្រមូលផ្តុំដីកសិកម្មក៏អាចទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀតផងដែរនៅក្នុងទិដ្ឋភាពខ្លះ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការបែបនេះអាចអនុវត្ត និងត្រូវតែអនុវត្តតាមវិធីដែលគោរពសិទ្ធិមនុស្ស ហើយវាជាការសំខាន់ចាំបាច់ខ្លាំងណាស់ដែលសេចក្តីព្រាងច្បាប់នេះត្រូវចែងពីចំណុចនេះឲ្យបានច្បាស់លាស់។ បើតាមបទដ្ឋានសិទ្ធិមនុស្ស កសិករតូចតាចដែលរងផលប៉ះពាល់ គួរតែត្រូវបានបង្ហាញប្រាប់នូវព័ត៌មានពេញលេញអំពីជម្រើសទាំងអស់ដែលពួកគេអាចមាន អំពី

ការផ្ដល់សំណងសមរម្យតាមតម្លៃទីផ្សារ ប្រសិនជាពួកគេជ្រើសរើសយកជម្រើសលក់ដីរបស់ខ្លួន ហើយត្រូវផ្ដល់ការជួយឧបត្ថម្ភគាំទ្រពេញលេញ ដើម្បីជួយពួកគេឆ្លងផុតដំណាក់កាលផ្លាស់ប្ដូរនេះឆ្ពោះទៅរកជីវភាពថ្មីមួយដែលមិនមានការបាត់បង់ដល់គុណភាពនៃជីវិតរបស់ពួកគេ។ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ក៏ភាពចាំបាច់នៃប្រសិទ្ធភាពតែមួយមុខនោះ មិនអាចជាមូលហេតុសមស្របនៃការបណ្ដេញពួកគេដោយបង្ខំចេញពីដីធ្លីរបស់ខ្លួនបានឡើយ។ ក្នុងករណីនេះ ភាពចន្លោះប្រហោងដ៏ធំមួយនៅក្នុងសេចក្ដីព្រាងច្បាប់នេះ គឺការមិនមានចែងពីលក្ខណៈវិនិច្ឆ័យ នីតិវិធី ឬជម្រើសជាដំណោះស្រាយជាក់លាក់នានា ដែលតាមរយៈនេះដំណើរការនៃការប្រមូលផ្ដុំដីកសិកម្មតូចៗនឹងត្រូវបានធ្វើនិយ័តកម្ម។ ទន្ទឹមគ្នានេះដែរ ក៏មិនមានបទប្បញ្ញត្តិកំណត់អំពី រចនាសម្ព័ន្ធកម្មសិទ្ធិថ្មីដែលកើតចេញពីការប្រមូលផ្ដុំដីកសិកម្មតូចៗ ដែលអាចនឹងនាំឲ្យមានហានិភ័យនៃទំនាស់ទាក់ទងនឹងដីធ្លីច្រើនថែមទៀត នៅថ្ងៃអនាគត។

ការព្រួយបារម្ភបំផុតនោះគឺការខ្វះលក្ខណៈវិនិច្ឆ័យ ដែលអាចចែកឲ្យដាច់ពីគ្នារវាងកសិកម្មខ្នាតតូច និងកសិឧស្សាហកម្មខ្នាតធំ នៅក្នុងការអនុវត្តទោសប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី៦ ដែលរួមមានទាំងការពិន័យជាប្រាក់យ៉ាងច្រើន ដែលវាច្បាស់ជាហួសពីលទ្ធភាពរបស់កសិករដែលធ្វើកសិកម្មគ្រាន់តែចិញ្ចឹមជីវិត។ វាជាការចាំបាច់ដែលត្រូវបង្កើតឡើងនូវកិច្ចធានាការពារដ៏មុតមាំនៃនីតិវិធីត្រឹមត្រូវ កំណត់អប្បបរមានិងអតិបរមានៃការពិន័យចំពោះបទល្មើសដែលអាចដាក់ទណ្ឌកម្មបានក្រោមច្បាប់នេះដែលចៅក្រមអាចសម្រេចថា មានពិរុទ្ធភាព ឬគ្មានទោស ហើយធានាការពារចំពោះការអនុវត្តទណ្ឌកម្មសមហេតុផលនិងសមាមាត្រនៃទណ្ឌកម្ម ក្នុងករណីដែលកើតមានការរំលោភបំពានច្បាប់។

ដោយពិចារណាអំពីសារៈសំខាន់និងភាពស្មុគ្រស្មាញនៃច្បាប់នេះ និងទស្សនៈដែលបានសំដែងដោយក្រុមពាក់ព័ន្ធនានា រួមទាំងកសិករតូចតាច សហគមន៍ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល ការិយាល័យOHCHR មើលឃើញថាដំណើរការពិគ្រោះយោបល់នេះហាក់មានការចូលរួមមិនទាន់ពេញលេញនៅឡើយ។ សំណៅផ្សេងៗនៃសេចក្ដីព្រាងច្បាប់នេះ ត្រូវបានបញ្ចេញ ឬអាចរកបានតែនៅដំណាក់កាលក្បែរបំផុតទៅនឹងពេលពិគ្រោះយោបល់ថ្នាក់តំបន់ និងថ្នាក់ជាតិ ឧទាហរណ៍ជាអាទិ៍សេចក្ដីព្រាងលើកទី៦ ដែលសំណៅជាភាសាអង់គ្លេសត្រូវបានចែកចាយនៅថ្ងៃសុក្រទី១៦ ខែធ្នូ ២០១៦ សម្រាប់កិច្ចពិគ្រោះយោបល់ដែលត្រូវធ្វើនៅថ្ងៃច័ន្ទ ទី១៩ ខែធ្នូ ហើយការពិគ្រោះយោបល់នោះទៀតសោត ជារឿយៗមិនសូវមានការជម្រុញលើកទឹកចិត្តឲ្យមានការជជែកពិភាក្សាប្រកបដោយអត្ថន័យឡើយ។ សេចក្ដីព្រាងច្បាប់លើកទី២ និងលើកទី៥ មិនត្រូវបានបញ្ចេញជាសាធារណៈនោះទេ។ ការធានាការពារសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈនៅក្នុងការអនុវត្តជាក់ស្ដែង វាអាចបង្កើតឲ្យមានការព្រមព្រៀងរួមគ្នាមួយ ដែលត្រូវការពេលវេលាគ្រប់គ្រាន់សម្រាប់ការជជែកពិភាក្សា ការលើកអំណះអំណាងដោយសេរី ហើយប្រសិនជាចាំបាច់ក៏ត្រូវឲ្យមានការសិក្សាស្រាវជ្រាវលើបញ្ហាដែលមានភាពចម្រូងចម្រាសផងដែរ។ ការជជែកពិភាក្សាគួរតែផ្អែកលើព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ ដែលត្រូវបានចែករំលែកដោយតម្លាភាពជាភាសា និងទម្រង់ដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់អាចទទួលយកបានក្នុងរយៈពេលមួយសមស្របនៅមុនពេលនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈទៀតផង។ ដើម្បីបង្ហាញពីការគោរពសិទ្ធិមនុស្ស ដំណើរការគឺមានសារៈសំខាន់ដូចគ្នានឹងលទ្ធផល។

សេចក្ដីវិភាគនេះគ្របដណ្ដប់តែលើមាត្រាទាំងឡាយនៃសេចក្ដីព្រាងច្បាប់ស្ដីពីដីកសិកម្ម ដែលមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស។ មាត្រាជាច្រើនដទៃទៀតដែលការិយាល័យOHCHR មិនបានផ្ដល់មតិយោបល់ គឺ

មិនមានសរសេរនៅទីនេះទេ ហើយការរក្សាទុកមាត្រាមួយចំនួននៅទីនេះដោយគ្មានមិតិយោបល់ដើម្បីងាយស្រួលយោងតែប៉ុណ្ណោះ (ដើម្បីជួយសម្រួលដល់ការយល់ដឹងអំពីមាត្រាដែលត្រូវបានវិភាគ ហើយដែលមាត្រាទាំងនោះជាសេចក្ដីយោង)។ សេចក្ដីវិភាគនេះផ្អែកលើអត្ថបទបកប្រែជាភាសាអង់គ្លេសមិនផ្លូវការដោយគម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គ (MRLG) នៃសេចក្ដីព្រាងច្បាប់ដែលចេញផ្សាយក្នុងខែតុលា ឆ្នាំ ២០១៦។

## II.ការវិភាគផ្នែកសិទ្ធិមនុស្ស

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ច្បាប់នេះមានគោលបំណងកំណត់ក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងដីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មតិយោបល់៖** ជាការសំខាន់ដែលត្រូវចែងតាំងពីដើមដំបូងថា សេចក្តីព្រាងច្បាប់នេះ មានគោលបំណងបង្កើតនូវក្របខណ្ឌគតិយុត្តដែលទទួលស្គាល់ជាក់លាក់ការលើកកម្ពស់និងការពារសិទ្ធិមនុស្ស នៅក្នុងចំណោមគោលបំណងទាំងអស់នៃច្បាប់នេះ ។

**ការិយាល័យOHCHRសូមផ្តល់អនុសាសន៍**ឲ្យជំនួសមាត្រា១ នូវប្រយោគនេះ៖ *"ច្បាប់នេះមានគោលបំណងកំណត់ក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងដីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សន្ធិសញ្ញានិងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានាដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី។*

មាត្រា២.-

ច្បាប់នេះមានគោលដៅ ៖

- គាំទ្រគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍផលិតកម្មកសិកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម
- ធានានូវការគ្រប់គ្រង និងការប្រើប្រាស់ធនធានដីកសិកម្ម ដើម្បីទ្រទ្រង់ផលិតកម្មកសិកម្មយូរអង្វែងប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងមាននិរន្តរភាព
- បង្កើនសក្តានុពលផលិតកម្មកសិកម្ម ស្របតាមលក្ខណៈធម្មជាតិនៃធនធានដីកសិកម្ម ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ ដែលផ្អែកលើវិស័យកសិកម្មជាមូលដ្ឋាន
- ថែរក្សា កែលម្អគុណភាពដីកសិកម្ម និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកសិកម្មប្រកបដោយប្រសិទ្ធិភាពដើម្បីធានាការអភិវឌ្ឍផលិតកម្មដំណាំកសិកម្មប្រកបដោយនិរន្តរភាព
- ចូលរួមការពារនិងអភិរក្សធនធានដីកសិកម្ម រួមជាមួយការអភិរក្សប្រព័ន្ធអេកូឡូស៊ីបរិស្ថានរួមនៃតំបន់ផលិតកម្មកសិកម្ម ដែលមានសារៈសំខាន់សម្រាប់មត៌កកសិកម្មជាតិ។

**មតិយោបល់៖** ដើម្បីធានាថាសេចក្តីព្រាងច្បាប់នេះនឹងត្រូវបានប្រើប្រាស់ជាឧបករណ៍ សម្រាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងមិនត្រូវបានធ្វើយុត្តិកម្មសម្រាប់ការរំលោភសិទ្ធិមនុស្សទេនោះ ជាការសំខាន់ដែលខ្លឹមសារអំពីការធានានេះ ត្រូវបានបញ្ចូលនៅក្នុងគោលបំណងនៃសេចក្តីព្រាងច្បាប់។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍** បន្ថែមចំនួនពីរចំណុចដូចខាងក្រោម៖

- *ត្រូវធានាថា មិនមានសកម្មភាពណាមួយអនុវត្តក្រោមច្បាប់នេះ រួមចំណែកដល់ការរំលោភសិទ្ធិមនុស្សឡើយ។*
- *ដាក់បញ្ចូលដំណើរការដែលគិតគូរដោយយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្ស ថាជាផ្នែកមួយដ៏សំខាន់នៃការធ្វើការវាយតំលៃផលប៉ះពាល់ផ្សេងៗ។*

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

មាត្រា៥.-

ការគ្រប់គ្រងធនធានដីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម។

ក្រសួងទទួលបន្ទុកវិស័យកសិកម្មបំពេញសមត្ថកិច្ចក្នុងក្របខណ្ឌនៃការគ្រប់គ្រងធនធានដីកសិកម្ម ដោយអនុលោមតាមច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មតិយោបល់៖** ជាការសំខាន់ដែលច្បាប់នេះត្រូវចែងឲ្យបានច្បាស់ថា ច្បាប់នេះនឹងត្រូវបានអនុវត្តស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលកំពុងអនុវត្ត។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យបន្ថែមទៅក្នុងកថាខ័ណ្ឌទី២ នៃមាត្រា៥៖ *"ក្រសួង...ដោយអនុលោមតាមច្បាប់នេះ បទដ្ឋានអន្តរជាតិដែលកំពុងអនុវត្ត និងបទបញ្ញត្តិពាក់ព័ន្ធជាធរមាន"*

មាត្រា៧.-

ក្រោមវិសាលភាពនៃច្បាប់នេះ អង្គការទទួលបន្ទុកកិច្ចការធនធានដីកសិកម្ម បំពេញបេសកម្ម និងភារកិច្ច ដូចខាងក្រោម៖

១. គ្រប់គ្រងធនធានដីកសិកម្មរួមជាមួយហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការប្រើប្រាស់ដីកសិកម្មគ្រប់រូបភាព សម្រាប់ទិសដៅផលិតកម្មប្រកបដោយនិរន្តរភាព។

២. សិក្សា រៀបចំ និងលើកសំណើគោលនយោបាយយុទ្ធសាស្ត្រ និងក្របខណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយប្រសិទ្ធភាព។

៣. សិក្សា រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម កម្រិតជាតិ កម្រិតក្រោមជាតិ រយៈពេលវែង និងផែនការសកម្មភាពគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្មនៅគ្រប់កម្រិត។

៤. សិក្សា កំណត់អត្តសញ្ញាណនៃតំបន់ផលិតកម្មកសិកម្មនិងផ្ទៃដីដាំដុះ ព្រមទាំងកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ការធ្វើចំណាត់ថ្នាក់ធនធានដីកសិកម្ម ដើម្បីបង្កើតផែនទីប្រើប្រាស់ដីកសិកម្ម ជាមូលដ្ឋានបច្ចេកទេស និងជាឧបករណ៍គតិយុត្តក្នុងការអនុវត្តច្បាប់នេះ ដោយសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៥. សិក្សា ប្រមូលព័ត៌មាន និងបង្កើតមូលដ្ឋានទិន្នន័យស្តីពីវិស័យកសិកម្ម ដែលឆ្លុះបញ្ចាំងអំពីកត្តាវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គម និងប្រព័ន្ធអេកូឡូស៊ី ដើម្បីកំណត់នូវសក្តានុពលធនធានដីកសិកម្ម និងផលិតភាពកសិកម្ម ព្រមទាំងតម្រូវការនៃការអភិវឌ្ឍ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ដែលអាចធានានិរន្តរភាពសម្រាប់ផលិតកម្មដំណាំកសិកម្ម។

៦. ស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធព័ត៌មាន និងមូលដ្ឋានទិន្នន័យស្តីពីធរណីសាស្ត្រ អេកូឡូស៊ីសាស្ត្រ និងការប្រើប្រាស់ធនធានដីកសិកម្មសម្រាប់ការតាមដាន និងការវាយតម្លៃស្ថានភាពប្រែប្រួល គុណភាពដី និងផលប៉ះពាល់នៃឱនភាពដី ដើម្បីកំណត់នូវកម្មវិធី និងវិធានការទប់ស្កាត់ ឬការស្តារគុណភាពដីឡើងវិញ។

៧. អនុវត្តការចុះបញ្ជីប្រើប្រាស់ដីកសិកម្ម ធ្វើជំរឿនដីកសិកម្ម គ្រប់គ្រងរាល់សកម្មភាព និងគម្រោងវិនិយោគ ផលិតកម្មកសិកម្មដែលប្រើប្រាស់ធនធានដីកសិកម្ម ដោយជំរុញការអនុវត្តវិធានសម្រាប់កិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព និងបទបញ្ញា អភិរក្សធនធានដីកសិកម្ម។

៨. គាំទ្រសហគមន៍កសិកម្ម និងអ្នកប្រើប្រាស់ដីកសិកម្ម ដែលអនុវត្តកិច្ចប្រតិបត្តិកសិកម្ម ប្រកបដោយនិរន្តរភាព និងប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ព្រមទាំងការចូលរួមក្នុងការថែរក្សាគុណភាពដីកសិកម្ម តាមរយៈការផ្តល់ជំនួយបច្ចេកទេស ការលើកទឹកចិត្ត និងការធ្វើសកម្មភាពគាំទ្រផ្សេងទៀតស្របតាមគោលបំណងនៃច្បាប់នេះ។

៩. ផ្តល់សេវាកម្មបច្ចេកទេស ក្នុងការកំណត់តំបន់សក្តានុពលសម្រាប់ផលិតកម្មកសិកម្ម ធ្វើការអង្កេត ការវាយតម្លៃ និងការកែលម្អគុណភាពដីកសិកម្ម ព្រមទាំងផ្តល់សេវាកម្មលើការងារវិស្វកម្មកសិកម្មសម្រាប់ផលិតកម្មដំណាំកសិកម្ម។

១០. ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ ដោយមានការចូលរួមជាប្រព័ន្ធពីគ្រប់ភាគីពាក់ព័ន្ធ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈដែលបង្ហាញអំពីសារៈសំខាន់នៃការគ្រប់គ្រងការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សធនធានដីកសិកម្ម រួមជាមួយការស្តារឡើងវិញនូវធនធានដីកសិកម្មនិងប្រព័ន្ធអេកូឡូស៊ី។

១១. ជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយប្រសិទ្ធិភាព។

១២. តាមដាន ស្រាវជ្រាវ ទប់ស្កាត់ និងចាត់វិធានការចំពោះរាល់សកម្មភាពល្មើសច្បាប់នៅក្នុងកិច្ចប្រតិបត្តិកសិកម្មមិនសមស្រប ដែលនាំមកនូវការបំផ្លាញគុណភាពដីកសិកម្ម និងប្រព័ន្ធអេកូបរិស្ថាន ការរានដីកសិកម្មថ្មី ការទុកចោលទំនេរ ឬការបង្កកដីកសិកម្ម សម្រាប់ជំនួញដីក្រៅគោលបំណងកសិកម្ម និងជំរុញការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព។

១៣. បំពេញភារកិច្ចផ្សេងទៀត ក្នុងក្របខណ្ឌនៃគោលបំណង និងវិសាលភាពនៃច្បាប់នេះ។

**មតិយោបល់៖** មាត្រា៧ ចែងអំពីបេសកម្មរបស់អង្គភាពដែលទទួលបន្ទុកកិច្ចការធនធានដីកសិកម្មឲ្យរៀបចំគោលនយោបាយកសិកម្ម លើកកម្ពស់ និងឃ្លាំមើលការអនុវត្តគោលនយោបាយនេះ។ មាត្រា៩ ចែងអំពីលក្ខខណ្ឌដែលតម្រូវឲ្យរដ្ឋធ្វើការពិគ្រោះយោបល់ជាសាធារណៈ លើការសម្រេចចិត្តលើគោលនយោបាយកសិកម្ម។ នៅពេលពិនិត្យមើលលើមាត្រាទាំងពីររួមគ្នាឃើញថា លក្ខខណ្ឌដើម្បីធ្វើការពិគ្រោះយោបល់ជាសាធារណៈ ត្រូវបានទុកចោលដោយមិនមានបញ្ជាក់ពីស្ថាប័នទទួលខុសត្រូវណាមួយជាក់លាក់ ដែលជាការទុកឲ្យមាននូវភាពស្រពិចស្រពិលអំពីថាតើជាបន្ទុករបស់អង្គភាពដែលទទួលបន្ទុកកិច្ចការធនធានដីកសិកម្ម ឬអង្គភាពណាមួយផ្សេងទៀត។ ការិយាល័យ OHCHR មានកង្វល់ថា ការបែងចែកភារកិច្ចធ្វើការពិគ្រោះយោបល់ក្នុងមាត្រា៩ ចេញពីតួនាទីរបស់អង្គភាពនេះនៅក្នុងមាត្រា៧ អាចនឹងត្រូវបកស្រាយក្នុងន័យថា ការពិគ្រោះយោបល់ជាសាធារណៈមិនត្រូវបានសន្មត់ថា ធ្វើឡើងនៅដំណាក់កាលបង្កើតគោលនយោបាយនោះទេ។

ការិយាល័យOHCHR បញ្ជាក់ពីសារៈសំខាន់នៃកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យនៅដំណាក់កាលធ្វើគោលនយោបាយ ជាពិសេសជាមួយបុគ្គល និងសហគមន៍ដែលនឹងរងផលប៉ះពាល់ ដែលអាចឈានទៅបង្កើតបាននូវគោលនយោបាយល្អប្រសើរថែមទៀត ដោយរួមបញ្ចូលនូវវិធានការដែលកាត់បន្ថយហានិភ័យសិទ្ធិមនុស្សឲ្យនៅកម្រិតអប្បរមា។ សិទ្ធិនេះមានចែងក្នុងមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលក្នុងនោះ "បុគ្គលគ្រប់រូបមានសិទ្ធិ និងមានឱកាស (ដោយមិនមានការរើសអើង)...និងដោយគ្មានការរឹតត្បិតមិនសមហេតុផលដល់៖ (ក) ការចូលរួមក្នុងកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី...។"

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនដែលកម្ពុជាជាភាគី បានកំណត់កាតព្វកិច្ចរបស់រដ្ឋក្នុងការលុបបំបាត់ការរើសអើងក្នុងការចូលរួមក្នុងកិច្ចការសាធារណៈនិងកិច្ចការនយោបាយ។ មាត្រា ៧ នៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចែងយ៉ាងជាក់លាក់ថា "រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងជីវភាពនយោបាយនិងសាធារណៈរបស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវលក្ខខណ្ឌស្មើភាពជាមួយបុរសនូវសិទ្ធិ"។ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ក្នុងមាត្រា៥ តម្រូវឲ្យរដ្ឋភាគីលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ក្នុងការអាស្រ័យផលសិទ្ធិដែលក្នុងនោះមានសិទ្ធិនយោបាយ ជាពិសេសសិទ្ធិចូលរួមការបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត តាមប្រព័ន្ធនៃការបោះឆ្នោតជាសកល និងស្មើភាពសិទ្ធិចូលរួមក្នុងរដ្ឋាភិបាល ក៏ដូចជាក្នុងការដឹកនាំការងារសាធារណៈនៅគ្រប់ជាន់ថ្នាក់ និងមានលទ្ធភាពស្មើគ្នាក្នុងការបំរើការងារសាធារណៈ"។

ការពិគ្រោះយោបល់ដ៏មានអត្ថន័យ ទាមទារឲ្យមានការបញ្ចេញជាសាធារណៈនូវ ព័ត៌មានពាក់ព័ន្ធទាំងអស់ជាមុន មុននឹងមានការពិគ្រោះយោបល់។ នៅពេលដែលOHCHR គាំទ្រដល់សេចក្តីត្រូវការដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ដូចបានរំលេចនៅក្នុងវាក្យខណ្ឌទី១០ ការបញ្ជូនជាឯកតោភាគីនូវព័ត៌មានពីរដ្ឋាភិបាលទៅសាធារណៈជន ជាការឆ្លើយតបមិនបានពេញលេញទៅនឹងការការផ្លាស់ប្តូរព័ត៌មាននិងទស្សនៈទៅវិញទៅមកនៃព័ត៌មាននិងទស្សនៈដែលអាចជាលទ្ធផលចេញមកពីការពិគ្រោះយោបល់ជាសាធារណៈ។ (សូមមើលមតិយោបល់បន្ថែមទៀតលើមាត្រា៩)

ជាបន្ថែមទៀត OHCHR គត់សំគាល់ឃើញថា កថាខណ្ឌទី១ នៃមាត្រានេះ ប្រគល់ការទទួលខុសត្រូវទៅឲ្យរដ្ឋាភិបាលក្នុងការ "គ្រប់គ្រង" ធនធានដីកសិកម្ម។ ពាក្យដដែលនេះ ប្រើជាថ្មីទៀតនៅក្នុងកថាខណ្ឌទី២ នៃមាត្រា៩០ ដែលក្នុងនេះក្រសួងទទួលបន្ទុកវិស័យកសិកម្មគ្រប់គ្រងធនធានដីកសិកម្ម*អចិន្ត្រៃយ៍* តាមរយៈសកម្មភាពកម្មវិធីអប់រំផ្សព្វផ្សាយមួយចំនួន។ ទន្ទឹមនឹងសេចក្តីព្រាងច្បាប់នេះទទួលស្គាល់ថា ដីអាចជាកម្មវត្ថុនៃការកាន់កាប់ និងសិទ្ធិប្រើប្រាស់ទៅតាមការរៀបចំផ្សេងៗក្រោមជំពូកទី៥ រួមមានទាំងសម្បទានិក ជនជាតិដើមភាគតិច និងអ្នកដ៏ទៃទៀតដែលទំនងនឹងទទួលខុសត្រូវក្នុងការចាត់ចែងដីរបស់ខ្លួន និងអំពីសកម្មភាពគ្រប់គ្រងដែលអាជ្ញាធរពាក់ព័ន្ធអាចត្រូវអនុញ្ញាតិអោយអនុវត្តក្រោមមាត្រា៧នៃច្បាប់នេះ ដូច្នេះកថាខណ្ឌទី១ គួរតែកំណត់ឲ្យឃើញច្បាស់ពីភាពខុសគ្នារវាងការគ្រប់គ្រងដោយអ្នកកាន់កាប់និងអ្នកប្រើប្រាស់ និងការគ្រប់គ្រងដោយអាជ្ញាធរ។ ប្រសិនជាចេតនាគឺជាការរឹតត្បិតសកម្មភាពគ្រប់គ្រងដែលអនុញ្ញាត ដូចទៅនឹងសកម្មភាពទាំងឡាយដែលមានរៀបរាប់ក្នុងកថាខណ្ឌទី២ នៃមាត្រា៩០ ដូចច្នេះគួរតែចែងពីចំនុចទាំងនេះ។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យគាត់តែងឡើងវិញនូវវាក្យខណ្ឌទី១០ ដូចខាងក្រោម៖

*"លើកកម្ពស់ការអនុវត្តន៍កម្មវិធីផ្សព្វផ្សាយអប់រំនិងការពិគ្រោះយោបល់ ដោយគ្រប់ភាគីពាក់ព័ន្ធនឹងត្រូវបានអញ្ជើញចូលរួមជាប្រព័ន្ធ ហើយតាមរយៈនោះ ព័ត៌មានអំពីគោលនយោបាយកសិកម្មបានស្នើឡើងនឹងត្រូវបានចែករំលែក និងមានការស្វែងរកការមូលមតិគ្នាលើបញ្ហាទាក់ទងទៅនឹងការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សដីកសិកម្ម ក៏ដូចជាការស្តារឡើងវិញនូវដីកសិកម្មនិងប្រព័ន្ធអេកូឡូស៊ី។ ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាពិសេសក្នុងចំណោមបុគ្គល និងសហគមន៍ដែលនឹងរងផលប៉ះពាល់នឹងត្រូវធ្វើឡើងដោយឈរលើមូលដ្ឋាននៃការបង្ហាញព័ត៌មានពាក់ព័ន្ធទាំងអស់យ៉ាងពេញលេញនិងទាន់ពេលវេលា។"*

## ជំពូកទី៣

## និរន្តរភាពនៃធនធានដីកសិកម្ម

**មាត្រា៩.-**

ការគ្រប់គ្រងធនធានដីកសិកម្មត្រូវធានានិរន្តរភាពសម្រាប់ផលិតកម្មកសិកម្ម តាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ស្របតាមគោលនយោបាយដីធ្លី និងគោលនយោបាយជាតិធនធានដីកសិកម្ម។

រដ្ឋធានាការចូលរួមជាសាធារណៈនូវរាល់សេចក្តីសម្រេចចិត្តទាំងឡាយ ដែលអាចបង្កហានិភ័យលើនិរន្តរភាពនៃការប្រើប្រាស់ធនធានដីកសិកម្មរបស់សហគមន៍មូលដ្ឋាន ដែលមានជីវភាពពឹងអាស្រ័យលើមុខរបរកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មតិយោបល់៖** ការដាក់ជាកាតព្វកិច្ចនូវការធានាការចូលរួមជាសាធារណៈទៅក្នុងការធ្វើសេចក្តីសម្រេចក្រោមផ្នែកស្តីពី"និរន្តរភាពនៃធនធានដីកសិកម្ម" និងពាក្យពេចន៍ប្រើនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា៩ បញ្ជាក់ថា ការចូលរួមជាសាធារណៈគឺតម្រូវឲ្យមានតែនៅពេលដែលសកម្មភាពចិញ្ចឹមជីវិត និងការប្រតិបត្តិរបស់សហគមន៍មូលដ្ឋានគំរាមកំហែងដល់និរន្តភាពនៃធនធានដីកសិកម្ម ដោយមិនតម្រូវឲ្យមានតាំងពីដំណាក់កាលដំបូង ឬក៏នៅពេលដែលសេចក្តីសម្រេចចិត្តនានា អាចនឹងប៉ះពាល់ដល់និរន្តភាពនៃការចិញ្ចឹមជីវិតរបស់ប្រជាជន។ ការិយាល័យOHCHR សូមធ្វើការគូសបញ្ជាក់ថា ការចូលរួមក្នុងកិច្ចការសាធារណៈ គឺជាសិទ្ធិមនុស្សមួយ ដូចដែលមានចែងនៅក្នុងមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ហើយអាស្រ័យហេតុនេះ ត្រូវតែតម្រូវឲ្យមាននៅមុនពេលដែលគោលនយោបាយកសិកម្មនានា ត្រូវបានអនុម័ត និងអនុវត្ត។ (សូម មើលមតិយោបល់ លើមាត្រា៧)។

ត្រូវមានការយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមដែលជាប្រពៃណីត្រូវបានគេមើលរំលង ដើម្បីធានាថា ពួកគេត្រូវបានបញ្ចូលនៅក្នុងដំណើរការទាំងនេះ។ ក្នុងចំណោមក្រុមនោះ មានស្ត្រី ជាពិសេសស្ត្រីជនបទ។ មាត្រា១៤ (២) នៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទចែងថា "រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានាដល់ការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី និងជាពិសេសត្រូវធានាឲ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ៖ (ក) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់។ និង (ច) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍ ។"

សិទ្ធិរបស់ជនជាតិដើមភាគតិចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺមានចែងក្នុង មាត្រា១៨ នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ដែលបើតាមមាត្រានេះ *"ជនជាតិដើមភាគតិចមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តលើរាល់បញ្ហាដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេតាមរយៈតំណាងដែលជ្រើសតាំងដោយពួកគេផ្ទាល់ស្របតាមនីតិវិធីរបស់ខ្លួនក៏ដូចជាមានសិទ្ធិរក្សានិងបង្កើតស្ថាប័នជនជាតិដើមភាគតិចដែលមានតួនាទីធ្វើសេចក្តីសំរេចនានា"*។

នៅក្នុងការអនុវត្តជាក់ស្តែង បទពិសោធន៍បង្ហាញថា ការពិគ្រោះយោបល់ជាសាធារណៈអាចនឹងមិនគ្រប់លក្ខណៈទេ ប្រសិនជាបទប្បញ្ញត្តិមិនបានចែងកំណត់អំពី ជំហ៊ានជាក់លាក់នានាដែលត្រូវចាត់ឡើង ដើម្បីធានាឲ្យមានការចូលរួមប្រកបដោយអត្ថន័យ។ បទដ្ឋានសិទ្ធិមនុស្សតម្រូវឲ្យមាននូវ គោលការណ៍ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ(FPIC) ដូចមានចែងក្នុងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) នៅគ្រប់ការសំរេចនានាដែលអាចប៉ះពាល់ដល់ជីវិតរបស់មនុស្ស។ (សូមមើលសំណើររបស់ការិយាល័យ OHCHR ឲ្យបន្ថែម "ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) នៅក្នុងសន្ទានុក្រម"។

ចំពោះដំណើរការទាំងឡាយណាដែលទទួលបានដោយមានការយល់ព្រមរបស់ជនជាតិដើមភាគតិច ដែលប្រកបដោយអត្ថន័យ ដំណើរការនោះគួរតែបានប្រព្រឹត្តិទៅតាមរយៈនីតិវិធី និងស្ថាប័ននានាដែលកំណត់ដោយជនជាតិដើមភាគតិចផ្ទាល់។ ជនជាតិដើមភាគតិចគួរតែបញ្ជាក់ឲ្យបានជាក់លាក់ថា ស្ថាប័នជាតំណាងណា ដែលខ្លួននឹងអនុញ្ញាតឲ្យបង្ហាញពីការយល់ព្រមក្នុងនាមខ្លួន។

សិទ្ធិចូលរួមជាសាធារណៈអនុវត្តចំពោះបុគ្គលគ្រប់រូបដែលអាចនឹងទទួលរងផលប៉ះពាល់។ គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ ដែលកម្ពុជាបានទទួលយក កំណត់ការពិគ្រោះយោបល់ និងការចូលរួមថាជា "ការចូលរួម និងការស្វែងរកការគាំទ្រពីអ្នកទាំងឡាយដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ ដែលអាចទទួលរងផលប៉ះពាល់ពីការសម្រេចចិត្ត មុនពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង និងការឆ្លើយតបទៅនឹងការរួមចំនែករបស់ពួកគេ ដោយពិចារណាអំពីអតុល្យភាពអំណាចរវាងភាគីផ្សេងៗ និងការធានាឲ្យបាននូវការចូលរួមរបស់បុគ្គល និងក្រុមយ៉ាងសកម្ម ដោយសេរី ដោយប្រសិទ្ធភាព ដោយអត្ថន័យ និងដោយទទួលព័ត៌មានគ្រប់គ្រាន់អំពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធ។"

លក្ខខណ្ឌជាមុនកំណត់សម្រាប់ការចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចការសាធារណៈ និងដំណើរការធ្វើការសម្រេចចិត្ត គឺលទ្ធភាពដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធ។ សិទ្ធិទទួលព័ត៌មាន មានចែងក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង មាត្រា១៩ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបើតាមមាត្រានេះ "សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ" ត្រូវរាប់បញ្ចូលទាំង "សេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង"។ ក្នុងករណីនៃអ្នកការពារសិទ្ធិមនុស្ស សិទ្ធិនេះត្រូវបានពង្រឹងនៅក្នុងមាត្រា៦ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។[1]

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ថា វិធានច្បាស់លាស់ដើម្បីគ្រប់គ្រងលើការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈគួរតែបង្កើតឲ្យមានឡើង ដោយបន្ថែមនូវបទប្បញ្ញត្តិដូចខាងក្រោម៖

*"ក្រសួងទទួលបន្ទុកវិស័យកសិកម្ម ត្រូវធានាថា គម្រោង ផែនការ សកម្មភាព ឬការសម្រេចផ្សេងៗ ក្នុងវិស័យកសិកម្ម នឹងត្រូវបើកឲ្យមានការចូលរួមជាសាធារណៈ ស្របតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលត្រូវកំណត់ដោយប្រកាសសម្រាប់អនុវត្ត៖*

*ក) ការជូនដំណឹងពីដំបូង៖ អាជ្ញាធរពាក់ព័ន្ធទទួលខុសត្រូវលើគម្រោង ផែនការ សកម្មភាព ឬការសម្រេចផ្សេងៗដែលនឹងមានផលប៉ះពាល់លើជីវភាពរស់នៅរបស់បុគ្គលនិងសហគមន៍ ត្រូវផ្សព្វផ្សាយពីគម្រោង ផែនការ សកម្មភាព និងការសម្រេចទាំងនោះ ឲ្យបានយ៉ាងហោចណាស់ក៏ ១២ខែ មុនការចាប់ផ្តើម។*

---

[1] យោងមាត្រា៦ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស "ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ៖ (ក) ដឹង ស្វែងរក យកបាន ទទួល និងរក្សាព័ត៌មានស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ រួមមានការទទួលបាននូវព័ត៌មានស្តីពីរបៀបផ្តល់អនុភាពដល់សិទ្ធិ និងសេរីភាពទាំងនោះផង ក្នុងប្រព័ន្ធច្បាប់ តុលាការ ឬរដ្ឋបាលនៅក្នុងប្រទេស។ (ខ) ដូចមានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស និងលិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធ មានសេរីភាពក្នុងការបោះពុម្ព ចែកចាយ ឬផ្សព្វផ្សាយដោយសេរីទៅកាន់អ្នកដទៃទៀត អំពីទស្សនៈ ព័ត៌មាន និងការយល់ដឹងស្តីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់។ (គ) សិក្សា ពិភាក្សា បង្កើត និងមានមតិលើការអនុវត្តទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ និងទាក់ទាញការយកចិត្តទុកដាក់ពីសាធារណៈជនទៅលើបញ្ហាទាំងនោះ តាមរយៈមធ្យោបាយទាំងនេះ និងមធ្យោបាយសមស្របផ្សេងទៀត។"

ខ) ព័ត៌មានទទួលបាន៖ ក្រសួងទទួលខុសត្រូវឬស្ថាប័នពាក់ព័ន្ធត្រូវធានាថា គ្រប់បុគ្គលដែលនឹងរងផលប៉ះពាល់ត្រូវតែទទួលបានទាន់ពេលវេលានូវរាល់ព័ត៌មានចាំបាច់ ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព ក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តលើវិស័យកសិកម្ម។ ក្រុមហ៊ុនដែលត្រូវបានជ្រើសរើសឱ្យអនុវត្តគម្រោង ត្រូវតែបញ្ចេញព័ត៌មានអំពី ទំនាក់ទំនងបុគ្គលនិងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធទាំងអស់ ការវាយតម្លៃហេតុប៉ះពាល់ដែលបានធ្វើឡើង និងព័ត៌មានអំពីផលវិបាកដែលអាចមាននៃគម្រោង ផែនការ សកម្មភាព ឬការសម្រេចផ្សេងៗ។ កិច្ចព្រមព្រៀងស្របច្បាប់ដែលរដ្ឋាភិបាលប្រគល់ឱ្យក្រុមហ៊ុននូវសិទ្ធិអនុវត្តគម្រោង ត្រូវរួមបញ្ចូលនូវបទប្បញ្ញត្តិជាក់លាក់ដែលកំណត់យ៉ាងច្បាស់អំពីប្រយោជន៍សាធារណៈទាក់ទងនឹងព័ត៌មានទាំងនោះ ហើយដែលវិធានស្ដីពីការរក្សាការសំងាត់ចំពោះព័ត៌មានទាំងនេះមិនត្រូវយកមកអនុវត្តឡើយ។

គ) ការគោរពវប្បធម៌សហគមន៍មូលដ្ឋាន៖ គម្រោង ផែនការ សកម្មភាព ឬការសម្រេចផ្សេងៗត្រូវបង្កើតឡើងដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃបែបវិទ្យាសាស្ត្រដែលសមស្របនិងមានភាពពាក់ព័ន្ធ ហើយនិងផ្អែកលើការយល់ដឹងជាប្រពៃណីរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ រួមទាំងជនជាតិដើមភាគតិចផងដែរ។

ឃ) ក្របខណ្ឌពេលវេលាសមស្រប៖ ដំណើរការនៃការចូលរួមជាសាធារណៈ ផ្ដល់ឱ្យសាធារណៈជននូវពេលវេលាគ្រប់គ្រាន់ និងសមហេតុផល ដើម្បីវាយតំលៃលើព័ត៌មានដែលបានបង្ហាញ និងឆ្លើយតបចំពោះសំណើរដែលពាក់ព័ន្ធ និងសេចក្ដីសម្រេចដែលស្នើរឡើងដោយម្ចាស់គម្រោង ឬដោយក្រសួង ឬស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធដទៃផ្សេងទៀត។

ង) កម្រិតសមស្របសម្រាប់ការចូលរួម៖ រាល់ដំណើរការនៃការចូលរួមជាសាធារណៈត្រូវតែផ្ដល់នូវឱកាសពិតប្រាកដដល់សាធារណៈជន ដើម្បីចូលរួមនៅដំណាក់កាលនីមួយៗ នៃដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ ជនជាតិដើមភាគតិចត្រូវមានលទ្ធភាពកំណត់យកស្ថាប័នតំណាងដែលមានសិទ្ធិបង្ហាញពីការយល់ព្រមក្នុងនាមបុគ្គលឬសហគមន៍ដែលរងផលប៉ះពាល់។ អត្រាអប្បរមាកំណត់ចំពោះអ្នកចូលរួមជាស្ត្រីនៅក្នុងកិច្ចពិគ្រោះយោបល់ត្រូវកំណត់យក [xx]%។

ច) ដំណើរការដែលសម្របតាម៖ រាល់ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវរៀបចំ អនុវត្ត និងកែសម្រួលទៅតាមការចាំបាច់ដើម្បីឱ្យស្របទៅនឹងសេចក្ដីត្រូវការ និងកាលៈទេសៈនៃគម្រោង ផែនការសកម្មភាព ឬសេចក្ដីសម្រេច ហើយដើម្បីឱ្យឆ្លុះបញ្ចាំងពីសេចក្ដីត្រូវការ និងការចង់បានរបស់អ្នកចូលរួម ។

ឆ) លទ្ធផលប្រកបដោយគម្លាភាព៖ រាល់ការចូលរួមចំណែកពីសាធារណៈជន នឹងត្រូវយកមកពិចារណាក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត។ ដំណើរការនៃការចូលរួមជាសាធារណៈ ដែលនៅដំណាក់កាលចុងក្រោយ នឹងត្រូវផ្ដល់ព័ត៌មាន និងហេតុផលអំពីថាតើ ធាតុចូលពីសាធារណជនត្រូវបានពិចារណា និងមានឥទ្ធិពលដល់សេចក្ដីសម្រេចចុងក្រោយយ៉ាងដូចម្ដេចខ្លះ។

ជ) យន្តការ និងនីតិវិធីនានា ត្រូវបង្កើតឡើងដើម្បីពិនិត្យផ្ទៀងផ្ទាត់ថា ពិតជាមានការស្វែងរកការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ។ ការបង្កើតយន្តការនិងនីតិវិធីទាំងនេះត្រូវមានការចូលរួមពីសហគមន៍រងផលប៉ះពាល់ រួមទាំងជនជាតិដើមភាគតិច។

# ជំពូកទី៥

# ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម

## ផ្នែកទី១

## បទប្បញ្ញត្តិដីកសិកម្ម

មាត្រា២៤.-

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលកាន់កាប់និងប្រើប្រាស់ធនធានដីកសិកម្ម ក្រោមគោលបំណងផលិតកម្មដំណាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានករណីយកិច្ចអនុវត្តកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព ស្របតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ។

រាជរដ្ឋាភិបាលលើកទឹកចិត្ត និងផ្តល់នូវការគាំទ្រចំពោះការចូលរួមជាសាធារណៈក្នុងការអនុវត្តកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព ចំពោះកម្មសិទ្ធិករដីធ្លី និងប្រជាកសិករដែលកាន់កាប់និងប្រើប្រាស់ដីកសិកម្ម សម្រាប់ផលិតកម្មដំណាំកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចូលរួមគាំទ្រ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយជាតិធនធានដីកសិកម្ម និងផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងនិងប្រើប្រាស់ធនធានដីកសិកម្ម តាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រសួងទទួលបន្ទុកវិស័យកសិកម្ម និងចូលរួមជំរុញការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ក្នុងការបំពេញករណីកិច្ច អនុវត្តកិច្ចប្រតិបត្តិកសិកម្ម ប្រកបដោយនិរន្តរភាព។

**មតិយោបល់៖** ការដាក់កាតព្វកិច្ចឲ្យកសិករ "អនុវត្តកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តភាព" ដូចមានចែងក្នុងវាក្យខណ្ឌ១ នៃមាត្រា២៤ បើកឱកាសឲ្យរដ្ឋាភិបាលដាក់ការត្រួតត្រាថ្មីមួយលើការប្រើប្រាស់ដីដោយគ្រួសារកសិករដែលជាកម្មវត្ថុនៃវិធានការទណ្ឌកម្ម ក្នុងករណីខកខានមិនបានបំពេញតាមការកំណត់ក្រោមជំពូកទី៦។ ភាពស្រពិចស្រពិលនៃប្រយោគ "ប្រតិបត្តិកសិកម្ម ប្រកបដោយនិរន្តភាព" នឹងអនុញ្ញាតឲ្យភ្នាក់ងាររដ្ឋមានឆន្ទានុសិទ្ធិបង្អាក់ដោយបំពានដល់ផលិតភាពកសិកម្មរបស់កសិករ។ ទន្ទឹមនឹងបញ្ជីនៃវិធាននៃកិច្ចប្រតិបត្តិទាំងនេះកំណត់ក្នុងមាត្រា២៦ ជួយដោះស្រាយកង្វល់នេះមួយផ្នែក ប៉ុន្តែវានៅមិនច្បាស់ទេថាតើនៅកម្រិតណាដែលអាចចាត់ទុកថាកសិករមិនបានបំពេញតាមមាត្រានេះ។ បទប្បញ្ញត្តិនេះសន្មត់ថា កសិករទាំងអស់ស្ថិតក្នុងតួនាទីច្បាស់លាស់មួយដើម្បីទទួលអនុវត្តកិច្ចប្រតិបត្តិកសិកម្មទាំងនេះ។

លក្ខខណ្ឌតម្រូវសម្រាប់អាជ្ញាធរក្នុងការលើកកម្ពស់ការយល់ដឹងអំពី បច្ចេកទេស ឧបករណ៍ និងកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព (ដូចមានចែងក្នុងមាត្រា៧ វាក្យខណ្ឌ៦ ដល់១០ និងមាត្រា២៤ វាក្យខណ្ឌ២) ហើយដែលជាហេតុផល ដើម្បីជួយដល់កសិករក្នុងការទទួលយកជាបណ្តើរៗនូវកិច្ចប្រតិបត្តិល្អប្រសើរ គឺជាការចង់បានដើម្បីដាក់កាតព្វកិច្ចឲ្យកសិករគោរពតាមលក្ខខណ្ឌតម្រូវក្នុងការអនុវត្តកិច្ចប្រតិបត្តិប្រកបដោយនិរន្តរភាពដែលចែងយ៉ាងស្រពិចស្រពិល ហើយដែលមាននូវផលវិបាកខាងទណ្ឌកម្ម។ ចំណុចនេះគួរតែចែងឲ្យស្របតាមមាត្រា១១ វាក្យខណ្ឌ២(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែល

កម្ពុជាជារដ្ឋភាគី ហើយដែលបង្កើតនូវការទទួលខុសត្រូវរបស់រដ្ឋក្នុងការចាត់វិធានការផ្សេងៗ "ដើម្បីធ្វើឲ្យប្រសើរឡើងដល់វិធីនៃការផលិត ការរក្សាទុក និងការចែកចាយម្ហូបអាហារដោយការប្រើប្រាស់ពេញលេញនូវចំណេះដឹងខាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដោយ... ការអភិវឌ្ឍន៍ ឬការកែទម្រង់របបដីធ្លី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។"

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យ**ធ្វើការកែសម្រួលមាត្រា២៤ វាក្យខណ្ឌ១ ថា៖ *"រូបវន្តបុគ្គលឬនីតិបុគ្គល... ត្រូវបានលើកទឹកចិត្តឲ្យអនុវត្តកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ។"* ដើម្បីធានាថា កម្មវិធីផ្សព្វផ្សាយដូចបានតម្រូវ នឹងត្រូវផ្តោតជាពិសេសទៅលើអ្នកទាំងឡាយណាដែលតាមបទពិសោធជាក់ស្តែងបង្ហាញថាមានការលំបាកដើម្បីឲ្យការផ្សព្វផ្សាយបានទៅដល់ពួកគេ ការិយាល័យOHCHR សូមផ្តល់អនុសាសន៍បញ្ចូលអត្ថបទថ្មីខាងក្រោមនេះទៅក្នុងវាក្យខណ្ឌ២ នៃមាត្រា២៤៖

*"...កិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព សម្រាប់កម្មសិទ្ធិករដីធ្លី និងប្រជាកសិករ រួមទាំងក្រុមងាយរងគ្រោះ មានដូចជាស្ត្រី ជនជាតិដើមភាគតិច និងកសិករដែលធ្វើកសិកម្មសម្រាប់តែចិញ្ចឹមជីវិត ដែល...."*

**មាត្រា២៦.-**

វិធានរួមសម្រាប់កិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព ត្រូវបានកំណត់ដូចខាងក្រោម៖

១- ត្រូវប្រើប្រាស់ដីកសិកម្មក្នុងក្របខណ្ឌនៃគោលបំណងផលិតកម្មដំណាំកសិកម្ម។

២- ត្រូវប្រើប្រាស់ដីកសិកម្ម ស្របតាមលក្ខខណ្ឌធម្មជាតិនៃប្រព័ន្ធអេកូឡូស៊ី និងត្រូវស្របតាមចំណាត់ថ្នាក់ដីកសិកម្មសម្រាប់ប្រភេទដំណាំសក្តានុពល។

៣- ត្រូវថែរក្សា និងកែលម្អគុណភាពដីកសិកម្មដែលប្រើប្រាស់ ក្នុងគោលបំណងបង្កើន ឬរក្សាកម្រិតជីវជាតិដី រក្សាស្ថេរភាពនៃគុណភាពដីនិងលក្ខណៈសម្បត្តិរបស់ដី និងរក្សាលំនឹងនៃប្រព័ន្ធអេកូឡូស៊ី។

៤- ត្រូវប្រើប្រាស់ធាតុចូលកសិកម្មសមស្របនៅក្នុងផលិតកម្មដំណាំ និងការការពារដំណាំ ដោយជៀសវាងការបំពុលដីកសិកម្ម និងការបំផ្លាញប្រព័ន្ធអេកូឡូស៊ីរួមនៃតំបន់ផលិតកម្មកសិកម្ម។

៥- ត្រូវអនុវត្តបច្ចេកទេសឬមធ្យោបាយចម្រុះនៅក្នុងប្រព័ន្ធផលិតកម្មដំណាំកសិកម្មដោយធានាការទប់ស្កាត់ការហូរច្រោះដីនិងជីជាតិពីទីជម្រាលនិងការទប់ស្កាត់កំណដីនិងខ្សាច់នៅតំបន់ទំនាប។

មាត្រា២៨.-

រូបវន្តបុគ្គលឬនីតិបុគ្គល សាធារណៈឬឯកជន ដែលកាន់កាប់ដីកសិកម្មដែលបានចាត់ថ្នាក់ក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ត្រូវប្រើប្រាស់ដីកម្មសិទ្ធិរបស់ខ្លួន សម្រាប់តែគោលបំណងផលិតកម្មកសិកម្មប៉ុណ្ណោះ។

ដីរដ្ឋអាចធ្វើសម្បទាន ជួល ឬប្រើប្រាស់សម្រាប់គោលបំណងផលិតកម្មដំណាំកលសិកម្ម ដោយផ្អែកតាមចំណាត់ថ្នាក់ធនធានដីកសិកម្ម លក្ខខណ្ឌប្រព័ន្ធអេកូឡូស៊ីបរិស្ថាន និងសក្តានុពលនៃផលិតភាពដីកសិកម្ម តាមប្រភេទដំណាំ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា៖** ពាក្យ "ប៉ុណ្ណោះ" នៅឃ្លាទីមួយនៃមាត្រា២៨ ទំនងជាចង់និយាយថាផ្ទះសម្បែង ឬគ្រោងសំណង់សំខាន់ៗដទៃផ្សេងទៀត អាចនឹងមិនត្រូវបានអនុញ្ញាតឲ្យសាងសង់នៅលើដីកសិកម្មឡើយ។ ដូចបានកំណត់នៅក្នុងសន្ទានុក្រមនៃសេចក្តីព្រាងច្បាប់នេះ "ដីកសិកម្មសំដៅដល់ដីនៃគ្រប់ប្រភេទកម្មសិទ្ធិទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមជាមួយសំណង់ឬ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឲ្យវិស័យកសិកម្មដែលបានប្រើប្រាស់ ឬត្រូវបានបែងចែកដោយគោលនយោបាយដីធ្លី ឬតាមរយៈផែនការប្រើប្រាស់ដីថ្នាក់ជាតិ សម្រាប់ការប្រើប្រាស់ក្រោមគោលបំណងផលិតកម្មកសិកម្ម រួមជាមួយដីសម្បទានសេដ្ឋកិច្ចឬដីសម្បទានសង្គមកិច្ច ដែលផ្តល់ដោយរាជរដ្ឋាភិបាល សម្រាប់ការប្រើប្រាស់ក្នុងគោលបំណងអភិវឌ្ឍផលិតកម្មកសិកម្ម ព្រមទាំងបណ្តាដីទាំងឡាយដែលមានសក្តានុពលផលិតកម្មកសិកម្មផ្សេងទៀតដែលបច្ចុប្បន្នមិនទាន់បានប្រើប្រាស់ ដោយត្រូវធ្វើការចាត់ថ្នាក់ជាធនធានដីកសិកម្ម ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។" ប្រសិនជាមាត្រា២៨ ត្រូវបានបកស្រាយថា ជាការតម្រូវឲ្យកសិករផ្ទេរលំនៅឋានរបស់ខ្លួនចេញពី "ដីកសិកម្ម" របស់ខ្លួន នោះវានឹងផ្ទុយទៅនឹងការរាប់បញ្ចូលគ្រោងសំណង់បែបនោះ ដែលបម្រើឲ្យវិស័យកសិកម្មនៅក្នុងនិយមន័យខាងលើ ហើយជាបន្ថែមទៀត វានឹងមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុជាខ្លាំង ជាពិសេសចំពោះក្រុមគ្រួសារកសិករ។

កថាខ័ណ្ឌ២នៃមាត្រា២៨ បង្ហាញថាដីនឹងត្រូវធ្វើចំណាត់ថ្នាក់ដោយមិនមានការបញ្ជាក់ពីកិច្ចដំណើរការនៃការធ្វើចំណាត់ថ្នាក់ដីនោះទេ។ ប្រសិនបើការធ្វើចំណាត់ថ្នាក់ដី (ឡើងវិញ) លើផ្ទៃដីកសិកម្មគ្រួសារ រារាំងពួកគេពីការបន្តការដាំដុះសម្រាប់ចិញ្ចឹមជីវិត វាអាចនាំមកនូវការប៉ះពាល់ជាខ្លាំងលើសិទ្ធិរបស់ពួកគេក្នុងការទទួលបានបទដ្ឋានក្នុងការរស់នៅមានជីវភាពសមរម្យ និងសិទ្ធិក្នុងការជ្រើសរើសការងាររបស់ខ្លួនដោយសេរី ដូចមានចែងក្នុងមាត្រា១១ និងមាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដោយសារហានិភ័យខ្ពស់ដែលនឹងកើតមានឡើងដូចនេះ ដូច្នេះរាល់ការសម្រេចចិត្តដែលមានចរិតលក្ខណៈបែបនេះ គួរតែបានមកពីលទ្ធផលនៃការស្វែងរកការយល់ព្រម តាមរយៈកិច្ចពិគ្រោះយោបល់ជាមួយម្ចាស់ដី និងសហគមន៍មូលដ្ឋានដែលកាន់កាប់ ឬប្រើប្រាស់ដីនោះ។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យកែប្រែមាត្រា២៨ ដូចតទៅនេះ៖ *"រូបវន្តបុគ្គលឬនីតិបុគ្គល សាធារណៈឬឯកជន ដែលកាន់កាប់ដីកសិកម្ម ដែលបានចាត់ថ្នាក់ក្រោមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ត្រូវប្រើប្រាស់ដីសម្រាប់គោលបំណងផលិតកម្មកសិកម្មជាចម្បង។ ការចាត់ថ្នាក់ដីគឺជាលទ្ធផលនៃការពិគ្រោះ*

*យោបល់ជាមួយម្ចាស់ដី និងសហគមន៍មូលដ្ឋានដែលប្រើប្រាស់ដីនោះជាប្រពៃណី ឬពឹងអាស្រ័យលើដីនោះសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។*

**មាត្រា៣៥.-**

បន្ថែមលើបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន រូបវន្តបុគ្គលឬនីតិបុគ្គល កម្មសិទ្ធិករដីធ្លី ដែលកាន់កាប់ និងប្រើប្រាស់ដីកសិកម្ម ដែលមានទំហំចាប់ពី០៥ (ប្រាំ)ហិកតា ឡើងទៅ ពុំមានសិទ្ធិទុកដីឲ្យនៅទំនេរ ឬបង្កកដីដោយមិនអនុវត្តផលិតកម្មកសិកម្ម នៅក្នុងរយៈពេលមិនលើសពី០៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទ ចុះក្នុងឯកសារបញ្ជាក់កម្មសិទ្ធិកាន់កាប់ដី បានឡើយ។

កម្មសិទ្ធិករដីកសិកម្មដែលទុកចោលទំនេរ ឬមិនអនុវត្តផលិតកម្មកសិកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវប្រឈមចំពោះការពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់នេះ។

រាជរដ្ឋាភិបាលមានសិទ្ធិសម្រេចឲ្យក្រសួងទទួលបន្ទុកវិស័យកសិកម្ម ចាត់វិធានការចំពោះ ដីកសិកម្មដែលទុកចោលទំនេរ ដើម្បីប្រើប្រាស់ជាបណ្តោះអាសន្នសម្រាប់ប្រយោជន៍សាធារណៈក្រោមគោលបំណងផលិតកម្មកសិកម្ម នៅក្នុងរយៈពេលចាប់ពី០១ (មួយ)ឆ្នាំ ឡើងទៅរហូតដល់ពេលមានការស្នើសុំពីកម្មសិទ្ធិករឬម្ចាស់ដីនោះជាថ្មី ដើម្បីប្រើប្រាស់ដីកសិកម្មជាកម្មសិទ្ធិរបស់ខ្លួន ក្រោមផលិតកម្មកសិកម្មឡើងវិញ។

**មតិយោបល់៖** ការិយាល័យOHCHR ទទួលស្គាល់ពីចេតនាពិតប្រាកដនៃបទប្បញ្ញត្តិនេះដែលអនុញ្ញាតឲ្យរដ្ឋាភិបាលបែងចែកឡើងវិញ ដោយសកម្មជាមុននិងជាបណ្តោះអាសន្ននូវដី ដែលមិនត្រូវបានគេប្រើប្រាស់សម្រាប់គោលដៅផលិតកម្មកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យOHCHR កត់សំគាល់ថាមាត្រា៣៥ នេះ ហាក់ដូចជាផ្ទុយទៅនឹងសិទ្ធិលើអចលនទ្រព្យ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៤ ដែលចែងថា "ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ..." មាត្រានេះក៏ផ្ទុយផងដែរទៅនឹងមាត្រា១៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលចែងថា "មនុស្សគ្រប់រូប ទោះតែម្នាក់ឯងក្តី ឬដោយរួមជាមួយអ្នកដទៃក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិតាមអំពើចិត្តឡើយ ។"

ក្នុងស្ថានភាពជាក់ស្តែង មាត្រា៣៥ នេះ កាត់បន្ថយលទ្ធភាពរបស់ម្ចាស់ដី ដែលសម្រេចចិត្តឈប់បង្កបង្កើនផលជាបណ្តោះអាសន្នដោយមូលហេតុចាំបាច់មួយចំនួន។ ដោយយល់ឃើញថាប្រភេទដំណាំខ្លះ ការប្រតិបត្តិបែបប្រពៃណីនៃកសិកម្មពនេចររបស់ក្រុមជនជាតិដើមភាគតិចមួយចំនួន មានការទទួលស្គាល់នៅក្នុងមាត្រា៣៧ ឬកាលៈទេសៈដ៏ទៃទៀតអាចតម្រូវឲ្យទុកដីឲ្យនៅទំនេរក្នុងអំឡុងពេលណាមួយ ដូច្នេះការកំណត់រយៈពេល ៣ឆ្នាំ ទំនងជារយៈពេលខ្លីពេក ដែលជាការចាត់ទុកថា ដីនោះត្រូវបានគេទុកចោល ឬមិនប្រើប្រាស់។ ម្យ៉ាងវិញទៀត ដូចជាការចុះថោកខ្លាំងនៃតម្លៃផលដំណាំធ្វើឲ្យកសិកម្មមិនទទួលបានផលចំណេញនៅពេលមួយ និងអាចមានហេតុផលជាច្រើនទៀត ដែលមិនអាចដឹងជាមុន ចំពោះការទុកដីឲ្យនៅទំនេរមិនប្រើប្រាស់។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**លុបចោលមាត្រានេះ។

## ផ្នែកទី២

## ដីកសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច

មាត្រា៣៧.-

រដ្ឋធានាសិទ្ធិប្រើប្រាស់ដីកសិកម្មបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ និងបទដ្ឋានច្បាប់ពាក់ពន្ធ័ជាធរមាន។

ការអនុវត្តកសិកម្មពនេចរដោយសហគមន៍ជនជាតិដើមភាគតិច ត្រូវបានទទួលស្គាល់ដោយច្បាប់នេះ ជាការប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្ម ដែលត្រូវរៀបចំ និងចាត់ថ្នាក់ជាផ្ទៃដីកសិកម្មបម្រុងនៃធនធានដីកសិកម្ម សម្រាប់កសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។

**មតិយោបល់៖** អាស្រ័យដោយទំនាក់ទំនងមិនអាចកាត់ផ្តាច់ពីគ្នាបានរវាងអត្តសញ្ញាណនិងវប្បធម៌ នៅលើទិដ្ឋភាពមួយ និងលើទិដ្ឋភាពមួយទៀតរវាងទំនាក់ទំនងដីធ្លីដែលពួកគេរស់នៅ និងធនធានធម្មជាតិដែលពួកគេពឹងអាស្រ័យ ជនជាតិដើមភាគតិចប្រឈមនឹងហានិភ័យនិងកម្រិតផ្សេងៗនៃការប៉ះពាល់ជាច្រើន ដែលកើតចេញពីសេចក្តីសម្រេចលើការប្រើប្រាស់ដីរបស់ពួកគេ ដែលជារឿយៗរួមមានការបាត់បង់អត្តសញ្ញាណ វប្បធម៌ និងការចិញ្ចឹមជីវិតតាមទំនៀមទំលាប់។ សេចក្តីសម្រេចដែលកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ អាចប៉ះពាល់ដល់ជនជាតិដើមភាគតិច ជាអ្វីដែលក្រុមផ្សេងទៀតក្នុងសង្គមមិនទទួលអារម្មណ៍ថារងផលប៉ះពាល់។ តាមសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP) ការសម្រេចបែបនេះ អាចកើតមានតែក្នុងករណីលើកលែងតែប៉ុណ្ណោះ ហើយបន្ទាប់ពីទទួលបានការយល់ព្រមពីសហគមន៍ពាក់ព័ន្ធចំពោះការតាំងទីលំនៅថ្មី ដែលជាការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ ជាមុន និងដោយសេរី។ ទំនាស់អាចកើតមានឡើងរវាងការទទួលស្គាល់អំពី "ការប្រើប្រាស់ដីកសិកម្មបែបប្រពៃណី" នៅក្នុងកថាខ័ណ្ឌទី១ និងការចាត់ថ្នាក់ដីជា "ដីប្រើប្រាស់សម្រាប់គោលបំណងកសិកម្ម" នៅក្នុងកថាខ័ណ្ឌទី២ ជាពិសេស ក្នុងករណីជនជាតិដើមភាគតិច ដែលការប្រតិបត្តិវប្បធម៌របស់ពួកគេ មានរួមទាំងកសិកម្មពនេចរ។ សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា៩ និងគោលការណ៍យល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ ជាមុន និងដោយសេរី (FPIC) ក្នុងសន្ធានុក្រម។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យបន្ថែមនូវមាត្រាមួយដែលបញ្ជាក់ឡើងវិញពី មាត្រា ២៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ទៅក្នុងសេចក្តីព្រាងច្បាប់នេះ។ ដោយនិយាយយោងទៅលើដី ៥ ប្រភេទ (ដីលំនៅឋាន ដីស្រែចំការដាំដុះដាក់ស្តែង ដីបម្រុងចាំបាច់ក្នុងការផ្លូវវេនដំណាំ ដីព្រៃអារក្ស និងដីកប់ខ្មោច) ដែលមានកំណត់នៅក្នុងមាត្រា៦ នៃអនុក្រឹត្យលេខ ៨៣ ដែលមានចំណងជើងថា "អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច" ដែលផ្តល់សិទ្ធិកម្មសិទ្ធិដល់ជនជាតិដើមភាគតិច ហើយដែលការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា ដីទាំងនេះត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ។

ដើម្បីធានាការពារជនជាតិដើមភាគតិចពីផលប៉ះពាល់អវិជ្ជមានទាក់ទងនឹងដីធ្លី បទដ្ឋានគតិយុត្តអន្តរជាតិ តម្រូវថា នីតិវិធីពិគ្រោះយោបល់ជាពិសេសនិងដោយលែកពីគេ ត្រូវបានធ្វើឡើងតាមការចាំបាច់ ដើម្បីបង្កលក្ខណៈឲ្យជនជាតិដើមភាគតិចចូលរួមប្រកបដោយអត្ថន័យ។ លំនាំនៃវប្បធម៌ផ្សេងពីគេ ប្រវត្តិសាស្ត្រ ក៏

ដូចជា ភាសា និងភាពខុសពីគេផ្សេងៗទៀតនៃជនជាតិដើមភាគតិច អាចជាការរារាំងពួកគេពីការចូលរួមពិគ្រោះយោបល់ដែលរៀបចំឡើងសម្រាប់ប្រជាជនខ្មែរដទៃទៀត ដែលជារឿយៗនាំឲ្យពួកគេត្រូវបានផាត់ចេញពីដំណើរការប្រជាធិបតេយ្យបែបសាមញ្ញនេះទាំងផ្នែកខ្លឹមសារនិងដំណើរការ ហើយលុះត្រាតែមានវិធានការគិតទុកជាមុនយ៉ាងល្អ ត្រូវបានចាត់ឡើង ទើបដោះស្រាយភាពចន្លោះប្រហោងទាំងអស់នេះបាន។

មាត្រា២៣ ដល់ មាត្រា២៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ និងមាត្រា១៥ មាត្រា៣៧ និងមាត្រា៤០ ដល់មាត្រា៤៧ នៃច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចជាម្ចាស់លើដីរបស់ពួកគេ ដែលឆ្លើតបទៅនឹងសិទ្ធិលើអចលនទ្រព្យ ដែលមានចែងក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា១៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា៣៥)។ ទោះជាយ៉ាងណាក៏ដោយ មាត្រា៣៧ ត្រូវបានតាក់តែងឡើងក្នុងន័យចង្អៀតដែលមើលសេចក្តីទៅផ្ទុយនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រានេះធ្វើការយោងទៅលើការប្រតិបត្តិកសិកម្មពនេចររបស់សហគមន៍ជនជាតិដើមភាគតិច ហើយទទួលស្គាល់ការប្រតិបត្តិនេះដោយច្បាប់នេះថាជា "ដីប្រើប្រាស់សម្រាប់គោលដៅកសិកម្ម" ដែលត្រូវបានរៀបចំ និងចាត់ថ្នាក់ថាជាដីបំរុងកសិកម្មនៃធនធានដីកសិកម្ម សម្រាប់កសិកម្មតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។ ភាពខុសគ្នារវាងសិទ្ធិដែលផ្តល់ឲ្យជនជាតិដើមភាគតិចក្រោមរូបភាព "ដីបំរុងកសិកម្ម" និងក្រោមរូបភាពប័ណ្ណកម្មសិទ្ធិសមូហភាពដែលសហគមន៍ជនជាតិដើមភាគតិចអាចធ្វើការស្នើសុំតាមមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា២៣ ដល់មាត្រា២៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ គួរតែត្រូវបានស្រាយបំភ្លឺ។

មាត្រា១៨ នៃ UNDRIP ចែងថា "ជនជាតិដើមភាគតិចមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តលើរាល់បញ្ហាដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ" ចំនែកឯមាត្រា១៩ តម្រូវឲ្យ "រដ្ឋទាំងឡាយត្រូវពិគ្រោះយោបល់ និងសហការដោយសុចរិតជាមួយជនជាតិដើមភាគតិចពាក់ព័ន្ធ...ដើម្បីទទួលបានការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ ជាមុន និងដោយសេរី(FPIC) មុននឹងអនុម័តនិងអនុវត្តវិធានការច្បាប់ឬវិធានការរដ្ឋបាលដែលអាចប៉ះពាល់ដល់ជនជាតិដើមភាគតិច។" ដូច្នេះការយល់ព្រមរបស់ក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ត្រូវតែខិតខំស្វែងរកសម្រាប់លើរាល់ការសម្រេចចិត្តទាំងអស់ដែលប៉ះពាល់ដល់ពួកគេ ដែលរួមមានការពិគ្រោះយោបល់យ៉ាងសកម្មជាមួយពួកគេនៅគ្រប់ដំណាក់កាលនៃគម្រោង។ មាត្រានេះចែងបន្តទៀតថា ក្នុងករណីដែលជនជាតិដើមភាគតិចយល់ថា គម្រោងនេះធ្វើឲ្យអន្តរាយដល់សិទ្ធិមនុស្សរបស់ពួកគេ ពួកគេមានសិទ្ធិដកការគាំទ្ររបស់ខ្លួនចំពោះគម្រោងនេះ និងសកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធ។ នៅក្នុងស្ថានភាពទាំងនេះ ផ្នែកនៃគម្រោងដែលជនជាតិដើមភាគតិចរំពឹងថានឹងមានផលប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិរបស់ពួកគេ មិនគួរបន្តធ្វើតទៅទៀតឡើយ។

**ការិយាល័យ** OHCHR **សូមផ្តល់អនុសាសន៍** កែសម្រួលមាត្រា៣៧ ដូចតទៅ៖

*"រដ្ឋធានាសិទ្ធិប្រើប្រាស់ដីកសិកម្មបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះនិងបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន រួមទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលកំពុងអនុវត្ត។*

*ការអនុវត្តកសិកម្មពនេចរដោយសហគមន៍ជនជាតិដើមភាគតិច ត្រូវបានទទួលស្គាល់ថាជាការប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្ម។ ដីទាំងនេះនឹងត្រូវចាត់ថ្នាក់ជាដីកសិកម្មបម្រុងនៃធនធានដីកសិកម្មសម្រាប់អនុវត្តកសិកម្មប្រពៃណីរបស់ជនជាតិដើមភាគតិច។*

*ដីដែលបានកំណត់តាមច្បាប់ថាមានលក្ខណៈគ្រប់គ្រាន់សម្រាប់កម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបំរុងទុកសម្រាប់ការប្រើប្រាស់របស់ពួកគេ ហើយមិនត្រូវប្រើប្រាស់ក្នុងគោលបំណងផ្សេងឡើយ លើកលែងតែ "កិច្ចការងារដែលរដ្ឋបំពេញដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិ" ដូចមានចែងក្នុងមាត្រា២៦ នៃច្បាប់ភូមិបាលឆ្នាំ២០០១។*

*រដ្ឋធានាការពារសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ដីកសិកម្មបែបប្រពៃណីក្រោមបទប្បញ្ញត្តិនិងនីតិវិធីដែលបង្កើតឡើងក្រោមច្បាប់នេះ និងច្បាប់ជាធរមានដទៃទៀត ជាពិសេសច្បាប់ភូមិបាលឆ្នាំ២០០១ អនុក្រឹត្យលេខ ៨៣ (លេខ ៨៣ អនក្រ.បក) និងគោលនយោបាយជាតិឆ្នាំ២០០៩ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច។*

*រដ្ឋធានាការពារសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច រួមទាំងការស្វែងរកការយល់ព្រមពីពួកគេតាមរយៈការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ នៅពេលដែលមានវត្តមានរបស់ពួកគេនៅទីតាំងគម្រោង ហើយមានទំនាក់ទំនងជាសមូហភាពទៅនឹងទីតាំងគម្រោងនោះ ឬមានសិទ្ធិកម្មសិទ្ធិឬការកាន់កាប់ជាប្រពៃណីតាមមាត្រា២៦ (២) នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) រួមទាំងសិទ្ធិធ្វើជាម្ចាស់ សិទ្ធិប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងដី ដែនដី និងធនធានធម្មជាតិ។*

*ការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច ត្រូវតែធ្វើដោយគ្មានការគំរាមកំហែងឬបង្ខិតបង្ខំ ត្រូវតែធ្វើឡើងមុនការបែងចែងដីធ្លីសម្រាប់គម្រោងជាក់លាក់ និង/ឬការអនុម័តយល់ព្រមលើគម្រោងនិងសកម្មភាពទាក់ទងនឹងគម្រោងដែលមានផលប៉ះពាល់ដល់ដី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងស្វែងរកឲ្យមានការធានាថាអ្នកដែលរងផលប៉ះពាល់ ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី ទទួលបានព័ត៌មានពេញលេញ ហើយអាចរកបានរាល់ព័ត៌មានពាក់ព័ន្ធទាំងឡាយ (ពីរដ្ឋាភិបាល ពីគម្រោង និងពីការសិក្សាស្រាវជ្រាវ និងប្រភពឯករាជ្យពីខាងក្រៅ ) ជាភាសា និងទម្រង់ដែលពួកគេអាចយល់បាន ដើម្បីឈានទៅដល់ការយល់ព្រមដោយស្ម័គ្រចិត្ត។ ដំណើរការដែលមានការព្រមព្រៀងគ្នារវាងក្រុមហ៊ុន/អាជ្ញាធររដ្ឋ និងជនជាតិដើមភាគតិចត្រូវចងក្រងជាឯកសារ ហើយកស្តុតាងនៃការព្រមព្រៀងរវាងភាគីទាំងអស់លើលទ្ធផលនៃការចរចាទាំងអស់ត្រូវបញ្ចេញឲ្យដឹងជាសាធារណៈ។*

*ជនជាតិដើមភាគតិចមានសិទ្ធិដកការគាំទ្ររបស់ខ្លួន ចំពោះគម្រោង និងសកម្មភាពពាក់ព័ន្ធនឹងគម្រោងដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ ហើយក៏អាចនឹងជ្រើសរើសមិនចូលរួមក្នុងដំណើរការពិគ្រោះយោបល់ទាក់ទងនឹងគម្រោងនោះផងដែរ។ ផ្នែកណាមួយនៃគម្រោងដែលមិនមានការយល់ព្រមពីសហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ មិនត្រូវបន្តអនុវត្តឡើយ។*

*នៅពេលណាដែលកិច្ចព្រមព្រៀងសម្បទាន ឬកិច្ចសន្យាជួលអាចមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើជនជាតិដើមភាគតិច ហើយនៅពេលដែលការរៀបចំការពិគ្រោះយោបល់មានការព្រមព្រៀងពីអ្នកពាក់ព័ន្ធ ម្ចាស់គម្រោងត្រូវ៖*

*ក) ដោយមានការពិគ្រោះយោបល់ពេញលេញជាមួយសហគមន៍មួយឬច្រើនដែលរងការប៉ះពាល់ កំណត់ពីផលប៉ះពាល់ដែលនឹងកើតមានឡើង និងព្រមព្រៀងលើវិធានការកាត់បន្ថយផលប៉ះពាល់ ព្រមទាំងរៀបចំបែងចែកផលប្រយោជន៍ ជាមួយបុគ្គលដែលពាក់ព័ន្ធទាំងអស់។*

*ខ) ស្វែងរកជម្រើសផ្សេងនៃការបង្កើតគម្រោងដើម្បីជៀសវាងការផ្លាស់ប្តូរទីលំនៅរបស់ជនជាតិដើមភាគតិច។ ក្នុងករណីលើកលែង នៅពេលដែលការផ្លាស់ប្តូរទីលំនៅមិនអាចជៀសវាងបាន ម្ចាស់គម្រោងមិនត្រូវធ្វើការផ្លាស់ប្តូរទីលំនៅជនជាតិដើមភាគតិចចេញពីដីរបស់ពួកគេ ដោយមិនមានការយល់ព្រមពីពួកគេបន្ទាប់ពីពួកគេទទួលបានព័ត៌មានគ្រប់គ្រាន់ ជាមុន និងដោយសេរីឡើយ។ ម្ចាស់គម្រោងត្រូវរៀបចំផែនការតាំងទីលំនៅថ្មីដែលស្របទៅនឹងការចង់បានរបស់សហគមន៍ដែលរងផលប៉ះពាល់ ក្នុងនោះមានទាំងយុទ្ធសាស្ត្រនៃការតាំងទីលំនៅថ្មីដោយផ្អែកលើដីធ្លី។ នៅពេលណាដែលអាចធ្វើទៅបាន ហើយដែលហេតុផលនៃការផ្លាស់ប្តូរទីលំនៅរបស់ពួកគេលែងនៅជាធរមានហើយនោះ ផែនការតាំងទីលំនៅថ្មីគួរអនុញ្ញាតឲ្យអ្នករងផលប៉ះពាល់អាចវិលត្រឡប់ទៅកាន់ដីធ្លី និងដែនដីដែលពួកគេធ្លាប់ជាម្ចាស់ ឬប្រើប្រាស់និងកាន់កាប់បែបប្រពៃណីវិញ។*

*គ) ធានាថាសំណងសម្រាប់ការខូចខាតទ្រព្យសម្បត្តិគឺសមរម្យ សមធម៌ និងអាចទទួលយកបាន និងជាអប្បបរិមាស្មើនិងតម្លៃទីផ្សា និងបន្តធានាថាវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានគិតគូទុកជាមុនគឺមានលក្ខណៈសមស្រប និងមាននិរន្តរភាព។*

*ឃ) ធានាថារាល់ទម្រង់នៃការរើសអើងក្នុងវិធានការកាត់បន្ថយផលប៉ះពាល់ រួមទាំងការរើសអើងផ្អែកលើយេនឌ័រ ត្រូវហាមឃាត់ជាដាច់ខាត និងត្រូវមានដំណោះស្រាយនៅពេលកើតមានករណីរើសអើង និងបន្តធានាថាវិធានការសមស្របនឹងត្រូវចាត់ឡើង សម្រាប់បុគ្គល និងក្រុមទាំងឡាយណាដែលជីវភាពរស់នៅរបស់ពួកគេរងការគំរាមកំហែងខ្លាំងបំផុតដោយសារតែការតាំងទីលំនៅថ្មី ដើម្បីបង្ការស្ថានភាពធ្លាក់ចុះដុនដាបនៃកម្រិតជីវភាពរស់នៅរបស់ពួកគេ។”*

**មាត្រា៣៨.-**

ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវសហការនិងសម្របសម្រួលជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ជនជាតិដើមភាគតិចដើម្បីកំណត់ និងចាត់ថ្នាក់ផ្ទៃដីកសិកម្មបម្រុងសម្រាប់កសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។

សហគន៍ជនជាតិដើមភាគតិចមិនត្រូវបានលើកទឹកចិត្តឱ្យពង្រីកវិសាលភាពនៃការអនុវត្តកសិកម្មពនេចរក្រៅដែននៃផ្ទៃដីកសិកម្មបម្រុងដែលបានចាត់ថ្នាក់និងចុះបញ្ជីប្រើប្រាស់ដីកសិកម្មក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះឡើយ។

ប្រជាពលរដ្ឋដែលធ្វើទេសន្តរប្រវេសន៍ឬធ្វើចំណាកស្រុកពុំមានបុព្វសិទ្ធិជាជនជាតិដើមភាគតិចឡើយ និងពុំមានសិទ្ធិប្រើប្រាស់ដីកសិកម្មដើម្បីអនុវត្តកសិកម្មពនេចរតាមបែបប្រពៃណី ដូចសហគមន៍ជនជាតិដើមភាគតិចឡើយ។

**មតិយោបល់៖** មាត្រា៣៨ ត្រូវមានការយល់ដឹងដោយគិតពិចារណាទៅដល់ច្បាប់ពាក់ព័ន្ធដទៃទៀត ដែលនៅជាធរមាន។ មាត្រា២៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ បានចែងថា "ដីសហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំ..."។ មាត្រា៤ នៃអនុក្រឹត្យ ឆ្នាំ២០០៩ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចចែងថា "ដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំ ឬដីរៀបចំបម្រុងសម្រាប់ចំការពនេចរ ឬដីចំការវិលជុំ សំដៅដល់ដីសហគមន៍ជនជាតិដើមភាគតិច ធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែ ឬជាចំការ ក្នុងការដូរវេនដំណាំតាមប្រពៃណី"។ ជាងនេះទៅទៀត ក្រសួងបរិស្ថានកំពុងតែព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិនៃប្រទេសកម្ពុជា ដែលមានបទប្បញ្ញត្តិអំពីប័ណ្ណកម្មសិទ្ធិសហគមន៍ដែលនឹងត្រូវចេញឲ្យដោយក្រសួងបរិស្ថានដែលសមស្របចំពោះសហគមន៍ជនជាតិដើមភាគតិច។ នេះបង្ហាញថាប័ណ្ណកម្មសិទ្ធិទាំងនោះអាចនឹងរាប់បញ្ចូលទាំងដី ដែលសហគមន៍ជនជាតិដើមភាគតិចចាត់ទុកថាជាដីបម្រុងទុក។ ជាការសំខាន់ចាំបាច់ដែលបទប្បញ្ញត្តិអំពីការចុះបញ្ជីដីធ្លីដែលមានក្នុងច្បាប់ទាំងពីរនេះត្រូវធ្វើឲ្យមានការបំពេញបន្ថែមអោយគ្នាទៅវិញទៅមក នៅមុនការអនុម័តក្រមបរិស្ថាន និងច្បាប់ស្តីពីដីកសិកម្ម។

ជាបន្ថែមលើការផ្តល់មតិយោបល់ និងអនុសាសន៍ទៅលើមាត្រា៣៧ ការិយាល័យOHCHR ធ្វើការកត់សំគាល់ដោយកង្វល់ចំពោះកថាខណ្ឌទី២ នៃមាត្រា៣៨ ដែលហាមឃាត់ការពង្រីកវិសាលភាពនៃការអនុវត្តកសិកម្មពនេចរ ដែលការពង្រីកនេះអាចជាការចាំបាច់ ក្នុងករណីដែលចំនួនប្រជាជននៃសហគមន៍ជនជាតិដើមភាគតិចមួយចំនួនអាចមានការកើនឡើង។ ការអនុវត្តកសិកម្មពនេចរ គឺជាផ្នែកមួយនៃជីវភាពរស់នៅតាមបែបប្រពៃណីនិងទំនៀមទំលាប់របស់សហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានទទួលស្គាល់ជាពិសេស ដោយច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ។

មាត្រា២៤ ដល់មាត្រា២៨ នៃច្បាប់ភូមិបាលទទួលស្គាល់សិទ្ធិនៃសហគមន៍ជនជាតិដើមភាគតិចចំពោះភាពជាម្ចាស់សមូហភាពទៅលើដីរបស់ពួកគេនិងសិទ្ធិក្នុងការគ្រប់គ្រងដីរបស់ពួកគេ។ ដីរបស់សហគមន៍ជនជាតិដើមភាគតិចរួមមាន ដីលំនៅឋាននិងដីកសិកម្ម និងរួមបញ្ចូលទាំងដីបម្រុងទុកសម្រាប់ការប្តូរវេនដំណាំ។ មាត្រា២៣ នៃច្បាប់ភូមិបាលបានចែងថា "ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ"។ ម្យាងវិញទៀតសហគមន៍ជនជាតិដើមភាគតិចគឺត្រូវបានអនុញ្ញាតឲ្យបន្តគ្រប់គ្រងសហគមន៍របស់ពួកគេនិងដីធ្លីតាមប្រពៃណីនិងទំនៀមទំលាប់របស់ពួកគេនៅពេលរង់ចាំការកំណត់ឋានៈផ្លូវច្បាប់សម្រាប់សហគមន៍។ ចំណុចនេះស្របទៅនឹងមាត្រា៣៧ នៃច្បាប់ស្តីពីព្រៃឈើ ដែលអនុញ្ញាតជាពិសេសឲ្យ "សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជិការួចហើយជាមួយរដ្ឋ"។

មាត្រា៥ (ឃ)(v) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ចែងថា "សិទ្ធិ មានកម្មសិទ្ធតែម្នាក់ឯង ក៏ដូចជារួមជាមួយអ្នកដទៃ"។ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិចបញ្ជាក់សិទ្ធិនេះថាជា កាតព្វកិច្ចរបស់រដ្ឋចំពោះជនជាតិដើមភាគតិច "រដ្ឋទាំងឡាយត្រូវផ្តល់យន្តការការពារនិងដោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះ៖...អំពើណាមួយដែលមានបំណងឬមានឥទ្ធិពលដល់ការដកហូតពីពួកគេនូវដីធ្លី ដែនដី ឬធនធានរបស់ពួកគេ" (មាត្រា ៨ (២)(ខ)) និង "សិទ្ធិរក្សា និងបង្កើតប្រព័ន្ធ ឬស្ថាប័ននយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធានាបាននូវមធ្យោបាយក្នុងការចិញ្ចឹមជីវិតនិងការ

អភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ" (មាត្រា ២០ (១))។ ដូច្នេះយោងតាមអនុសញ្ញា និងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិច បង្ហាញថាជនជាតិដើមភាគតិចមានសិទ្ធិចំពោះដីធ្លីនិងធនធាន ក្រោមការកាន់កាប់និងប្រើប្រាស់ជាលក្ខណៈប្រពៃណីនិងការរស់រានតាមទំនៀមទំលាប់របស់ពួកគេ ដូចក្នុងករណីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា គឺពួកគេពឹងផ្អែកលើការអនុវត្តកសិកម្មពនេចរ។ លទ្ធផលនៃកិច្ចសិក្សាស្រាវជ្រាវមួយរបស់អង្គការស្បៀងនិងកសិកម្មបង្ហាញថា ការធ្វើកសិកម្មពនេចរ គឺសំខាន់បំផុតសម្រាប់សន្តិសុខស្បៀងអាហាររបស់ពួកគេ និងនិរន្តរភាពនៃបរិស្ថានផងដែរ។[2]

តាមទស្សនៈខាងលើនេះ ការដាក់កម្រិតកំណត់បែបសិប្បនិម្មិតចំពោះតំបន់ដែលអាចនឹងត្រូវបានប្រើប្រាស់ដោយជនជាតិដើមភាគតិចសម្រាប់ការអនុវត្តកសិកម្មតាមបែបប្រពៃណីរបស់ពួកគេ គឺវាផ្ទុយទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ជាងនេះទៅទៀត ការប្រើប្រាស់ពាក្យអកម្មនិងមិនច្បាស់លាស់ ("មិនត្រូវបានលើកទឹកចិត្តឱ្យពង្រីក...") ធ្វើឱ្យមានការលំបាកក្នុងការគិតឃើញជាមុនអំពីប្រភេទនៃសកម្មភាពជាក់លាក់ ដែលនឹងចាត់ទុកជា "ការលើកទឹកចិត្ត" ហើយដែលនឹងត្រូវវិនិច្ឆ័យថាខុសច្បាប់ ដែលនាំឲ្យមាននូវសំណួរសាមញ្ញជាច្រើន។ ឧទាហរណ៍ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិចដែលមានកំណើនប្រជាជនកើនឡើងដែលដីកសិកម្មបែងចែកឲ្យពួកគេនោះមិនអាចផ្គត់ផ្គង់បានតទៅទៀត វាទំនងជានឹងធ្វើឲ្យអ្នកដឹកនាំសហគមន៍មានពិរុទ្ធភាព ដោយសារការរំលោភទៅលើបទប្បញ្ញត្តិមួយនេះ ប្រសិនបើគាត់ស្វះស្វែងរកការពិភាក្សា និងចរចារឡើងវិញពីព្រំប្រទល់ដីកសិកម្មដែលបានបែងចែកឲ្យសហគមន៍របស់គាត់។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យលុបកថាខ័ណ្ឌទី២ នៃមាត្រា៣៨។

មាត្រា ៤០.-

ការគ្រប់គ្រងដីកសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម។

**មតិយោបល់៖** បន្ថែមពីលើមាត្រា ៨ ((២)(ខ)) និងមាត្រា ២០ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) (សូមមើលមតិយោបល់របស់ការិយាល័យOHCHR ទៅលើមាត្រា៣៨) មាត្រា៣ នៃសេចក្តីប្រកាសដដែលនេះបានចែងថា "ជនជាតិដើមភាគតិចមានសិទ្ធិស្វ័យសំរេច។ តាមស្មារតីនៃសិទ្ធិនេះ ជនជាតិដើមភាគតិចមានសិទ្ធិសំរេចដោយសេរីអំពីឋានៈនយោបាយរបស់ខ្លួន និងធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី" និងមាត្រា៤ ចែងថា "ជនជាតិដើមភាគតិច ក្នុងការអនុវត្តសិទ្ធិស្វ័យសំរេចរបស់ខ្លួន មានសិទ្ធិគ្រប់គ្រងដោយខ្លួនឯង ឬដោយស្វ័យភាពលើបញ្ហាទាំងឡាយដែលទាក់ទងនឹងកិច្ចការផ្ទៃក្នុង និងកិច្ចការនៅមូលដ្ឋានរបស់ខ្លួន ព្រមទាំងវិធីសាស្រ្តនិងមធ្យោបាយផ្សេងៗសម្រាប់ផ្តល់ហិរញ្ញវត្ថុដល់ដំណើរការស្វ័យភាពរបស់ខ្លួន"។ មាត្រា៣ បញ្ជាក់បន្ថែមលើមាត្រា១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ដែលបង្កើតសិទ្ធិស្វ័យសម្រេចសម្រាប់បុគ្គលគ្រប់រូប។ សូមមើលអនុសាសន៍របស់ការិយាល័យOHCHR លើមាត្រា៩។ មាត្រានេះចែងថាការគ្រប់គ្រងដីកសិកម្មបែបប្រពៃណីរបស់ពួកគេ

[2] កសិកម្មពនេចរ សន្តិសុខស្បៀងនិងជីវភាពរស់នៅ បញ្ហាប្រឈមចាស់ និងបញ្ហាប្រឈមថ្មីសម្រាប់សហគមន៍ជនជាតិដើមភាគតិច នៅតំបន់អាស៊ី អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ឆ្នាំ២០១៥។

ជាមួយនឹងភាពចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ជនជាតិដើមភាគតិច គួរតែទុកឲ្យជនជាតិដើមភាគតិចជាអ្នកសម្រេចដោយខ្លួនឯងជាជាងកំណត់ដោយប្រកាស ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យលុបចោលមាត្រានេះ។

## **ផ្នែកទី៣**

## **ដីកសិកម្មក្រោមតំបន់អភិវឌ្ឍន៍កសិកម្ម**

**មតិយោបល់៖** ផ្នែកទី៣ អនុញ្ញាតឲ្យមានការប្រមូលផ្តុំដីដែលកាន់កាប់ដោយកសិករខ្នាតតូចឬកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចធ្វើឲ្យអន្តរាយដល់សិទ្ធិជាច្រើន លុះត្រាតែមានភ្ជាប់ជាមួយនូវវិធានការការពារសមស្របដើម្បីទប់ស្កាត់ការរំលោភបំពាន។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យបន្ថែមមាត្រាណែនាំថ្មីទៅក្នុងផ្នែកទី៣ ដូចតទៅនេះ៖ "*ការអនុវត្តច្បាប់នេះមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធិកាន់កាប់ដីជាប្រពៃណីរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានឡើយ។ រាល់ការសម្រេចបង្កើតតំបន់ដីកសិកម្មឬតំបន់អភិវឌ្ឍន៍កសិកម្មត្រូវផ្អែកលើការវាយតម្លៃយ៉ាងល្អិតល្អន់លើសិទ្ធិកម្មសិទ្ធិនិងប្រើប្រាស់ដីជាប្រពៃណីនៅក្នុងតំបន់ និងត្រូវមានការពិគ្រោះយោបល់ស្វែងរកការព្រមព្រៀងជាមួយអ្នកប្រើប្រាស់ដីដែលមានសិទ្ធិលើដីធ្លីតាមបែបប្រពៃណី*"។ ការិយាល័យOHCHR សូមផ្តល់អនុសាសន៍បន្ថែមថា លក្ខខណ្ឌតម្រូវឲ្យអាជ្ញាធរទទួលស្គាល់ការរៀបចំឲ្យមានការកាន់កាប់តាមបែបប្រពៃណី ត្រូវចែងយោងទៅវិញទៅមកនៅទូទាំងច្បាប់ទាំងមូល។

មាត្រា ៤១.-

> ផ្ទៃដីកសិកម្មដែលកាន់កាប់និងប្រើប្រាស់ដោយកសិករខ្នាតតូចឬមធ្យមសម្រាប់ផលិតកម្មកសិកម្មគ្រួសារអាចប្រមូលផ្តុំបង្កើតជាតំបន់អភិវឌ្ឍន៍កសិកម្មក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍ផលិតកម្មកសិកម្មនិងចូលរួមការប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធិភាពនិងនិរន្តរភាពស្របតាមគោលនយោបាយជាតិធនធានដីកសិកម្ម។

**មតិយោបល់៖** យោងតាមសន្ទានុក្រមជាឧបសម្ពន្ធនៃច្បាប់នេះ "តំបន់អភិវឌ្ឍន៍កសិកម្ម" ដែលបានឃើញក្នុងមាត្រា៤១ គឺសំដៅដល់ "ផ្ទៃដីកសិកម្មដែលកាន់កាប់និងប្រើប្រាស់ដោយកសិករខ្នាតតូចឬមធ្យមសម្រាប់ផលិតកម្មកសិកម្មគ្រួសារ អាចប្រមូលផ្តុំបង្កើតជាតំបន់អភិវឌ្ឍន៍កសិកម្មក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍ផលិតកម្មកសិកម្មនិងចូលរួមការប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធិភាពនិងនិរន្តរភាព ស្របតាមគោលនយោបាយជាតិធនធានដីកសិកម្ម។" មាត្រា៤១ បង្កើតលទ្ធភាពប្រមូលផ្តុំដីធ្លីបែបនេះ។

សំណួរដែលត្រូវលើកឡើងគឺ អំពីផលវិបាកជាសក្តានុពលនៃតំបន់អភិវឌ្ឍន៍កសិកម្មទៅលើដំណើរការដទៃទៀតដែលបានបង្កើតឡើងដើម្បីធ្វើឲ្យសិទ្ធិស្របច្បាប់រួមមានទាំងតាមរយៈប័ណ្ណកម្មសិទ្ធិសមូហភាព និងអំពីវិសាលភាពដែលផលវិបាកនេះអាចបណ្តាលឲ្យមានទំនាស់សង្គមធ្ងន់ធ្ងរចំពោះសិទ្ធិដីធ្លីនិងធនធានធម្មជាតិនៅថ្នាក់មូលដ្ឋាន។ ការលុបចោលផ្នែកមួយដ៏ចាំបាច់ក្នុងមាត្រា ៤១ នោះ គឺលក្ខខណ្ឌដែលថា "ផ្ទៃដីកសិកម្មដែលកាន់កាប់និងប្រើប្រាស់ដោយកសិករខ្នាតតូចឬមធ្យមសម្រាប់ផលិតកម្មកសិកម្មគ្រួសារ អាចប្រមូលផ្តុំ

បង្កើតជាតំបន់អភិវឌ្ឍន៍កសិកម្ម" ដែលបានបង្ហាញថាតំបន់អភិវឌ្ឍន៍កសិកម្មអាចបង្កើតបាននៅស្ទើរគ្រប់ទីកន្លែង នៅលើគ្រប់ទម្រង់នៃដីកសិកម្ម ជាដីឯកជន ដីសមូហភាព ឬសម្បទានដីសង្គមកិច្ច។
ដោយសារ មាត្រា៤១ មិនតម្រូវឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយឬមានការយល់ព្រមពីបុគ្គលនិងសហគមន៍ ដែលរងផលប៉ះពាល់ទាក់ទងនឹងតំបន់អភិវឌ្ឍន៍កសិកម្ម មុនការប្រមូលផ្តុំដី ហើយក៏មិនមាន នីតិវិធីសម្រាប់រំសាយតំបន់អភិវឌ្ឍន៍ទាំងនោះ វាទំនងជានឹងកើតមានឡើងនូវការប្រមូលផ្តុំដីមានលក្ខណៈមិនស្ម័គ្រចិត្តដោយដាក់កំហិតលើបុគ្គលនិងគ្រួសារកសិករ មានទាំងម្ចាស់ដី ឬអ្នកជួលដី និងសហគមន៍ ជនជាតិដើមភាគតិចផងដែរ ដែលអាចជាការរំលោភបំពានគោលការណ៍ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ(FPIC) (សូមមើលសន្ទានុក្រម)។ ជាងនេះទៅទៀត ទោះបីជាមាត្រា៤១ មិនប្រគល់សមត្ថកិច្ចប្រមូលផ្តុំដីទៅឲ្យស្ថាប័នណាមួយជាក់លាក់ក៏ដោយ ក៏មាត្រា៤៣ និងមាត្រា៤៤ ប្រគល់ភារកិច្ចឲ្យ មន្ទីរកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទនៅថ្នាក់មូលដ្ឋាន និងក្រុមប្រឹក្សាឃុំ/សង្កាត់ សហការគ្នាបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋានសាមី ក៏ដូចជាការប្រើប្រាស់ដីកសិកម្ម ដែលជាការបង្ហាញថាសេចក្តីសម្រេចទាំងឡាយទាក់ទងនឹងតំបន់អភិវឌ្ឍន៍កសិកម្ម អាចនឹងត្រូវធ្វើឡើងដោយមន្ទីរកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ និងអាជ្ញាធរមូលដ្ឋាន។ វាហាក់បីដូចជាការមានសិទ្ធិអំណាចទាំងស្រុងក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយសម្រាប់ការប្រមូលផ្តុំដី ដោយមិនធ្វើទៅតាមរយៈមធ្យោបាយ ដែលបុគ្គលនិងសហគមន៍រងការប៉ះពាល់អាចធ្វើការតវ៉ាទៅនឹងសេចក្តីសម្រេចទាំងនោះ ឬធ្វើការទាមទារសំណងតាមផ្លូវច្បាប់។

**ការិយាល័យ** OHCHR **សូមផ្តល់អនុសាសន៍**ថា មាត្រា៤១ គួរសេរសេរឡើងវិញថា៖ *"ផ្ទៃដីកសិកម្មដែលបានកាន់កាប់និងប្រើប្រាស់ដោយកសិករខ្នាតតូចឬមធ្យម សម្រាប់ផលិតកម្មកសិកម្មគ្រួសារ ដោយបន្ទាប់ពីមានការពិគ្រោះយោបល់និងមានការព្រមព្រៀងពីកម្មសិទ្ធិករ អាចប្រមូលផ្តុំបង្កើតជាតំបន់អភិវឌ្ឍន៍កសិកម្ម..."*

**មាត្រា៤៣.-**

ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវជំរុញ និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការសិក្សានិងវាយតម្លៃសក្តានុពលនៃផលិតភាពដីកសិកម្ម និងការប្រើប្រាស់ដីកសិកម្មរបស់កសិករខ្នាតតូចឬមធ្យម ក្នុងគោលបំណងបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម នៅតាមបណ្តាខេត្ត រាជធានី ក្នុងព្រះរាជាណាចក្រកម្ពុជា។

មន្ទីរកសិកម្ម រាជធានី ខេត្តមានភារៈកិច្ចគាំទ្រនិងសហការជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងការរៀបចំនិងការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្មនៅក្នុងមូលដ្ឋានសាមី និងរៀបចំនូវផែនការអភិវឌ្ឍន៍កសិកម្មឃុំ/សង្កាត់រយៈពេលវែង និងផែនការសកម្មភាពប្រចាំឆ្នាំ ដែលកំណត់នូវមូលដ្ឋានទិន្នន័យប្រើប្រាស់ដីកសិកម្មរបស់ឃុំ/សង្កាត់ និងបណ្តាកម្មវិធីការងារកសិកម្មដែលត្រូវអនុវត្តនិងអភិវឌ្ឍន៍ រយៈពេលវែង។

**មតិយោបល់៖** សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៤១ ពាក់ព័ន្ធនឹងសេចក្តីត្រូវការមាននូវលក្ខខណ្ឌតម្រូវ ដើម្បីពិគ្រោះយោបល់និងទទួលបានការយល់ព្រមពីបុគ្គលនិងសហគមន៍ដែលរង

ការប៉ះពាល់។ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពបំពេញភារកិច្ចដែលបានប្រគល់ឲ្យក្រោមមាត្រា៤៣ គឺជាការសំខាន់ដែលត្រូវផ្តល់ឲ្យមានវគ្គបណ្តុះបណ្តាលនិងការគាំទ្រចាំបាច់ដល់ពួកគេ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ថា មាត្រា៤៣ គួរតែសរសេរឡើងវិញដូចខាងក្រោមនេះ៖

*"ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវជម្រុញនិងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការ សិក្សានិងវាយតម្លៃសក្តានុពលផលិតកម្មកសិកម្មនាពេលបច្ចុប្បន្ននិងអនាគតនិងការប្រើប្រាស់ដីកសិកម្មរបស់កសិករខ្នាតតូចឬមធ្យមដែលផ្តល់ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) ដាក់ដីរបស់ពួកគេចូលទៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្មក្នុងខេត្ត/រាជធានីនៃព្រះរាជាណាចក្រកម្ពុជា។*

*មន្ទីរកសិកម្មខេត្ត/រាជធានី គាំទ្រនិងសហកាជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងការរៀបចំ និងការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្មនៅក្នុងមូលដ្ឋានសាមី ដោយផ្អែកលើមូលដ្ឋាននៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីម្ចាស់ដី និងអ្នកជួលដី និងរៀបចំផែនការអភិវឌ្ឍន៍កសិកម្ម ឃុំ/សង្កាត់ រយៈពេលវែង និងមធ្យម និងផែនការសកម្មភាពប្រចាំឆ្នាំ ដែលកំណត់នូវមូលដ្ឋានទិន្នន័យនៃការប្រើប្រាស់ដី កសិកម្មរបស់ឃុំ/សង្កាត់ និង បណ្តាកម្មវិធីការងារកសិកម្មដែលត្រូវអនុវត្ត និងអភិវឌ្ឍរយៈពេលវែង។*

*ក្រសួងទទួលបន្ទុកវិស័យកសិកម្មបណ្តុះបណ្តាលនិងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តន៍កិច្ចពិគ្រោះយោបល់ប្រកបដោយតម្លាភាពនិងការចូលរួម ដើម្បីសម្រេចគោលដៅទាំងនេះ។*

មាត្រា៤៤.-

ផែនការអភិវឌ្ឍន៍កសិម្មឃុំ/សង្កាត់ ត្រូវផ្តោតសំខាន់ទៅលើសក្តានុពលនៃការប្រើប្រាស់ដីកសិកម្ម សម្រាប់ការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ដែលកំណត់នូវបណ្តាកម្មវិធីនិងសកម្មភាពស្របតាមសក្តានុពលធនធានដែលមានស្រាប់របស់មូលដ្ឋាន និងដោយមានការចូលរួមយោបល់ពីគ្រប់ភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន។

ការបង្កើត និងការគ្រប់គ្រងតំបន់អភិវឌ្ឍន៍កសិកម្មត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម។

គោលការណ៍ណែនាំស្តីពីផែនការអភិវឌ្ឍន៍កសិកម្ម ឃុំ/សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងទទួលបន្ទុកវិស័យកសិកម្មនិងក្រសួងមហាផ្ទៃ។

**មតិយោបល់៖** សូមមើលមតិយោបល់និងអនុសាសន៍របស់ការិយាល័យ OHCHR ទៅលើមាត្រា៤៣។

## ផ្នែកទី៤

## ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន

មាត្រា ៤៥.-

ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន ត្រូវបានកំណត់ចំពោះដីរដ្ឋដែលបានធ្វើសម្បទានដោយរាជរដ្ឋាភិបាលក្រោមកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច ឬកិច្ចព្រមព្រៀងសម្បទានផ្សេងទៀតដើម្បីប្រើប្រាស់រយៈពេលវែងក្នុងក្របខណ្ឌនៃការវិនិយោគផលិតកម្មកសិកម្ម កសិឧស្សាហកម្ម ឬគម្រោងអភិវឌ្ឍន៍ផ្សេងទៀតក្រោមគោលបំណងផលិតកម្មកសិកម្ម។

រាជរដ្ឋាភិបាលធានាការប្រើប្រាស់ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន មិនស្ថិតនៅក្រោមទំនាស់ផលប្រយោជន៍របស់សហគមន៍មូលដ្ឋានឡើយ។

ការប្រើប្រាស់ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទានត្រូវមានការចូលរួមពិគ្រោះយោបល់របស់សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធនិងត្រូវអនុលោមតាមគោលនយោបាយជាតិធនធានដីកសិកម្ម ផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ធនធានដីកសិកម្មនិងបទប្បញ្ញត្តិនៃច្បាប់នេះព្រមទាំង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

នីតិវិធីសម្រាប់ដំណើរពិគ្រោះយោបល់លើការប្រើប្រាស់ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម។

**មតិយោបល់៖** ច្បាប់និងនីតិវិធីមួយចំនួនកំពុងនៅជាធរមានដែលគ្រប់គ្រងលើដីសម្បទានសេដ្ឋកិច្ច រួមមានផ្នែកនៃមាតិកាទី២ ជំពូកទី៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចឆ្នាំ២០០៥ ក្រមរដ្ឋប្បវេណី និងអនុក្រឹត្យលេខ១១៤ ស្តីពីការបញ្ចាំ និងការផ្ទេរសិទ្ធិចំពោះការជួលរយៈពេលវែង ឬដីសម្បទានសេដ្ឋកិច្ច (សូមមើលឧបសម្ព័ន្ធទី១)។ ក្នុងខែឧសភា ឆ្នាំ២០១២ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសផ្អាកជាបណ្តោះអាសន្ននូវការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី និងណែនាំឲ្យសមត្ថកិច្ចពិនិត្យមើលឡើងវិញលើដីសម្បទានសេដ្ឋកិច្ចដែលបានផ្តល់កន្លងមក។ ជាលទ្ធផលនៅខែសីហា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីពិនិត្យ កំណត់ និងវាយតម្លៃដីសម្បទានសេដ្ឋកិច្ច។ នៅខែកុម្ភៈ ឆ្នាំ២០១៦ សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសបញ្ចប់ការពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចដោយរាជរដ្ឋាភិបាលកម្ពុជា និងបានសន្យាថានឹងដកហូតមកវិញនូវផ្ទៃដីជិតមួយលានហិកតា ហើយប្រគល់ឲ្យទៅគ្រួសារក្រីក្រ។

ដោយការបន្ថែមបទប្បញ្ញត្តិថ្មីមួយទៀតពីលើវិធាន និងបទប្បញ្ញត្តិជាធរមានបែបនេះ ផ្នែកទី៤ អាចដាក់ឲ្យមានដំណើរការឡើងវិញនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ប្រសិនបើដីសម្បទានមិនពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ជាមួយសហគមន៍មូលដ្ឋានហើយប្រសិនជាមានកិច្ចពិគ្រោះយោបល់ជាមួយពួកគេត្រូវបានធ្វើឡើង។ កថាខណ្ឌទី២ មិនបានកំណត់ច្បាស់លាស់ពីពេលវេលាសម្រាប់កិច្ចពិគ្រោះយោបល់ដែលនឹងត្រូវតែរៀបចំធ្វើឡើងជាមួយអ្នករងផលប៉ះពាល់ ថាតើនឹងត្រូវធ្វើនៅមុនពេលធ្វើការសម្រេចចិត្ត ឬក្នុងពេល ឬក្រោយពេល

សម្បទាន។ លក្ខខណ្ឌតម្រូវសម្រាប់កិច្ចពិគ្រោះយោបល់មិនមានកំណត់ច្បាស់លាស់អំពីដំណើរការដែលធានានូវកិច្ចពិគ្រោះយោបល់ពិតប្រាកដ ដែលខុសពីកិច្ចពិគ្រោះយោបល់គ្រាន់តែជារូបភាព។

ជាបន្ថែម សេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះអនុញ្ញាតឲ្យប្រើប្រាស់ដីសាធារណៈរបស់រដ្ឋជាដីសម្បទានកសិកម្ម ដែលផ្ទុយទៅនឹងមាត្រា១៦ និងមាត្រា១៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលអនុញ្ញាតឲ្យផ្លាស់ប្តូរ ឬផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបាន លុះត្រាតែនៅពេលដែលទ្រព្យសម្បត្តិនោះបាត់បង់ប្រយោជន៍សាធារណៈប៉ុណ្ណោះ។ មាត្រា១៦ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ចែងថា "ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះ មិនអាចកំណត់អាជ្ញាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេស.....ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ"។ តាមមាត្រា១៧ នៃច្បាប់ភូមិបាល ចែងថា "ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់។"

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យធ្វើការតាក់តែងមាត្រា៤៥ ឡើងវិញដូចខាងក្រោមនេះ៖

*"អនុលោមតាមច្បាប់ភូមិបាល អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចនិងក្រមរដ្ឋប្បវេណី ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន ត្រូវបានកំណត់ចំពោះដីឯកជនរបស់រដ្ឋដែលបានធ្វើសម្បទានដោយរាជរដ្ឋាភិបាលសម្រាប់ការប្រើប្រាស់រយៈពេលវែងក្នុងក្របខណ្ឌនៃការវិនិយោគផលិតកម្មកសិកម្ម កសិឧស្សាហកម្ម ឬគម្រោងអភិវឌ្ឍន៍ផ្សេងទៀតក្រោមគោលបំណងផលិតកម្មកសិកម្ម។*

*ផ្ទៃដីនៃដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានលុបចោល ត្រូវបែងចែកជូនគ្រួសារកសិករតាមនីតិវិធីដែលយុត្តិធម៌ សមធម៌ និងតម្លាភាព ឬក៏បញ្ចូលជាដីសម្បទានសង្គមកិច្ច និងជាដីសម្រាប់ការបរិច្ចាគជូនជនក្រីក្រ ស្របតាមតាមមាត្រា៨៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១។ គ្រួសារកសិករដែលបានបាត់បង់ដី ឬនឹងបាត់បង់ដីដោយសារសម្បទានដីសេដ្ឋកិច្ច ត្រូវទទួលបានសំណងសមរម្យ។ ដីដែលមានម្ចាស់ឬកាន់កាប់ដោយគ្រួសារកសិករ នឹងអាចចាត់បញ្ចូលក្នុងសម្បទានដីសេដ្ឋកិច្ចក្នុងពេលអនាគតបាន លុះត្រាណាតែមានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពីពួកគេ។*

*រាជរដ្ឋាភិបាលត្រូវធានាថាកិច្ចព្រមព្រៀងសម្បទាន មិនជាប់ពាក់ព័ន្ធនឹងដីដែលជាកម្មវត្ថុនៃទំនាស់ជាមួយសហគមន៍មូលដ្ឋានឡើយ រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ។ ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវធានាឲ្យមាននូវកិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ចំពោះរាល់គម្រោងសម្បទានទាំងអស់ស្របតាមមាត្រា៩ នៃច្បាប់នេះ។ សម្បទានអាចផ្តល់បានតែចំពោះដីដែលបានចាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋប៉ុណ្ណោះ ស្របតាមច្បាប់ភូមិបាល ឆ្នាំ២០០១។"*

**មាត្រា ៤៧.-**

កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងផលិតកម្មកសិកម្ម ដែលប្រើប្រាស់ដីរដ្ឋត្រូវធានាលក្ខណ្ឌនៃប្រព័ន្ធអេកូឡូស៊ីបរិស្ថាន និងផលិតភាពដីនៃទីតាំងស្នើសុំ ដែលឆ្លើយតបតាមប្រភេទដំណាំសក្តានុពល និងមានលក្ខណៈសមស្របសម្រាប់ផលិតកម្មកសិកម្ម។

សម្បទានិកត្រូវដាក់ពាក្យស្នើសុំ ដោយភ្ជាប់ជាមួយនូវសំណើរគម្រោងបឋមសម្រាប់សម្បទានកសិកម្ម ដែលបញ្ជាក់នូវព័ត៌មានចាំបាច់ដូចខាងក្រោម៖

- ប្រវត្តិ និងសមត្ថភាពរបស់សម្បទានិក នៅក្នុងការអនុវត្តមុខរបរផលិតកម្មកសិកម្មនៅក្នុងប្រទេសឬក្រៅប្រទេស
- គោលបំណងច្បាស់លាស់ក្នុងការស្នើសុំសម្បទាន ដោយបង្ហាញនូវប្រភេទផលិតកម្មកសិកម្ម ប្រភេទដំណាំសក្តានុពល ទំហំផលិតកម្មប្រចាំឆ្នាំ ផ្ទៃដីកសិកម្មដែលត្រូវការ និងរយៈពេលវិនិយោគផលិតកម្មកសិកម្ម
- កិច្ចប្រតិបត្តិបច្ចេកទេស សមត្ថភាពធនធានហិរញ្ញវត្ថុ និងសេចក្តីត្រូវការធាតុចូលសម្រាប់ដំណើរការវិនិយោគផលិតកម្មកសិកម្ម នៅក្នុងរយៈពេលនៃកិច្ចព្រមព្រៀង។
- ព័ត៌មានចាំបាច់ផ្សេងទៀតតាមតម្រូវការរបស់រាជរដ្ឋាភិបាល។

**មតិយោបល់៖** សូមមើលសេចក្តីណែនាំស្តីពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យធ្វើការតាក់តែងមាត្រា៤៧ ឡើងវិញដូចខាងក្រោមនេះ៖

*"កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងនៃផលិតកម្មកសិកម្មដែលប្រើប្រាស់ដីរដ្ឋ ត្រូវបញ្ចូលបទប្បញ្ញត្តិសំដៅថែរក្សាលក្ខណ្ឌនៃប្រព័ន្ធអេកូឡូស៊ីបរិស្ថាន និងធានាផលិតភាពដីនៃទីតាំងស្នើសុំ ដែលឆ្លើយតបតាមប្រភេទដំណាំសក្តានុពល និងមានលក្ខណៈសមស្របសម្រាប់ផលិតកម្មកសិកម្ម។*

*សម្បទានិកត្រូវដាក់ពាក្យស្នើសុំ ដោយភ្ជាប់ជាមួយនូវសំណើរគម្រោងបឋមសម្រាប់សម្បទានកសិកម្ម ដែលបញ្ជាក់នូវព័ត៌មានចាំបាច់ដូចខាងក្រោមនេះ៖*

- *ប្រវត្តិ និងសមត្ថភាពរបស់សម្បទានិក នៅក្នុងការអនុវត្តមុខរបរផលិតកម្មកសិកម្មនៅក្នុងប្រទេសឬក្រៅប្រទេស*
- *គោលបំណងច្បាស់លាស់ក្នុងការស្នើសុំសម្បទាន ដោយបង្ហាញនូវប្រភេទផលិតកម្មកសិកម្ម ប្រភេទដំណាំសក្តានុពល ទំហំផលិតកម្មប្រចាំឆ្នាំ ផ្ទៃដីកសិកម្មដែលត្រូវការ និងរយៈពេលវិនិយោគផលិតកម្មកសិកម្ម*
- *កិច្ចប្រតិបត្តិបច្ចេកទេស សមត្ថភាពធនធានហិរញ្ញវត្ថុ និងសេចក្តីត្រូវការ ធាតុចូលសម្រាប់ដំណើរការវិនិយោគផលិតកម្មកសិកម្ម នៅក្នុងរយៈពេលនៃកិច្ចព្រមព្រៀង។*

- *របាយការណ៍លំអិតស្ដីពីដំណើរការពិគ្រោះយោបល់ជាមួយអ្នករងផលប៉ះពាល់និងសហគមន៍មូលដ្ឋាន និងអំពីដំណើរការដែលកិច្ចពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាក់លាក់ជាមួយក្រុមងាយរងគ្រោះបំផុត (ជាពិសេសស្ត្រី និងជនជាតិដើមភាគតិច)។*
- *ព័ត៌មានចាំបាច់ផ្សេងទៀត តាមការតម្រូវរបស់រាជរដ្ឋាភិបាល។"*

មាត្រា ៥០.-

កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងនៃផលិតកម្មកសិកម្ម ត្រូវបានកំណត់សុពលភាពក្នុងរយៈពេលមិនលើសពី៥០ (ហាសិប)ឆ្នាំ អាស្រ័យលើប្រភេទផលិតកម្មដំណាំកសិកម្ម និងទំហំវិនិយោគនៃគម្រោងសម្បទាន។

យោងតាមសំណើររបស់សម្បទានិក និងផ្អែកតាមរបាយការណ៍វាយតម្លៃរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម លើប្រសិទ្ធផលនៃការអនុវត្តរបស់សម្បទានិក រាជរដ្ឋាភិបាលអាចសម្រេចបន្តកិច្ចព្រមព្រៀងសម្បទានកសិកម្មបាន សម្រាប់រយៈពេលមិនលើសពីសុពលភាពនៃកិច្ចព្រមព្រៀងគ្រាដំបូង។

កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងនៃផលិតកម្មកសិកម្ម អាចបញ្ឈប់មុនកាលបរិច្ឆេទបញ្ចប់សុពលភាព នៅពេលក្រសួងទទួលបន្ទុកវិស័យកសិកម្មបានរកឃើញកំហុសរបស់សម្បទានិកដែលបានរំលោភធ្ងន់ធ្ងរលើបណ្ដាលក្ខណ្ឌនៃកិច្ចព្រមព្រៀង ឬប្រព្រឹត្តល្មើសនឹងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធជាធរមាន។

វិធានដោះស្រាយវិវាទ នៅក្នុងដំណើរការអនុវត្តកិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវអនុលោមតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀង បទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ពាក់ព័ន្ធជាធរមាន។

**មតិយោបល់៖** សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា៤៥។ ការមិនបានចែងយោងទៅបទដ្ឋានដែលមានស្រាប់ក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតស្ដីពី ដីសម្បទានសេដ្ឋកិច្ចដែលនៅជាធរមាន អាចជាហានិភ័យនៃការភ័ន្តច្រឡំក្នុងការអនុវត្តមាត្រា៥០។ ជាឧទាហរណ៍ មាត្រា៥០ មិននិយាយយោងបទប្បញ្ញត្តិដែលមានចែងក្នុង មាត្រា៥៩ នៃច្បាប់ភូមិបាល ដែលថា ទំហំនៃសម្បទានដីសេដ្ឋកិច្ចគឺមិនត្រូវលើសពី ១០០០០ ហិកតា ទេ ឬថាអនុក្រឹត្យស្ដីពីដីសម្បទានសេដ្ឋកិច្ចបានកម្រិតរយៈពេលនៃសម្បទានដីសេដ្ឋកិច្ចជាអតិបរិមាត្រឹម ៩៩ឆ្នាំ ខណៈដែលកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ អនុញ្ញាតឲ្យរយៈពេលអតិបរិមា ៥០ឆ្នាំ និងអាចពន្យាពេលបាន៥០ឆ្នាំបន្ថែមទៀត ឬសរុបទៅគឺ ១០០ឆ្នាំ។

**ការិយាល័យ** OHCHR **សូមផ្ដល់អនុសាសន៍**ឲ្យធ្វើការតាក់តែងមាត្រា៥០ ឡើងវិញដូចខាងក្រោមនេះ៖

*"កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងនៃផលិតកម្មកសិកម្ម ត្រូវបានកំណត់សុពលភាពក្នុងរយៈពេលមិនលើសពី៥០ (ហាសិប) ឆ្នាំ និងមិនលើសពីទំហំ ១០០០០ហិកតា។ រាជរដ្ឋាភិបាលអាចសម្រេច*

*បន្តកិច្ចព្រមព្រៀងសម្បទានលើទីតាំងដីដដែល ដែលមានរយៈពេលមិនលើសពីសុពលភាពនៃកិច្ចព្រមព្រៀងគ្រាដំបូងដោយក្នុងករណីណាក៏ដោយក៏មិនលើសពី៤៩ឆ្នាំ ឬសរុប៩៩ឆ្នាំ។*

*ការផ្តល់សម្បទាន និងការបន្តរយៈពេលសម្បទាន ត្រូវផ្អែកលើសំណើរផ្លូវការរបស់សម្បទានិក និងរបាយការណ៍ពិស្តារដែលចេញដោយក្រសួងទទួលបន្ទុកវិស័យកសិកម្ម អំពីការវាយតម្លៃជាសាធារណៈលើផលប៉ះពាល់ជាក់ស្តែងឬផលប៉ះពាល់ដែលនឹងកើតមានចំពោះសហគមន៍មូលដ្ឋាន ជីវភាពរស់នៅនិងវប្បធម៌របស់ពួកគេ បរិស្ថាន និងលើទិដ្ឋភាពដទៃទៀតនៃសម្បទានដែលរដ្ឋាភិបាលនិងសហគមន៍រងផលប៉ះពាល់ចាត់ទុកថាសំខាន់។ ក្នុងករណីនៃការបន្តកិច្ចព្រមព្រៀងសម្បទាន របាយការណ៍វាយតម្លៃត្រូវមានការវាយតម្លៃពីប្រសិទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងរបស់សម្បទានិក។ ការចូលរួមយ៉ាងពេញលេញនិងប្រកបដោយប្រសិទ្ធិភាពនៃសហគមន៍មូលដ្ឋានក្នុងការវាយតម្លៃត្រូវបានធានា។ ការវាយតម្លៃសមស្រប ប្រកបដោយការចូលរួម និងជាសាធារណៈ ត្រូវធ្វើឡើងផងដែរនៅចុងបញ្ចប់នៃរយៈពេលសម្បទាន។*

*កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងនៃផលិតកម្មកសិកម្ម អាចបញ្ឈប់មុនកាលបរិច្ឆេទបញ្ចប់សុពលភាព នៅពេលរកឃើញកំហុសរបស់សម្បទានិក ដែលបានរំលោភធ្ងន់ធ្ងរលើបណ្តាលក្ខណ្ឌនៃកិច្ចព្រមព្រៀង ឬប្រព្រឹត្តបទល្មើសមួយឬច្រើនក្រោមច្បាប់នេះនិងច្បាប់ពាក់ព័ន្ធជាធរមាន។*

*វិធានដោះស្រាយវិវាទ នៅក្នុងដំណើរការអនុវត្តកិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវអនុលោមតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀង បទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ពាក់ព័ន្ធជាធរមាន។ រាល់យន្តការ ឬដំណើរការដោះស្រាយវិវាទត្រូវមានលក្ខណៈសមធម៌ តម្លាភាព លទ្ធភាពទៅប្រើប្រាស់បាន និងស្របតាមបទដ្ឋានសិទ្ធិមនុស្ស ហើយដោយផ្អែកលើមូលដ្ឋាននៃការចូលរួមនិងការសន្ទនាជាមួយភាគីពាក់ព័ន្ធ។"*

### មាត្រា ៥១.-

សម្បទានិកមានកាតព្វកិច្ចរៀបចំផែនការគ្រប់គ្រងផលិតកម្មកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន នៅក្នុងរយៈពេលមិនលើសពី១៨ (ដប់ប្រាំបី) ខែ ក្រោយកាលបរិច្ឆេទចូលប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងសម្បទាន។

ផែនការគ្រប់គ្រងផលិតកម្មកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យកសិកម្មនិងត្រូវរៀបចំដូចខាងក្រោម៖

១- ផែនការមេគ្រប់គ្រងផលិតកម្មកសិកម្ម កម្រិតផ្ទៃដីសម្បទានទាំងមូល នៅក្នុងរយៈពេលនៃកិច្ចព្រមព្រៀងសម្បទាន

២- ផែនការគ្រប់គ្រងផលិតកម្មកម្រិតតំបន់ ដែលត្រូវបែងចែកលើផ្ទៃដីសម្រាប់គម្រោងសម្បទានទាំងមូល ទៅតាមដំណាក់កាលកំណត់ នៅក្នុងរយៈពេលនៃកិច្ចព្រមព្រៀងសម្បទាន។

៣- ផែនការប្រតិបត្តិផលិតកម្មកសិកម្មប្រចាំឆ្នាំ កម្រិតឡូត៍ប្រតិបត្តិការដែលបានបែងចែកនៅក្នុងកម្រិតតំបន់និមួយៗ សម្រាប់អនុវត្តប្រតិបត្តិការផលិតកម្មកសិកម្មប្រចាំឆ្នាំ។

៤- របាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សង្គមលើតំបន់សម្បទាន ត្រូវពិនិត្យ វាយតម្លៃ និងយល់ព្រមជាមុនដោយក្រសួងបរិស្ថាន។

**មតិយោបល់៖** ដើម្បីធានាថាមតិយោបល់ដែលបានផ្ដល់នៅអំឡុងពេលនៃកិច្ចពិគ្រោះយោបល់ត្រូវបានយកមកធ្វើការពិនិត្យពិចារណាដោយម៉ត់ចត់ ហើយថាកង្វល់ដែលបានលើកឡើងក្នុងអំឡុងនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការចុងក្រោយ រាល់ផែនការគ្រប់គ្រងកសិកម្មត្រូវដាក់ឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ*ជាមុន* មុននឹងចុះកិច្ចព្រមព្រៀងសម្បទាន។ ត្រូវទុកពេលវេលាគ្រប់គ្រាន់សម្រាប់កិច្ចពិគ្រោះយោបល់នេះ ហើយឯកសារពាក់ព័ន្ធផ្សេងៗត្រូវដាក់ឲ្យអាចរកបានជាសាធារណៈឲ្យបានមុនពេលនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈ។ ពាក់ព័ន្ធនឹងការវាយម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន សេចក្ដីព្រាងច្បាប់នេះត្រូវពិចារណាផងដែរអំពីកិច្ចពិភាក្សាកាលពីពេលថ្មីៗនេះលើសេចក្ដីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ ដែលមានបទប្បញ្ញត្តិជាក់លាក់ស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីបង្ការបទប្បញ្ញត្តិផ្ទុយគ្នា ឬច្រឡំគ្នា។

**ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍**ឲ្យធ្វើការតាក់តែងមាត្រា៥១ ឡើងវិញដូចខាងក្រោមនេះ (សំណើរសុំកែប្រែជា*អក្សរទ្រេត*)៖

"សម្បទានិកមានភាពព្វកិច្ចរៀបចំផែនការគ្រប់គ្រងផលិតកម្មកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាននៅក្នុងរយៈពេលតិចបំផុត *១២* (ដប់ពីរ) ខែ *មុន* កាលបរិច្ឆេទចូលប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទាន។

ផែនការគ្រប់គ្រងផលិតកម្មកសិកម្ម...... (មិនមានសំណើរសុំកែសម្រួលនៅក្នុងកថាខណ្ឌនេះទេ)។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមលើតំបន់សម្បទាន ត្រូវពិនិត្យ វាយតម្លៃ និងយល់ព្រមជាមុនដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវនៃ*ក្រមបរិស្ថាននិងធនធានធម្មជាតិរបស់កម្ពុជា។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវផ្សព្វផ្សាយជាសាធារណៈឲ្យបានយ៉ាងតិច ១២០ថ្ងៃ មុនការពិនិត្យពិចារណាចុងក្រោយលើគម្រោង ដោយមានទាំងផែនទី ផែនការ និងរាល់វិធានការកាត់បន្ថយគ្រោះថ្នាក់ដែលស្នើឡើងសម្រាប់គម្រោង។ បន្ថែមពីលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលព្រមព្រៀងធ្វើឡើងតាមកាលកំណត់ ត្រូវធ្វើការវាយតម្លៃនេះផងដែរ នៅមុនការធ្វើសេចក្ដីសម្រេចចិត្តអំពីសកម្មភាពថ្មីចម្បងណាមួយ ការកែប្រែផ្សេងៗក្នុងកិច្ចព្រមព្រៀងសម្បទាន ឬផែនការដែលពាក់ព័ន្ធ ឬកិច្ចព្រមព្រៀងថ្មី និងចំពោះការឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិយាកាសប្រតិបត្តិការ ដូចជាស្ថានភាពតានតឹងក្នុងសង្គមមានការកើនឡើងជាដើម។*"

**មាត្រា ៥២.-**

ផែនការគ្រប់គ្រងផលិតកម្មកសិកម្ម ទីតាំងនិងផ្ទៃដីសម្រាប់ប្រតិបត្តិការផលិតកម្មកសិកម្ម និងរបាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមនៅក្នុងតំបន់ក្រោមគម្រោងសម្បទាន ត្រូវមានការចូលរួមពិគ្រោះយោបល់ជាមុនពីសំណាក់សហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មតិយោបល់៖** ការិយាល័យOHCHR ស្វាគមន៍ការណែនាំនូវលក្ខខណ្ឌតម្រូវដើម្បីធានាឲ្យមានកិច្ចពិគ្រោះយោបល់ជាមុនដែលមានការចូលរួមពីសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ មានស្ថានភាពជាច្រើនដែលគំនិតស្តីពីកិច្ចពិគ្រោះយោបល់ប្រកបដោយការចូលរួមដែលសូម្បីតែមានការទទួលយកនិងមានចេតនាពិតប្រាកដក៏ដោយ ក៏អាចប្រែក្លាយទៅជាការអនុវត្តន៍បែបរូបភាពប្រជុំប៉ុណ្ណោះ ហើយដែលមិនបាននាំមកនូវលទ្ធផលនៃកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យឡើយ។ ការអនុវត្តច្បាប់ នឹងមានផលប៉ះពាល់មួយចំនួនដល់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលកាន់កាប់ដីតាមបែបប្រពៃណី។ ប្រការសំខាន់គឺច្បាប់ត្រូវបញ្ជាក់ឲ្យច្បាស់នូវសមាសធាតុសំខាន់ៗអំពីកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យដើម្បីធានាថាសិទ្ធិរបស់អ្នករងផលប៉ះពាល់ទាំងអស់ រួមទាំងសិទ្ធិជនជាតិដើមភាគតិចផង ដូចមានទទួលស្គាល់ក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ និងច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ត្រូវបានគាំពារ។ សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា៩។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**កែសម្រួលមាត្រា៥២ ដូចខាងក្រោមនេះ៖

*"ផែនការគ្រប់គ្រងផលិតកម្មកសិកម្ម ត្រូវជាកម្មវត្ថុនៃកិច្ចពិគ្រោះយោបល់ប្រកបដោយការចូលរួមពីសហគមន៍មូលដ្ឋាននិងភាគីពាក់ព័ន្ធ មុនមានការអនុម័តយល់ព្រម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលនឹងត្រូវអនុវត្តដោយក្រសួងទទួលបន្ទុកវិស័យកសិកម្ម។ កិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យគឺត្រូវមានការផ្សព្វផ្សាយព័ត៌មានអំពីផែនការ ទីតាំង និងផ្ទៃដីសម្រាប់ប្រតិបត្តិផលិតកម្មកសិកម្ម ផ្ទៃដីរក្សាទុកសម្រាប់ការប្រើប្រាស់និងជាជាប្រយោជន៍របស់សហគមន៍មូលដ្ឋាន ព័ត៌មានអំពីការបន្តកិច្ចព្រមព្រៀងសម្បទាន និងអត្ថបទរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងតំបន់ក្រោមគម្រោងសម្បទាន។ នៅពេលផ្នែកណាមួយនៃតំបន់សម្បទាន និងឬតំបន់ដីមានឥទ្ធិពលរបស់ខ្លួនមានផលប៉ះពាល់ខ្លាំងដល់ជីវភាពរស់នៅ ឬវប្បធម៌របស់ជនជាតិដើមភាគតិចនោះ ត្រូវមានការសម្របសម្រួលការចូលរួមរបស់ពួកគេក្នុងកិច្ចពិគ្រោះយោបល់ដែលស្របតាមគោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ(FPIC) តាមរយៈនីតិវិធីពិសេសដែលបានបង្កើតសម្រាប់គោលបំណងនេះ ហើយក៏ត្រូវមានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពីអ្នកដែលនឹងរងផលប៉ះពាល់ផងដែរ។"*

**មាត្រា៥៤.-**

ក្រសួងទទួលបន្ទុកវិស័យកសិកម្មមានសមត្ថកិច្ចគ្រប់គ្រង តាមដាន ត្រួតពិនិត្យនិងជម្រុញការអនុវត្តច្បាប់លើដំណើរការអនុវត្តកិច្ចព្រមព្រៀងសម្បទាន និងលើរាល់ប្រតិបត្តិការផលិតកម្មកសិកម្មរបស់សម្បទានិក ដោយផ្អែកតាមផែនការគ្រប់គ្រងផលិតកម្មកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាននេះ។

កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវត្រួតពិនិត្យឡើងវិញរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង លើការអនុវត្តកិច្ចព្រមព្រៀងដោយសម្បទានិក ការប្រើប្រាស់ដីកសិកម្មក្រោម

វិធានការនៃកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តភាព និងការអនុវត្តបទបញ្ញាអភិរក្សដីកសិកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

អង្គភាពទទួលបន្ទុកកិច្ចការធនធានដីកសិកម្ម មានសមត្ថកិច្ចផ្តល់សេវាកម្មបច្ចេកទេសសម្រាប់ការវាយតម្លៃស្ថានភាពប្រើប្រាស់ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទាន នៅមុនកាលបរិច្ឆេទចូលប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀង នៅពេលត្រួតពិនិត្យឡើងវិញរាងរាល់ ៥ (ប្រាំ)ឆ្នាំម្តង និងនៅកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀងសម្បទាន។

**មតិយោបល់៖** ការិយាល័យOHCHR ស្វាគមន៍ការកំណត់ការទទួលខុសត្រូវ តាមដាន និងដាក់ឲ្យអនុវត្តកិច្ចព្រមព្រៀងសម្បទាន និងត្រួតពិនិត្យឡើងវិញជាទៀងទាត់លើការប្រើប្រាស់ដីកសិកម្មស្ថិតក្រោមកិច្ចព្រមព្រៀងសម្បទាន។ ដើម្បីធានាថាកិច្ចព្រមព្រៀងសម្បទានត្រូវបានអនុវត្តដោយស្មោះត្រង់ ហើយប្រសិនជាមានកើតឡើងនូវស្ថានភាពថ្មីដែលតម្រូវឱ្យមានការផ្លាស់ប្តូរការអនុវត្តន៍ និងដើម្បីធានាថាបុគ្គលនិងសហគមន៍ដែលនឹងរងការប៉ះពាល់បានដឹងលឺអំពីការផ្លាស់ប្តូរនោះ ការត្រួតពិនិត្យឡើងវិញជាទៀងទាត់ត្រូវប្រព្រឹត្តិទៅដោយមានការចូលរួមពីពួកគេ ហើយលទ្ធផលត្រូវបញ្ចេញជាសាធារណៈ។ ក្នុងចំណោមហានិភ័យទូទៅនៃផលិតកម្មកសិកម្មចំពោះបរិស្ថាននិងសុខភាពមនុស្ស គឺការប៉ះពាល់លើសកម្រិតនឹងថ្នាំសម្លាប់សត្វល្អិត ឬសារធាតុបំពុល ហើយដោយសារហេតុផលនេះ ការិយាល័យ OHCHR ស្នើថាគួរតែមានការតាមដានជាញឹកញាប់ជាជាងធ្វើឡើង៥ឆ្នាំម្តង។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**កែសម្រួលឡើងវិញកថាខណ្ឌទី២ ដូចខាងក្រោម៖

*"កិច្ចព្រមព្រៀងសម្បទានក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវត្រួតពិនិត្យឡើងវិញរៀងរាល់៣ (បី)ឆ្នាំម្តង សម្រាប់គោលបំណងនៃការវាយតម្លៃការប្រើប្រាស់ដីកសិកម្ម ដោយអនុលោមតាមគោលការណ៍ណែនាំសម្រាប់ការប្រតិបត្តិការកសិកម្មប្រកបដោយនិរន្តរភាព បទបញ្ញាស្តីពីការអភិរក្សដីកសិកម្ម និងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។ ការត្រួតពិនិត្យឡើងវិញត្រូវមានការពិគ្រោះយោបល់ជាសាធារណៈ។ ក្នុងករណីមានការស្នើឡើងនូវការផ្លាស់ប្តូរនៅក្នុងកិច្ចព្រមព្រៀងសម្បទាន ឬលើការអនុវត្តផែនការរបស់សម្បទានិក ត្រូវមានការពិគ្រោះយោបល់ជាសាធារណៈដែលអនុលោមតាមគោលការណ៍នៃការយល់ព្រមជាមុន ដោយសេរីនិងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC)។"*

## ផ្នែកទី៥៖ ដីកសិកម្មក្រោមភតិសន្យាជួល

**មាត្រា ៥៧.-**

ដីរដ្ឋដែលស្ថិតក្រោមភតិសន្យាជួល ក្នុងគោលបំណងផលិតកម្មកសិកម្ម ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម និងត្រូវចុះបញ្ជី ប្រើប្រាស់ដីកសិកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ភតិសន្យាជួលដីរដ្ឋក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវជានាលក្ខណ្ឌនៃប្រព័ន្ធអេក្រូបរិស្ថាន និងផលិតភាពដីនៃទីតាំងដែលស្នើសុំជួលនោះ ដែលឆ្លើយតបតាមប្រភេទដំណាំសក្តានុពល និងមានលក្ខណៈសមស្របសម្រាប់ផលិតកម្មកសិកម្ម។

ភតិសន្យាជួលដីរដ្ឋក្រោមគោលបំណងផលិតកម្មកសិកម្ម ត្រូវមានពេលមិនលើសពី ១៥ (ដប់ប្រាំ) ឆ្នាំឡើយ និងត្រូវត្រួតពិនិត្យឡើងវិញរៀងរាល់៥ (ប្រាំ)ឆ្នាំ ម្តងលើការអនុវត្តរបស់ភាគីអ្នកជួលនូវលក្ខណ្ឌនៃកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាពនិងការអនុវត្តបទបញ្ជាអភិរក្សដីកសិកម្មដោយអនុលោមតាមបទបញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

**មតិយោបល់៖** ចំពោះកថាខណ្ឌទី៣នេះ ដោយពិចារណាទៅលើមាត្រា៥៩ នៃច្បាប់ភូមិបាលដែលបានកំណត់ទំហំដីសម្បទានសេដ្ឋកិច្ចត្រឹម ១០០០០ ហិកតា ការចែងបញ្ជាក់ឡើងវិញអំពីការកំណត់ទំហំដដែលនេះក្នុងបទប្បញ្ញត្តិនេះ អាចជួយធានាឲ្យមានភាពស៊ីចង្វាក់គ្នា ដើម្បីជៀសវាងភាពខុសគ្នាដែលអាចកើតមានរវាងដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋដែលស្ថិតក្រោមភតិសន្យាជួលក្នុងគោលបំណងផលិតកម្មកសិកម្ម។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យដាក់បន្ថែមឃ្លាថ្មីនៅចុងកថាខណ្ឌទី៣ ដូចខាងក្រោមនេះ៖

*"ភតិសន្យាជួលដីរដ្ឋសម្រាប់គោលបំណងផលិតកម្មកសិកម្មមិនត្រូវលើសពីទំហំ១០០០០ ហិកតា។"*

**មាត្រា ៥៩.-**

ក្រោមគោលបំណងនៃច្បាប់នេះ ជាទូទៅ ភតិសន្យាជួលដីកសិកម្មត្រូវកំណត់លក្ខខណ្ឌអប្បរមា ដូចខាងក្រោម៖

១- អត្តសញ្ញាណរបស់ភាគីអ្នកជួល និងភាគីម្ចាស់ដី

២- គោលបំណងនៃការជួលដីកសិកម្ម ដើម្បីអនុវត្តគម្រោងផលិតកម្មកសិកម្ម

៣- ទីតាំងនិងអត្តសញ្ញាណរបស់ដីកសិកម្មដែលត្រូវជួល ដោយមានព័ត៌មានភូមិសាស្ត្រនិងមានព្រំប្រទល់ច្បាស់លាស់

៤- ការពិពណ៌នាច្បាស់លាស់អំពី ការវាយតម្លៃស្ថានភាពដើមនៃប្រព័ន្ធអេក្រូបរិស្ថានលើទីតាំងដីកសិកម្មដែលត្រូវជួល លក្ខខណ្ឌធរណីសាស្ត្រ សក្តានុពលនៃផលិតភាពដី និងគុណភាពដី។

៥- រយៈពេលនៃការជួល និងកាលបរិច្ឆេទប្រសិទ្ធិភាពនៃភតិសន្យា

៦- ប្រាក់តំកល់ធានាភតិសន្យាជួល សម្រាប់ជួសជុលការខូចខាតគុណភាពដីកសិកម្ម ថ្លៃឈ្នួល និងបែបបទនៃការបង់ថ្លៃឈ្នួល។

៧- ការទទួលខុសត្រូវរៀងខ្លួនរបស់ភាគីអ្នកជួលនិងភាគីម្ចាស់ដីដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ពាក់ព័ន្ធជាធរមាន។

៨- លក្ខណ្ឌនៃការបញ្ឈប់ភតិសន្យា នៅក្នុងរយៈពេលសុពលភាពនៃការអនុវត្ត។

៩- វិធានដោះស្រាយវិវាទ។

១០-លក្ខណ្ឌផ្សេងទៀតស្របតាមទម្រង់នៃភតិសន្យាដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មតិយោបល់៖** ការិយាល័យOHCHR សូមស្វាគមន៍ការបញ្ចូលលក្ខខណ្ឌតម្រូវក្នុងវិធានដោះស្រាយវិវាទ (កថាខណ្ឌទី៩) ក្នុងភតិសន្យាជួលដីកសិកម្ម។ ក្នុងករណីដែលមានការរំលោភសិទ្ធិមនុស្ស ជនទាំងឡាយត្រូវមានលទ្ធភាពទៅប្រើប្រាស់យន្តការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ដូចជាយន្តការដោះស្រាយវិវាទឬបណ្ដឹង ដើម្បីបង្ការការរំលោភសិទ្ធិមនុស្សតទៅទៀត។ សិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធភាពមានចែងក្នុងមាត្រា៨ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងមាត្រា២ (៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ។ បើតាមមាត្រានៃកតិកាសញ្ញានេះ រដ្ឋភាគីសន្យា "ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន...ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ... (និង) ធានាថាអាជ្ញាធរមានសមត្ថកិច្ច ត្រូវពង្រឹងអនុវត្តការដោះស្រាយនៅពេលដែលបានផ្ដល់ការសម្រេចហើយនោះ"។ នេះជាការឆ្លើយតបទៅនឹងគោលការណ៍លេខ២៩ នៃគោលការណ៍ណែនាំស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ដែលចែងថា៖

> "គោលការណ៍ ២៩៖ ដើម្បីបង្កភាពងាយស្រួលដល់ការដោះស្រាយឲ្យបានឆាប់រហ័សនិងដោយផ្ទាល់ សហគ្រាសពាណិជ្ជកម្មនានាគួរតែបង្កើតឬចូលរួមនៅក្នុងយន្តការដោះស្រាយកម្រិតប្រតិបត្តិការដ៏មានប្រសិទ្ធភាព សម្រាប់បុគ្គល និងសហគមន៍នានាដែលអាចទទួលរងផលប៉ះពាល់អវិជ្ជមាន។"

យោងតាមការអត្ថាធិប្បាយរបស់ការិយាល័យOHCHR លើគោលការណ៍ណែនាំនេះ យន្តការដោះស្រាយបណ្ដឹងកម្រិតប្រតិបត្តិការបំពេញមុខងារសំខាន់ពីរ ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់សហគ្រាសពាណិជ្ជកម្មក្នុងការគោរពសិទ្ធិមនុស្ស។ ដំបូងពួកគេគាំទ្រការកំណត់ពីផលប៉ះពាល់សិទ្ធិមនុស្សអវិជ្ជមានដែលវាជាផ្នែកមួយនៃដំណើរការជាបន្តរបស់សហគ្រាសពាណិជ្ជកម្មលើការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស ដោយផ្ដល់ឲ្យមាននូវច្រកសម្រាប់អ្នករងផលប៉ះពាល់ដោយផ្ទាល់ពីប្រតិបត្តិការរបស់សហគ្រាសពាណិជ្ជកម្ម បង្ហាញពីកង្វល់ដែលពួកគេជឿថាត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ដោយវិភាគលើនិន្នាការ និងលំនាំផ្សេងៗមាននៅក្នុងពាក្យបណ្ដឹង សហគ្រាសពាណិជ្ជកម្មអាចកំណត់បាននូវបញ្ហាជាប្រព័ន្ធ និងអាចសម្រួបការអនុវត្តរបស់ខ្លួនតាមស្ថានភាពនោះ។ ទី២ យន្តការទាំងនេះអាចផ្ដល់លទ្ធភាពសម្រាប់ការឆ្លើយតបចំពោះបណ្ដឹងនៅពេលដែលកំណត់ពីបញ្ហាបានហើយ និងសម្រាប់ដោះស្រាយផលប៉ះពាល់អវិជ្ជមានតាំងពីដំបូង និងដោយផ្ទាល់ពីសហគ្រាសពាណិជ្ជកម្ម ដូច្នេះវាអាចទប់ស្កាត់ហានិភ័យនៃការកើនឡើងនិងការរីករាលដាលនៃបណ្ដឹង។ យន្តការទាំងនេះមិនចាំបាច់ទាមទាការលើកយកមកដោះស្រាយនូវបណ្ដឹងឬការមិនសុខចិត្តដែលរហូតទាល់តែទាក់ទងនឹងការចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្សនោះទេ ប៉ុន្តែគួរតែជាយន្តការដែលមានគោលបំណងជាក់លាក់ដើម្បីកំណត់ពីការព្រួយបារម្ភស្របច្បាប់នានារបស់ជនទាំងឡាយដែលរងផលប៉ះពាល់ជាអវិជ្ជមាន។

ប្រសិនបើកង្វល់ទាំងនោះមិនត្រូវបានកំណត់និងដោះស្រាយទេនោះ វាអាចនឹងរីករាលដាលទៅជាវិវាទកាន់តែធំ និងការរំលោភសិទ្ធិមនុស្សកាន់តែច្រើន។[3]

ជាការសំខាន់ដើម្បីកត់សំគាល់ថា ជនជាតិដើមភាគតិចជារឿយៗមានយន្តការដោះស្រាយវិវាទអនុវត្ត សម្រាប់ផ្ទៃក្នុងរបស់ពួកគេ ប្រព័ន្ធយុត្តិធម៌ និងយន្តការបណ្តឹង ដែលប្រតិបត្តិតាមរយៈស្ថាប័នតំណាងនិងផ្អែក លើច្បាប់ទំនៀមទម្លាប់របស់ពួកគេ។ ជាងនេះទៅទៀត ជនជាតិដើមភាគតិចអាចជ្រើសរើសក្នុងការចូលរួម ក្នុងយន្តការដោះស្រាយវិវាទដែលជាជម្រើសដទៃទៀត ដែលផ្អែកតាមស្ថាប័ននិងច្បាប់ទំនៀមទម្លាប់និងការ ប្រតិបត្តិរបស់ពួកគេ។ យន្តការដែលមានស្រាប់របស់ពួកគេគឺស្របតាមលក្ខណ្ឌដែលបានចែងក្នុងគោលការណ៍ ទី៣១ នៃភាពស្របច្បាប់ ភាពអាចទៅប្រើប្រាស់បាន អាចព្យាករណ៍បាន សមធម៌ គាំទ្រសិទ្ធិ និងតម្លាភាព។ វាក៏ជួយកាត់បន្ថយលទ្ធភាពនៃការរំលោភបំពានលើសិទ្ធិស្វ័យគ្រប់គ្រងរបស់ពួកគេ ដែលវាអាចកើតមានឡើង ក្នុងបរិបទដែលយន្តការនិងរចនាសម្ព័ន្ធនានាមិនស្របនឹងការប្រតិបត្តិនិងច្បាប់ទំនៀមទម្លាប់របស់ជនជាតិដើម ភាគតិច ត្រូវបានកំណត់ពីអ្នកខាងក្រៅ។

ដើម្បីឲ្យយន្តការទាំងនេះបំពេញតួនាទីជាគោលដៅរបស់វា ច្បាប់ត្រូវចែងលំអិតពីលក្ខណៈវិនិច្ឆ័យ សំខាន់ៗនិងនីតិវិធីសម្រាប់ការដោះស្រាយវិវាទ។ លក្ខណៈវិនិច្ឆ័យទាំងនេះមានកំណត់នៅក្នុងគោលការណ៍ ៣១ ដូចខាងក្រោម៖

> "**គោលការណ៍ ៣១៖** ដើម្បីធានាដល់ប្រសិទ្ធភាពនៃយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការទាំង របស់រដ្ឋ និងមិនមែនរបស់រដ្ឋ យន្តការទាំងនោះគួរតែ៖
>
> (ក) ស្របច្បាប់៖ ទទួលបានទំនុកចិត្តពីក្រុមអ្នកពាក់ព័ន្ធនានា ដែលជាកម្មវត្ថុនៃយន្តការទាំងនោះ ព្រមទាំងមានគណនេយ្យភាពចំពោះការប្រព្រឹត្ត ដោយយុត្តិធម៌លើដំណើរការដោះស្រាយនានា
>
> (ខ) អាចប្រើប្រាស់បាន៖ ត្រូវបានយល់ដឹងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងអស់ ដែលជាកម្មវត្ថុនៃ យន្តការទាំងនោះ ព្រមទាំងផ្តល់ជំនួយឧបត្ថម្ភគ្រប់គ្រាន់ដល់អ្នកដែលអាចប្រឈមមុខនឹងរបាំង ដោយឡែកណាមួយ ដែលរារាំងមិនឲ្យពួកគេប្រើប្រាស់យន្តការទាំងនោះបាន
>
> (គ) អាចព្យាករណ៍បាន៖ ផ្តល់នីតិវិធីច្បាស់លាស់ និងងាយស្រួលយល់ អមជាមួយនឹងតារាងពេល វេលាសម្រាប់ដំណាក់កាលដោះស្រាយនិមួយៗ ហើយពន្យល់យ៉ាងច្បាស់លាស់អំពី ប្រភេទនៃ ដំណើរការ និងលទ្ធផលដែលមាន ព្រមទាំងវិធីសាស្ត្រតាមឃ្លាំមើលការអនុវត្តន៍
>
> (ឃ) សមធម៌៖ ស្វះស្វែងធានាថា ភាគីរងគ្រោះនានាទទួលបានព័ត៌មាន ការប្រឹក្សា និងជំនាញការ សមស្របដែលចាំបាច់សម្រាប់ចូលរួមក្នុងដំណើរការដោះស្រាយដែលមានលក្ខណៈយុត្តិធម៌ មានព័ត៌មានគ្រប់គ្រាន់ និងដោយការគោរព

[3] "គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស៖ ការអនុវត្តក្រមខ័ណ្ឌ "ការគោរព ការការពារ និងដំណោះស្រាយ" របស់អង្គការសហ ប្រជាជាតិ HR/PUB/11/04 ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១១ សេចក្តីអត្ថាធិប្បាយលើគោលការណ៍ ២៩ ទំព័រ ៣១-៣២។

(ង) តម្លាភាព៖ ភាគីនានានៃយន្តការនេះត្រូវទទួលបានការជូនដំណឹង ជាប់ជានិច្ចអំពីការវិវត្តទៅមុខនៃនីតិវិធី ព្រមទាំងផ្តល់ព័ត៌មានគ្រប់គ្រាន់អំពី ការប្រព្រឹត្តទៅនៃយន្តការនេះ ដើម្បីកសាងទំនុកចិត្តលើប្រសិទ្ធិភាពនៃយន្តការ និងការពារផលប្រយោជន៍សាធារណៈណាមួយដែលប្រឈមមុខនឹងហានិភ័យ

(ច) សិទ្ធិជានិរន្តរ៍៖ ធានាថា លទ្ធផលនិងការដោះស្រាយអនុលោមតាមសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ

(ឆ) ប្រភពនៃការសិក្សាជាបន្ត៖ ស្រង់ចេញពីវិធានការពាក់ព័ន្ធនានា កំណត់យកមេរៀន ដើម្បីធ្វើឲ្យប្រសើរឡើងដល់យន្តការនេះ ព្រមទាំង បង្ការវិវាទនិងព្យសនកម្មនាពេលអនាគត

យន្តការកំរិតប្រតិបត្តិការក៏គួរតែមានលក្ខណៈដូចខាងក្រោមផងដែរ៖

(ជ) ផ្អែកលើការចូលរួម និងការសន្ទនា៖ ពិគ្រោះយោបល់ជាមួយក្រុម អ្នកពាក់ព័ន្ធនានា ដែលជាកម្មវត្ថុនៃយន្តការទាំងនេះ អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការទាំងនេះ ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើការសន្ទនា ធ្វើជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ។"

លក្ខណៈវិនិច្ឆ័យចំនួន ៧ ដំបូង អនុវត្តចំពោះយន្តការរដ្ឋឬយន្តការមិនមែនរដ្ឋ យន្តការជំនុំជម្រះក្តីឬការសន្ទនា។ លក្ខណៈវិនិច្ឆ័យទី ៨ និយាយចំពោះតែយន្តការកម្រិតប្រតិបត្តិដែលសហគ្រាសពាណិជ្ជកម្មជួយគ្រប់គ្រង។

យោងតាមសេចក្តីអធិប្បាយរបស់ការិយាល័យOHCHR ទៅលើគោលការណ៍ទី៣១ "យន្តការបណ្តឹងអាចបម្រើគោលបំណងរបស់វាបាន ប្រសិនបើជនដែលជាគោលដៅនៃយន្តការនេះយល់ដឹងអំពីវា ជឿជាក់លើវា និងមានលទ្ធភាពប្រើប្រាស់វាបាន។ លក្ខណៈវិនិច្ឆ័យទាំងនេះអាចផ្តល់ជាមគ្គុទេសក៍សម្រាប់រៀបចំ កែសម្រួលឡើងវិញ ឬវាយតម្លៃលើយន្តការដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដើម្បីជួយធានាថាវាមានប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្តែង។ យន្តការដែលរៀបចំឡើងឬអនុវត្តដោយខ្ជីខ្ជារ អាចប្រថុយនឹងការផ្តុំឡើងនៃអារម្មណ៍ខឹងសម្បារក្នុងចំណោមភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ ដែលបណ្តាលឲ្យពួកគេមានការយល់ឃើញកាន់តែខ្លាំងថាខ្លួនគ្មានសិទ្ធអំណាច និងធ្វើឲ្យពួកគេមិនគោរពចំពោះដំណើរការនេះ។"[4]

"ខណៈដែលសហគ្រាសពាណិជ្ជកម្មជាមួយនឹងភាពស្របច្បាប់ខ្លួន មិនអាចជាអ្នករងនូវបណ្តឹងផងនិងជាអ្នកកំណត់ពីលទ្ធផលដោះស្រាយជាឯកតោភាគីរបស់ខ្លួននោះ យន្តការទាំងនេះគួរផ្តោតលើការឈានទៅដំណោះស្រាយដែលមានការយល់ព្រមតាមរយៈកិច្ចសន្ទនា។ ប្រសិនជាការវិនិច្ឆ័យក្តីគឺជាការចាំបាច់ គួរតែផ្តល់ឲ្យមានយន្តការឯករាជ្យដែលមានភាគីទីបីចូលរួមដែលស្រមច្បាប់។"[5]

ការបញ្ចូលបទប្បញ្ញត្តិក្នុងកតិសន្យាជួលដែលមានន័យថា យន្តការដោះស្រាយវិវាទដែលបានរំពឹងទុកជាមុន ត្រូវគ្រប់គ្រងដោយសហគ្រាសពាណិជ្ជកម្មពាក់ព័ន្ធ។ ការងារនេះអាចត្រូវបានធ្វើឡើងដោយសហគ្រាសតែម្នាក់ឯងឬដោយមានការសហការជាមួយភាគីពាក់ព័ន្ធដទៃទៀត។ វិវាទក៏អាចត្រូវបានដោះស្រាយផងដែរ

[4] គោលការណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស, សេចក្តីអត្ថាធិប្បាយលើគោលការណ៍ ៣១ ទំព័រ ៣៤។

[5] គោលការណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស, គោលការណ៍ ៣១ និងសេចក្តីអត្ថាធិប្បាយពាក់ព័ន្ធ ទំព័រ ៣៣-៣៥។

តាមរយៈការព្រមព្រៀងគ្នាជ្រើសរើសយកស្ថានប័ន ឬអ្នកជំនាញពីខាងក្រៅ។ យន្តការមិនគួរតម្រូវឲ្យអ្នកដាក់ពាក្យបណ្ដឹង ទៅជ្រើសរើសយកវិធីដោះស្រាយផ្សេងជាមុនសិននោះឡើយ។ [6] ទន្ទឹមនឹងយន្តការដោះស្រាយកម្រិតប្រតិបត្តិអាចមានសារៈសំខាន់បំពេញបន្ថែមលើដំណើរការដែលមានការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធផ្សេងៗ និងយន្តការវិភាគរួម យន្តការនេះក៏មិនអាចជំនួសបានដែរ។ យន្តការនេះមិនអាចប្រើប្រាស់ដើម្បីធ្វើឲ្យចុះខ្សោយដល់តួនាទីសហជីពកម្មករដែលស្របច្បាប់ក្នុងការដោះស្រាយវិវាទការងារ ឬក៏ទប់ស្កាត់ការទៅប្រើប្រាស់យន្តការតាមប្រព័ន្ធតុលាការ ឬយន្តការក្រៅប្រព័ន្ធតុលាការដទៃទៀតឡើយ។[7]

ការទទួលខុសត្រូវក្នុងការផ្ដល់ដំណោះស្រាយ ក៏ជាគោលការណ៍ទូទៅមួយផងដែរនៃអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ នៅក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ ដែលចែងថា៖

> "តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសអាជីវកម្ម មានកាតព្វកិច្ចត្រូវគោរពសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសពាណិជ្ជកម្ម គប្បីធ្វើសកម្មភាពប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីជៀសវាងការរំលោភសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់របស់អ្នកដទៃ។ ពួកគេគប្បីមានប្រព័ន្ធគ្រប់គ្រងហានិភ័យសមស្របដើម្បីទប់ស្កាត់ និង ដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសអាជីវកម្ម គប្បីរៀបចំ និងសហការនៅក្នុងយន្តការមិនមែនតុលាការ ដើម្បីផ្ដល់ដំណោះស្រាយកែតម្រូវ រួមទាំងយន្តការបណ្ដឹងសាទុក្ខប្រកបដោយប្រសិទ្ធភាពនៅកម្រិតប្រតិបត្តិការ ក្នុងករណីសមស្រប និងក្នុងករណី ដែលពួកគេបានបណ្ដាលឲ្យមាន ឬបានរួមចំណែកបណ្ដាលឲ្យមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសអាជីវកម្ម គប្បីកំណត់ និងវាយតម្លៃផលប៉ះពាល់ដែលអាចមាន ឬផលប៉ះពាល់ជាក់ស្ដែងទៅលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់ ដែលពួកគេអាចមានការពាក់ព័ន្ធ។ អនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន រដ្ឋគប្បីផ្ដល់ឧបាស្រ័យតាមផ្លូវតុលាការប្រកបដោយប្រសិទ្ធភាពសម្រាប់ផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់ ដែលបង្កឡើងដោយសហគ្រាសអាជីវកម្ម។ ក្នុងករណីដែលពាក់ព័ន្ធសាជីវកម្មឆ្លងប្រទេស រដ្ឋប្រភពដើមនៃសាជីវកម្មទាំងនោះមានតួនាទីជួយដល់សាជីវកម្មទាំងនោះផង និងរដ្ឋម្ចាស់ផ្ទះផង ដើម្បីធានាឲ្យបានថាអាជីវកម្មទាំងឡាយមិនមានជាប់ពាក់ព័ន្ធក្នុងការបំពានសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់។ រដ្ឋគប្បីចាត់វិធានការបន្ថែម ដើម្បីការពារប្រឆាំងនឹងការបំពានសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់ ដោយសហគ្រាសអាជីវកម្ម ដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬត្រួតត្រាដោយរដ្ឋ ឬដែលទទួលបានការគាំទ្រ និងសេវាពីស្ថាប័នរដ្ឋ។"

នៅទីបំផុត មាត្រា៤០ នៃសេចក្ដីប្រកាសអង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិជនជាតិដើមភាគតិច ផ្ដល់ឲ្យជនជាតិដើមភាគតិចនូវសិទ្ធិទទួលបាននូវសេចក្ដីសម្រេចឆាប់រហ័ស តាមរយៈនីតិវិធីត្រឹមត្រូវនិងយុត្តិធម៌

[6] គោលការណ៍ណែនាំស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស, គោលការណ៍ ២៩ និងសេចក្ដីអត្ថាធិប្បាយពាក់ព័ន្ធ ទំព័រ ៣១។
[7] គោលការណ៍ណែនាំស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស, គោលការណ៍ ២៩ និងសេចក្ដីអត្ថាធិប្បាយពាក់ព័ន្ធ ទំព័រ ៣២។

ចំពោះការដោះស្រាយលើជំលោះ និងវិវាទជាមួយរដ្ឋ ឬភាគីផ្សេងទៀត ដែលរាប់ទាំងសហគ្រាសអាជីវកម្ម ក្នុងករណីដែលមានការបំពានលើសិទ្ធិរបស់ពួកគេ។ នីតិវិធីនេះត្រូវពិចារណាយ៉ាងត្រឹមត្រូវអំពីប្រពៃណី ទំនៀមទំលាប់ វិធាន និងប្រព័ន្ធច្បាប់របស់ជនជាតិដើមភាគតិចពាក់ព័ន្ធ។

**ការិយាល័យ OHCHR ស្នូមផ្តល់អនុសាសន៍**ថាចំណុចទី៩ ក្នុងមាត្រា ៥៩ គួរតែពង្រឹងបន្ថែមដើម្បីឲ្យឆ្លើយតបទៅនឹងចំណុចពិចារណាដែលបានរៀបរាប់ខាងលើ ដូចតទៅ៖

*"៩. វិធានដោះស្រាយវិវាទ មានរួមទាំងវិធានដែលចែងថា ៖*

- *កិច្ចពិគ្រោះយោបល់ជាមួយភាគីរងផលប៉ះពាល់ទាក់ទងនឹងការបង្កើតនីតិវិធីច្បាស់លាស់ដែលកំណត់រយៈពេលសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការនិងបែបបទពាក់ព័ន្ធដទៃទៀត។ នីតិវិធីនេះត្រូវពិចារណាទៅលើទំនៀមទម្លាប់ ប្រពៃណី ការគ្រប់គ្រង និងប្រព័ន្ធច្បាប់នៃសហគមន៍រងផលប៉ះពាល់ និងជនជាតិដើមភាគតិចដែលពាក់ព័ន្ធ។*
- *ផ្សព្វផ្សាយជាសាធារណៈអំពីលទ្ធផលឲ្យបានទាន់ពេលវេលា។*
- *ផ្សព្វផ្សាយដល់គ្រប់ភាគីជំលោះនូវរាល់ព័ត៌មានដែលភាគីផ្សេងទៀតបានផ្តល់ឲ្យ។*
- *កង្វល់សិទ្ធិមនុស្សស្ថិតក្នុងចំនោមមូលដ្ឋានផ្សេងទៀតនៃការទទួលយកបាននៃបណ្តឹង។*
- *ពិនិត្យឡើងវិញប្រកបដោយការចូលរួមជាទៀងទាត់លើប្រសិទ្ធភាពនៃនីតិវិធីដោះស្រាយវិវាទ និងលទ្ធផលនៃការដោះស្រាយលើករណី ក្នុងគោលបំណងណែនាំអំពីវិធានការកែតម្រូវជាប្រព័ន្ធតាមការចាំបាច់។*
- *ការផ្តល់នូវសេវាបកប្រែសម្រាប់អ្នកអះអាងថាជាជនរងគ្រោះប្រសិនបើចាំបាច់ ជាពិសេសសម្រាប់សមាជិកសហគមន៍ជនជាតិដើមភាគតិច និង*
- *អនុវត្តវិធានទាំងអស់ដោយមិនធ្វើឲ្យខូចប្រយោជន៍ដល់យន្តការដោះស្រាយវិវាទដទៃទៀត ដូចជាតុលាការ ក្រុមប្រឹក្សាអជ្ញាកណ្តាល ឬយន្តការសម្រុះសម្រួលដទៃរៀបចំដោយស្ថាប័នរដ្ឋ។*

**មាត្រា ៦០.-**

ក្នុងការអនុវត្តភតិសន្យាជួលដីកសិកម្ម ភាគីអ្នកជួលត្រូវទទួលខុសត្រូវសំខាន់លើការប្រើប្រាស់ដីកសិកម្មដូចខាងក្រោម ៖

១- ត្រូវប្រើប្រាស់ដីក្នុងគោលបំណងកសិកម្ម និងអនុវត្តផលិតកម្មដំណាំកសិកម្ម ដែលបានកំណត់ច្បាស់លាស់ក្នុងគោលបំណង នៃភតិសន្យាជួលដីកសិកម្ម។

២-ត្រូវប្រើប្រាស់ដីជួលដោយផ្អែកតាមវិធានស្តីពីកិច្ចប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព និងជៀសវាងការប្រើប្រាស់ដីមិនសមស្រប ដែលនាំមកនូវភាពសឹករិច ការហូរច្រោះ ការបាត់បង់គុណភាពឬជីជាតិដី ការបំពុលដីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ី។

៣-ត្រូវបង្កលក្ខណៈឬអនុញ្ញាតអោយភាគីម្ចាស់ដី ដើម្បីចូលពិនិត្យតាមពេលវេលាសមស្របលើស្ថានភាពនិងលក្ខណ្ឌនៃការប្រើប្រាស់ដីកសិកម្មដែលបានជួលក្រោមភតិសន្យា។

៤- ពុំមានសិទ្ធិជួលបន្តឲ្យភាគីទីបីណាមួយ នូវផ្ទៃដីទាំងមូល ឬផ្នែកណាមួយនៃដីកសិកម្មដែលបានជួលក្រោមភតិសន្យាឡើយ លើកលែងតែមានការយល់ព្រមជាមុនពីភាគីម្ចាស់ដី។

៥- មិនត្រូវបោះបង់ចោលឬទុកឲ្យនៅទំនេរដោយមិនអនុវត្តផលិតកម្មកសិកម្មលើដីជួលឡើយ លើកលែងតែមានចែងក្នុងលក្ខណ្ឌនៃការបញ្ឈប់ភតិសន្យា។

៦- នៅកាលបរិច្ឆេទបញ្ចប់ភតិសន្យា ត្រូវប្រគល់ដីកសិកម្មដែលបានជួលឲ្យទៅភាគីម្ចាស់ដីវិញក្នុងលក្ខណ្ឌស្របតាមស្ថានភាពដើមដែលបានវាយតម្លៃ។

៧-ត្រូវជួសជុលការខូចខាតឬចេញសំណងក្នុងការស្តារឡើងវិញលើដីកសិកម្មដែលបានជួលក្នុងករណីភាគីអ្នកជួលរំលោភលើលក្ខណ្ឌប្រើប្រាស់ដីដែលនាំមកនូវការខូចខាតគុណភាពដីខុសពីលក្ខណ្ឌនៃស្ថានភាពដើម។

**មតិយោបល់៖** កថាខណ្ឌទី៦ នៃមាត្រា៦០ ចែងថា នៅកាលបរិច្ឆេទបញ្ចប់ភតិសន្យា ត្រូវប្រគល់ដីកសិកម្មដែលបានជួលឲ្យទៅភាគីម្ចាស់ដីវិញក្នុងលក្ខណ្ឌស្របតាមស្ថានភាពដើមដែលបានវាយតម្លៃ។ តាមការជាក់ស្តែងវាពិតជាពិបាកក្នុងការសងដីទៅឲ្យម្ចាស់ដីវិញក្នុង "ស្ថានភាពដើម" ក្រោយជួលដីរាប់ឆ្នាំ ឬរាប់ទស្សវត្សរ៍ហើយនោះ។ ប្រសិនបើ "ស្ថានភាពដើម" នៃដីត្រូវបានចាត់ទុកថាជាការសំដៅលើ "គុណភាពដីដូចដើម" បទប្បញ្ញត្តិនេះអាចបញ្ជាក់ថា អ្នកជួលត្រូវរក្សាដីជួលឲ្យនៅទំនេរយ៉ាងហោចណាស់ក៏ពី ៣ឆ្នាំទៅ៥ ឆ្នាំដែរមុនកិច្ចព្រមព្រៀងជួលបញ្ចប់ ដើម្បីឲ្យគុណភាពដីនោះវិលត្រឡប់មកដូចដើមវិញ ដែលក្នុងករណីខ្លះអាចការពារការប្រែប្រួលដោយបរិស្ថានជុំវិញ។ ប្រសិនបើនេះជាគោលដៅ វាគួរត្រូវបានបញ្ជាក់ច្បាស់លាស់ ដើម្បីបង្ហាញពីតម្លាភាព។

**ការិយាល័យ** OHCHR **សូមផ្តល់អនុសាសន៍**លុបកថាខណ្ឌទី៦ ត្រង់ប្រយោគ "លក្ខណ្ឌស្របតាមស្ថានភាពដើមដែលបានវាយតម្លៃ" ឬក៏ការកែសម្រួលពាក្យពេចន៍បង្កើតនិយមន័យច្បាស់លាស់នៃ "ស្ថានភាពដើម" នៃដីដែលត្រូវធ្វើឲ្យដូចដើម។

មាត្រា ៦៤.-

ត្រូវហាមឃាត់ដាច់ខាតការជួលដីកសិកម្ម ទោះជាដីរដ្ឋឬឯកជន ដែលស្ថិតនៅតាមខ្សែក្រវាត់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ទៅអោយរូបវន្តបុគ្គលឬនីតិបុគ្គលបរទេសនៃប្រទេសដែលមានបន្ទាត់ព្រំដែនជាប់ជាមួយព្រះរាជាណាចក្រកម្ពុជា។

**មតិយោបល់៖** មាត្រា២នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) (កថាខណ្ឌទី១) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) (កថាខណ្ឌទី២) ចែងពីសេរីភាពរួចផុតពីរាល់ទម្រង់នៃការរើសអើង និងបង្ហាញបញ្ជីឈ្មោះលម្អិតមួយនៃមូលហេតុដែលមិនអនុញ្ញាតិឲ្យមានការបែងចែកណាមួយ មានជាអាទិ៍ "ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈខាងនយោបាយឬទស្សនៈផ្សេងៗទៀត *ដើមកំណើតជាតិឬសង្គម* ទ្រព្យសម្បត្តិ *កំណើត* ឬស្ថានភាពដទៃៗទៀតឡើយ" (ការបញ្ជាក់បន្ថែម)។ កត្តានេះពង្រឹងការហាមឃាត់ការរើសអើងពូជសាសន៍ ដូចបានកំណត់ក្នុង

អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) ដែលឲ្យនិយមន័យពាក្យការរើសអើងពូជសាសន៍ថា "ការប្រកាន់បែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយម ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ បុព្វញាតិ ឬដើមកំណើតជាតិ ឬជាតិពន្ធុ ដែលមានទិសដៅ ឬអានុភាពបំផ្លាញ ឬបន្ថយការទទួលស្គាល់ ការមានឬការប្រើប្រាស់ក្នុងល័ក្ខខ័ណ្ឌសមភាពនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ខាងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ឬវិស័យដទៃទៀតនៃជីវភាពសាធារណៈ"។ ក្នុងនាមជារដ្ឋភាគីមួយនៃសន្ធិសញ្ញាទាំងនេះ កម្ពុជាមានកាតព្វកិច្ចធ្វើការហាមឃាត់ការរើសអើងដូចដែលបានកំណត់ ។

មានករណីលើកលែងមួយចំនួន។ រដ្ឋភាគីត្រូវបានអនុញ្ញាតឲ្យរឹតត្បិតសិទ្ធិមួយចំនួនរបស់ពលរដ្ឋ ដូចជាសិទ្ធិបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ បើតាមគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការលុបបំបាត់ការរើសអើសពូជសាសន៍ "ការប្រព្រឹត្តផ្សេងគ្នាដោយផ្អែកលើឋានៈពលរដ្ឋ ឬឋានៈអន្តោប្រវេសន៍នឹងបង្កើតទៅជាការរើសអើង ប្រសិនជាលក្ខណៈវិនិច្ឆ័យសម្រាប់ភាពខុសគ្នាទាំងនោះ ត្រូវបានវិនិច្ឆ័យចំពោះកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះមិនត្រូវបានអនុវត្តស្របតាមគោលបំណងធម្មានុរូប ហើយមិនមានលក្ខណៈសមាមាត្រទៅនឹងការធ្វើឲ្យសម្រេចគោលបំណងនេះ"។[8] ដោយការហាមឃាត់ ការជួលដីរដ្ឋ ឬដីកសិកម្មឯកជនតែនៅតាមបណ្តោយព្រំដែនកម្ពុជា ហើយជាពិសេសចំពោះតែ "រូបវន្តបុគ្គ ឬនីតិបុគ្គលបរទេសនៃប្រទេសទាំងឡាយដែលមានព្រំដែនជាប់ជាមួយកម្ពុជា។" មានជាអាទិ៍ ជនជាតិវៀតណាម ឡាវ និងថៃ។ មាត្រា ៦៤ បង្ហាញពីការប្រកាន់បែងចែកយ៉ាងច្បាស់។

បទដ្ឋានជាតិក៏បានហាមឃាត់ការរើសអើងផ្អែកលើសញ្ជាតិផងដែរ។ ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៩៤ ចែងក្នុងមាត្រា២ ថា "ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ"។ មាត្រា៨ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤ មានភាពពាក់ព័ន្ធជាពិសេស ដោយសារមាត្រានេះចែងថា "អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់ និងមិនត្រូវជាកម្មវត្ថុនៃការរើសអើង ដោយតែមូលហេតុសញ្ជាតិបរទេស លើកលែងតែចំពោះដីធ្លីដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល"។ នៅក្នុងសេចក្តីព្រាងច្បាប់នេះ មាត្រា៦៤ សំដៅតែភតិសន្យាដែលមិនមានផលប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិលើដីធ្លីឡើយ។

បទប្បញ្ញត្តិនេះបង្ហាញពីគោលបំណងក្នុងការដោះស្រាយភាពភ័យខ្លាចទូទៅអំពីការការទន្រ្ទានយកដីនៅតាមតំបន់ព្រំដែនដោយប្រទេសឬប្រជាជននៃប្រទេសជិតខាង។ នេះជាការបញ្ជាក់ថា ជនជាតិវៀតណាម ឡាវ និងថៃ ត្រូវបានហាមឃាត់ការទិញដីតែនៅតាមតំបន់ព្រំដែន ដែលផ្ទុយទៅវិញជនបរទេសផ្សេងត្រូវបានសន្និដ្ឋានថាអាចទិញដីនៅទីនោះបាន ឬទីតាំងដទៃក្នុងប្រទេសជាទីដែលជនជាតិវៀតណាម ឡាវ និងថៃត្រូវបានអនុញ្ញាតឲ្យទិញដីសម្រាប់តែផលិតកម្មកសិកម្ម។ ខណៈដែលវាគឺជាសិទ្ធិនិងតួនាទីរបស់ប្រទេសទាំងអស់ក្នុងការរៀបចំដែនដីរបស់ខ្លួន ចំណុចនេះអាចត្រូវបានពិចារណាថាជា "គោលបំណងរបស់ច្បាប់" ក្នុងន័យរបស់ ICERD។ ទោះជាយ៉ាងណាក៏ដោយ ការហាមឃាត់ជាទូទៅផ្អែកទៅលើសញ្ជាតិគឺត្រូវបានចាត់ទុកថាជាការរើសអើងពូជសាសន៍។ នៅពេលដែលដីពាក់ព័ន្ធមិនមែនជាកម្មវត្ថុនៃវិវាទដែនដី វិធីសមស្រប

---

[8] យោបល់ទូទៅរបស់គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការលុបបំបាត់ការរើសអើសពូជសាសន៍លេខ ៣០ (២០០៤) ស្តីពីការរើសអើងលើជនគ្មានសញ្ជាតិ

សម្រាប់បំពេញ "គោលបំណងស្របច្បាប់" នេះអាចអនុវត្តកំណត់ព្រំប្រទល់ដីអនុលោមតាមកូអ័រដោណេដែលបានព្រមព្រៀង ធ្វើដូច្នេះវាអាចធានាថាអ្នកទាំងឡាយដែលស្វែងរកទិញដីក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងតាមតំបន់ព្រំដែនផង បានចូលក្នុងប្រទេសដោយស្របច្បាប់ និងមានសមត្ថភាពផ្លូវច្បាប់ក្នុងការធ្វើការងារនេះ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ថាគួរលុបចោលមាត្រា៦៤ ឬក៏កែសម្រួលមាត្រានេះឡើងវិញ ដោយលុបចោលចំណុចមួយចំនួនដែលមានលក្ខណៈរើសអើង ដើម្បីឲ្យស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ជាពិសេសក្រោមអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។

## ជំពូកទី៦

## ការអភិរក្សធនធានដីកសិកម្ម

### ផ្នែកទី១

### ការអភិរក្សគុណភាពដីកសិកម្ម

មាត្រា ៧៣.-

ត្រូវបានហាមឃាត់៖

(១) ការបំពុលដីកសិកម្មតាមរយៈការប្រើប្រាស់ថ្នាំកសិកម្ម ឬសារធាតុគីមីកសិកម្មលើសកម្រិត ការបញ្ចេញចោលសារធាតុពុលគ្រប់ប្រភេទ ដែលបង្កការបំផ្លាញគុណភាពដីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រព័ន្ធក្សេត្របរិស្ថានដើម។

(២) រាល់សកម្មភាពជីកកកាយ ឈូសឆាយ ចាក់លុបលើដីកសិកម្ម ឬការអនុវត្តការងារវិស្វកម្មកសិកម្ម ដោយខុសបច្ចេកទេស ដែលបង្កការហូរច្រោះដី ឬកំណរស្រទាប់ដី និងបំផ្លាញប្រព័ន្ធក្សេត្របរិស្ថានដើម។

(៣) ការដុតបំផ្លាញចោលនូវសំណល់រុក្ខជាតិឬសំណល់ដំណាំ នៅលើដីស្រែឬចំការ ដែលបង្កការបំផ្លាញមីក្រូសរីរាង្គកាយមានប្រយោជន៍និងបង្កការខូចខាតចំពោះគុណភាពដីកសិកម្ម។

**មតិយោបល់៖** សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា៣៧ និងមាត្រា៤៣។ ការអនុវត្តវិធីសាស្ត្រកសិកម្មបែបប្រពៃណី រួមទាំងការកសិកម្មពនេចរដោយជនជាតិដើមភាគតិច គឺជាសិទ្ធិដែលត្រូវបានការពារក្រោមមាត្រា៣៧ នៃសេចក្តីព្រាងច្បាប់នេះ ច្បាប់ភូមិបាល ឆ្នាំ២០០១ និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនទៀតដែលកម្ពុជាជារដ្ឋភាគី រួមទាំងកតិកាសញ្ញា ICCPR (មាត្រា១ និងមាត្រា២៧) និងអនុសញ្ញា ICERD (មាត្រា៥ (ឃ)(v))។ ដោយហេតុថាកសិកម្មពនេចរ សម្រាប់ក្រុមជនជាតិដើម

ភាគតិចជាច្រើន គឺការដុតសំណល់រុក្ខជាតិលើដីដែលត្រូវទុកចោលមួយរយៈពេល ដូច្នេះមាត្រា៧៣ ហាក់ផ្ទុយនឹងមាត្រា៣៧។

ប្រសិនជាមានចេតនាបន្ទុចបង្អាក់ការអនុវត្តបែបនេះ ការណែនាំនូវការអនុវត្តដែលប្រសើរជាងនេះគួរត្រូវបានធ្វើឡើងតាមរយៈការបណ្តុះបណ្តាល និងការគាំទ្រផ្នែកសម្ភារៈនិងហិរញ្ញវត្ថុ ដូចដែលបានគូសបញ្ជាក់ក្នុងមាត្រា៨៣ ដែលផ្អែកលើមូលដ្ឋានភស្តុតាង ជាជាងតាមរយៈការហាមឃាត់ទាំងស្រុង។ ការិយាល័យ OHCHR សូមសង្កត់ធ្ងន់ថា ការអនុវត្តន៍និងប្រពៃណីជាវប្បធម៌របស់ជនជាតិដើមភាគតិចត្រូវតែមានការគោរព ហើយថារាល់ការផ្លាស់ប្តូរណាមួយត្រូវតែកើតចេញពីជម្រើសដែលបានធ្វើឡើងដោយស្ម័គ្រចិត្ត។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**តាក់តែងឡើងវិញនូវមាត្រា ៧៣ វាក្យខណ្ឌទី៣ ដូចខាងក្រោម៖

*"(៣) ការដុតបំផ្លាញចោលនូវសំណល់រុក្ខជាតិឬសំណល់ដំណាំ នៅលើដីស្រែឬចំការ ដែលបង្កការបំផ្លាញមីក្រូសរីរាង្គកាយមានប្រយោជន៍ និងបង្កការខូចខាតចំពោះគុណភាពដីកសិកម្ម លើកលែងតែជនជាតិដើមភាគតិចដែលអនុញ្ញាតឲ្យអនុវត្តវិធីសាស្ត្រកសិកម្មប្រពៃណីរបស់ខ្លួន។"*

## ជំពូក៧

## ការផ្ទេរដីកសិកម្ម

មាត្រា ៨៤.-

ធនធានដីកសិកម្ម ដែលបានចាត់ថ្នាក់ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ទោះបីកាន់កាប់ដោយរូបភាពកម្មសិទ្ធិណាមួយក្តី អាចប្រើប្រាស់និងអភិវឌ្ឍន៍ក្រៅគោលបំណងកសិកម្មបានលុះត្រាតែមានការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈគម្រោងអភិវឌ្ឍន៍សម្រាប់ប្រយោជន៍សាធារណៈចាំបាច់ ដែលមានអាទិភាពនិងសក្តានុពលសេដ្ឋកិច្ចខ្ពស់ជាងផលិតកម្មកសិកម្ម។

ធនធានដីកសិកម្មពាក់ព័ន្ធក្រោមគម្រោងអភិវឌ្ឍន៍ដែលសម្រេចដោយរាជរដ្ឋាភិបាល ដូចមានចែងក្នុងមាត្រានេះ ត្រូវធ្វើការផ្ទេរដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មតិយោបល់៖** មាត្រា៨៤ ទទួលស្គាល់ថា រដ្ឋអាចកំណត់ថាផលប្រយោជន៍សាធារណៈក្នុងគម្រោងអភិវឌ្ឍន៍ជាក់លាក់អាចមានច្រើនជាងផលប្រយោជន៍បុគ្គលក្នុងការប្រើប្រាស់ដីជាក់លាក់ណាមួយ។ ទោះជាយ៉ាងណាក៏ដោយ ការអនុញ្ញាតឲ្យរដ្ឋាភិបាលសម្រេចជាឯកតោភាគីឲ្យកាន់កាប់ ឬផ្ទេរធនធានដីកសិកម្មដោយគ្មានការពិគ្រោះយោបល់ជាមួយ បុគ្គល ក្រុម ឬសហគ្រាសដែលរងផលប៉ះពាល់ ឬដោយមានការយល់ព្រមពីពួកគេនោះ មាត្រា៨៤ នេះបានប្រានចោលលក្ខខណ្ឌតម្រូវឲ្យមានកិច្ចពិគ្រោះយោបល់ដែលមានចែងក្នុងមាត្រា៧ មាត្រា៩ មាត្រា៣៧ និងមាត្រា៤៥។

មាត្រា៨៤ ក៏ប្រានចោលផងដែរនូវការទទួលស្គាល់ ការប្រើប្រាស់និងកម្មសិទ្ធិឯកជន និងសមូហភាពសហគមន៍ ដែលមានចែងក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា១៧ នៃសេចក្តីប្រកាសជាសកលស្តីពី

សិទ្ធិមនុស្ស។ សូមអានមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា៣៥។ យោងតាមមាត្រា២៩ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងមាត្រា៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋអាចដាក់សិទ្ធិទាំងនេះ "ឲ្យមានព្រំដែន ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ" "សម្រាប់តែដើម្បី... សុខមាលភាពទូទៅប៉ុណ្ណោះ នៅក្នុងសង្គមប្រជាធិបតេយ្យ"។ គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងជាតិ ចែងថា "... រដ្ឋគប្បីធ្វើអស្សាមិករណ៍តែក្នុងករណីដែលសិទ្ធិចំពោះដី...មានភាពចាំបាច់សម្រាប់គោលបំណងសាធារណៈប៉ុណ្ណោះ។ រដ្ឋគប្បីកំណត់ឲ្យបានច្បាស់នូវទស្សនទាននៃគោលបំណងសាធារណៈនៅក្នុងច្បាប់ ដើម្បីអនុញ្ញាតឲ្យមានការពិនិត្យមើលឡើងវិញតាមផ្លូវតុលាការ"។

បើគ្មានគុណវឌ្ឍ ឬនីតិវិធីណាមួយអំពីរបៀបដែលការសម្រេចដកហូតដីត្រូវធ្វើយ៉ាងណាទេ នីតិវិធីនៃការដកហូតដីជាក់ស្តែង ឬលក្ខណៈវិនិច្ឆ័យសម្រាប់កិច្ចពិគ្រោះយោបល់ឬការផ្តល់សំណងនោះ គឺមាត្រា៨៤ បង្ហាញពីហានិភ័យខ្ពស់ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលរួមរិតទៅដោយភាពស្រពិចស្រពិលនៃពាក្យពេចន៍ដូចខាងក្រោមនេះ៖

- "សេចក្តីសម្រេចរបស់រដ្ឋាភិបាល"៖ វាមិនច្បាស់ថាសេចក្តីសម្រេចនេះធ្វើឡើងតាមរយៈប្រកាស បទបញ្ជា ឬយន្តការផ្លូវការណាមួយ និងនៅកម្រិតណា ហើយថាតើវានៅកម្រិតក្រសួង ឬតម្រូវឲ្យមានការអនុញ្ញាតពីថ្នាក់លើ ដូចជាពីគណៈរដ្ឋមន្ត្រីជាដើម។
- "ប្រយោជន៍សាធារណៈចាំបាច់"៖ មិនមានការបង្ហាញពីលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ពីផលប្រយោជន៍សាធារណៈនេះទេ មិនមានការចាត់ចែងនូវស្ថាប័នណាមួយដែលអាចធ្វើការកំណត់រឿងនេះដែរ ហើយថាតើត្រូវផ្អែកលើមូលដ្ឋានអ្វីខ្លះ
- "អាទិភាពនិងសក្តានុពលសេដ្ឋកិច្ចខ្ពស់ជាងផលិតកម្មកសិកម្ម"៖ វិធីដែលអាទិភាពចំពោះគម្រោងអភិវឌ្ឍន៍ត្រូវបានកំណត់ និងសក្តានុពលភាពរបស់វាដែលត្រូវបានវាស់វែងគឺមានភាពមិនច្បាស់លាស់។
- "ការផ្ទេរ"៖ ទោះជាកម្មសិទ្ធិឯកជនអាចត្រូវបានចាត់ទុកជាមោឃៈ ហើយកម្មសិទ្ធិនោះត្រូវបានផ្ទេរឲ្យរដ្ឋ ឬសិទ្ធិប្រើប្រាស់ដីត្រូវបានផ្ទេរដោយគ្មានកម្មសិទ្ធិ ដែលក្នុងករណីនេះរដ្ឋជាអ្នកបង់ថ្លៃប្រើប្រាស់ទៅឲ្យម្ចាស់កម្មសិទ្ធិ។

ជាងនេះទៅទៀត មាត្រា៨៤ មិនមាននិយាយអំពីសិទ្ធិទទួលបានព័ត៌មានត្រឹមត្រូវដូចដែលបានធានាការពារនៅក្នុងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ICCPR, ភាពលំអិតនៃពាក្យ "អាទិភាពសេដ្ឋកិច្ចខ្ពស់ជាង" ពាក្យ "ប្រយោជន៍សាធារណៈ" មូលដ្ឋានជាភស្តុតាងដែលអាចឲ្យជឿជាក់បានអំពី "ភាពចាំបាច់", នីតិវិធីសម្រាប់ការធ្វើសេចក្តីសម្រេចលើអាទិភាពដែលត្រូវបន្តអនុវត្ត និងអត្តសញ្ញាណកម្មនៃដីដែលត្រូវផ្ទេរទៅឲ្យរដ្ឋ និងនីតិវិធីសម្រាប់ការពិគ្រោះយោបល់ ការផ្តល់សំណង និងការផ្ទេរកម្មសិទ្ធិ។ ច្បាប់នេះមិនបានចែងឲ្យច្បាស់ថាសំណងសមរម្យនឹងត្រូវផ្តល់ឲ្យម្ចាស់កម្មសិទ្ធិ និងអ្នកកាន់កាប់ដីដែលត្រូវបានគេផ្ទេរដីនោះទេ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍** ឲ្យមានការកែសម្រួលមាត្រា៨៤ ឡើងវិញ ដោយដាក់បញ្ចូលនិយមន័យច្បាស់លាស់នៃពាក្យ "សេចក្តីសម្រេចរបស់រដ្ឋាភិបាល" "ប្រយោជន៍សាធារណៈចាំបាច់" "អាទិភាពនិងសក្តានុពលសេដ្ឋកិច្ចខ្ពស់ជាងផលិតកម្មកសិកម្ម" និងពាក្យ "ការផ្ទេរ"។ ការកែសម្រួលឡើងវិញនូវមាត្រានេះគប្បីចែងនូវនីតិវិធីតម្លាភាពសម្រាប់កំណត់លើ "គម្រោងអភិវឌ្ឍន៍សម្រាប់ប្រយោជន៍សាធារណៈចាំបាច់ដែលមានអាទិភាពនិងសក្តានុពលសេដ្ឋកិច្ចខ្ពស់ជាងផលិតកម្មកសិកម្ម" ដែលបានជ្រើសរើស ដែលមាននូវកិច្ចពិគ្រោះយោបល់ជាសាធារណៈ ជាពិសេសជាមួយអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដែលមានការទទួលស្គាល់។ សម្រាប់ការដកហូតដីជាយថាហេតុពីម្ចាស់កម្មសិទ្ធិនិងអ្នកកាន់កាប់ដីដោយរដ្ឋសម្រាប់គម្រោងទាំងនោះ ត្រូវបង្កើតនីតិវិធីតម្លាភាពមួយ ដោយមានការទទួលបាននូវការយល់ព្រមជាមុន ដោយសេរី និងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ នៅមុនពេលដីដែលបានកំណត់នោះត្រូវបានផ្ទេរ ហើយត្រូវមានការវាយតម្លៃប្រកបដោយតម្លាភាព អំពីកម្រិតសមរម្យនៃសំណងដែលត្រូវផ្តល់សម្រាប់ដីនោះ។

មាត្រា ៨៥.-

រាជរដ្ឋាភិបាលមានសិទ្ធិសម្រេចផ្ទេរដីរដ្ឋ ទោះស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឬស្ថាប័នមួយណាក្តី មកជាធនធានកសិកម្មក្រោមគោលបំណងអភិវឌ្ឍន៍ផលិតកម្មកសិកម្មតាមរយៈកិច្ចព្រមព្រៀងសម្បទាន ឬគម្រោងអភិវឌ្ឍន៍កសិកម្មរយៈពេលវែង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ដីរដ្ឋដែលត្រូវផ្ទេរក្រោមគោលបំណងនៃមាត្រានេះ ត្រូវរំសាយចំណាត់ថ្នាក់ប្រើប្រាស់ដើម មកស្ថិតនៅក្រោមចំណាត់ថ្នាក់ធនធានដីកសិកម្មក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្មនិងត្រូវចុះបញ្ជីប្រើប្រាស់ដីកសិកម្ម ស្របតាមបទប្បញ្ញតិនៃច្បាប់នេះ។

**មតិយោបល់៖** មាត្រា៨៥ អនុញ្ញាតឲ្យ លក់ ជួល ឬផ្តល់សម្រាប់ផលិតកម្មកសិកម្មលើដីរដ្ឋបានក្រោមសម្បទាន ឬគម្រោងអភិវឌ្ឍន៍រយៈពេលវែង។ អនុលោមតាមមាត្រា២ កថាខណ្ឌទី៣ នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិអភិវឌ្ឍន៍ចែងថា "រដ្ឋមានសិទ្ធិនិងភារៈកិច្ចបង្កើតគោលនយោបាយអភិវឌ្ឍន៍ជាតិសមស្របក្នុងគោលបំណងឲ្យមានភាពប្រសើរឡើងនៃសុខុមាលភាពរបស់ប្រជាជនទាំងមូល និងរបស់បុគ្គលគ្រប់រូប ផ្អែកលើមូលដ្ឋាននៃការចូលរួមរបស់ពួកគេដ៏សកម្ម ដោយសេរី និងប្រកបដោយអត្ថន័យក្នុងការអភិវឌ្ឍ និងក្នុងការបែងចែកប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌នូវអត្ថប្រយោជន៍ដែលបានមកពីការការអភិវឌ្ឍនោះ"។ សិទ្ធិរបស់រដ្ឋក្នុងការធ្វើសេចក្តីសម្រេចបែបនេះ ដូចដែលបានអនុញ្ញាតក្នុងមាត្រា៨៥ គឺត្រូវបានទទួលស្គាល់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្ថិតក្រោមលក្ខខណ្ឌដែលកំណត់ថា សេចក្តីសម្រេចនេះត្រូវតែបានធ្វើឡើងតាមរយៈដំណើរការមួយដែលមានការចូលរួម ហើយដែលវារួមចំណែកដល់ការបែងចែកប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌នូវអត្ថប្រយោជន៍ដែលកើតចេញពីសេចក្តីសម្រេចនោះ។ សូមមើលមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា៨៤ ស្តីពីសេចក្តីត្រូវការឲ្យមាននីតិវិធី ដែលមានតម្លាភាព និងមូលដ្ឋានភស្តុតាងរឹងមាំសម្រាប់ការកំណត់ដីដែលត្រូវផ្ទេរ។ សិទ្ធិទទួលបានព័ត៌មាន ដូចដែលមានចែងក្នុងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ICCPR អំពីការធ្វើសេចក្តីសម្រេចចិត្ត និងការផ្តល់ហេតុផលសម្រាប់សេចក្តីសម្រេចទាំងនោះ គប្បី

ត្រូវបានធានាការពារទាំងស្រុងថាជាសមាសធាតុមួយដ៏សំខាន់នៃ "ការចូលរួមដ៏សកម្ម ដោយសេរី និងប្រកបដោយអត្ថន័យ"។

មានការគិតគួរយកចិត្តទុកដាក់ជាពិសេសចំពោះដីរដ្ឋដែលបច្ចុប្បន្នកំពុងត្រូវបានការពារសម្រាប់គោលបំណងការពារបរិស្ថាន ឬសម្រាប់ការប្រើប្រាស់ដោយជនជាតិដើមភាគតិច។ ដីទាំងនោះ គប្បីបន្តរក្សាការពារសម្រាប់គោលបំណងទាំងនេះ ដែលឆ្លើយតបទៅនឹងមាត្រា១៣ មាត្រា១៤ និងមាត្រា១៧នៃអនុសញ្ញា ILO ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ និងមាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ និងមាត្រា៣២ នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP)។ ចំពោះជនជាតិដើមភាគតិច សិទ្ធិរបស់ពួកគេក្នុងការស្វ័យសម្រេច ត្រូវតែបានការពារ ដូចមានចែងក្នុងមាត្រា១ កថាខណ្ឌទី២ នៃកតិកាសញ្ញា ICCPR ផង និងកតិកាសញ្ញា ICESCR ផង ដែលមានចែងដូចគ្នានេះថា "ក្នុងករណីណាក៏ដោយ ក៏ប្រជាជាតិនីមួយៗ មិនត្រូវបានដកហូតមធ្យោបាយផ្ទាល់របស់ខ្លួន សម្រាប់ចិញ្ចឹមជីវិតឡើយ"។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យមានការកែសម្រួលឡើងវិញនូវមាត្រា៨៥ ដោយដាក់ចេញនូវនីតិវិធីមួយមានតម្លាភាពសម្រាប់ការកំណត់ដីរដ្ឋមួយចំនួនសម្រាប់ផ្ទេរទៅជាធនធានដីកសិកម្ម ដែលត្រូវឲ្យមានកិច្ចពិគ្រោះយោបល់សាធារណៈ ជាពិសេសជាមួយអ្នកជំនាញដែលមានការទទួលស្គាល់ក្នុងការការពារបរិស្ថាននិងបុគ្គលឬសហគមន៍ដែលនឹងរងផលប៉ះពាល់។ រាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដែលជាមូលដ្ឋាននៃការធ្វើសេចក្តីសម្រេចផ្ទេរដីត្រូវផ្សព្វផ្សាយជាសាធារណៈ។ ជាងនេះទៀត ការកែសម្រួលមាត្រានេះឡើងវិញត្រូវបញ្ជាក់ថា ដីរដ្ឋដែលបុគ្គលឬសហគមន៍ពឹងអាស្រ័យ ជាពិសេស ជនជាតិដើមភាគតិច ត្រូវបានរួចផុតពីការផ្ទេរ ដែលអនុញ្ញាតក្រោមមាត្រានេះ។

### មាត្រា ៨៦.-

រាល់គម្រោងអភិវឌ្ឍន៍ដែលគ្របដណ្តប់លើធនធានដីកសិកម្មត្រូវមានការសិក្សា និងការវាយតម្លៃជាមុន លើផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងក្សេត្របរិស្ថាននៃតំបន់ផលិតកម្មកសិកម្ម និងត្រូវបានផ្តល់អនុសាសន៍ដោយគណៈកម្មាធិការគោលនយោបាយជាតិធនធានដីកសិកម្ម។

ក្រសួងទទួលបន្ទុកវិស័យកសិកម្មមានតួនាទីលើកសំណើរជូនរាជរដ្ឋាភិបាលលើរាល់គម្រោងផ្ទេរដីកសិកម្មទាំងឡាយ ទោះបីសម្រាប់គម្រោងអភិវឌ្ឍន៍ក្រៅគោលបំណងកសិកម្មក្តី ដើម្បីធានាឲ្យការផ្ទេរដីកសិកម្មអាចទទួលបាននូវប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ ដោយផ្តល់ផលប្រយោជន៍ជាអាទិភាពសម្រាប់សហគមន៍មូលដ្ឋាន និងកាត់បន្ថយជាអតិបរិមានូវផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងក្សេត្របរិស្ថាន ព្រមទាំងជៀសវាងនូវទំនាស់ដីធ្លី។

អង្គភាពទទួលបន្ទុកកិច្ចការធនធានដីកសិកម្មនៃក្រសួងទទួលបន្ទុកដីកសិកម្មមានសមត្ថកិច្ចសិក្សាវាយតម្លៃ ចំពោះស្ថានភាពដីកសិកម្មទាំងឡាយណា ដែលស្នើសុំផ្ទេរសម្រាប់ការប្រើប្រាស់ឬការអភិវឌ្ឍន៍ក្រៅគោលបំណងផលិតកម្មកសិកម្ម។

**មតិយោបល់៖** ការិយាល័យOHCHR សូមស្វាគមន៍ គោលបំណងដែលបញ្ជាក់នៅក្នុងមាត្រានេះ ដែលថារាល់ការផ្ទេរដីកសិកម្មត្រូវដាក់ជាអាទិភាពសម្រាប់គោលបំណងផ្តល់អត្ថប្រយោជន៍ដំបូងគេ គឺឲ្យទៅសហគមន៍មូលដ្ឋាន។ ការយាល័យOHCHR សូមអបអរសាទរផងដែរចំពោះលក្ខខណ្ឌតម្រូវឲ្យធ្វើការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម សម្រាប់គម្រោងអភិវឌ្ឍន៍ដែលពាក់ព័ន្ធការផ្ទេរដីកសិកម្មទៅជាដីមួយប្រភេទផ្សេងទៀត ដែលមិនបម្រើឲ្យវិស័យកសិកម្ម។ អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ការវាយតម្លៃផលប៉ះពាល់គប្បីមានការចូលរួមពេញលេញជាពិសេសពីសមាជិកសហគមន៍ដែលរងផលប៉ះពាល់។ សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា៩។ ដើម្បីឈានទៅសម្រេចគោលដៅនេះ ព័ត៌មានអំពីការរៀបចំគម្រោង ការអនុវត្ត និងលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់ គប្បីផ្សព្វផ្សាយជាសាធារណៈ និងអាចរកបាន ហើយការទទួលខុសត្រូវក្នុងការវាយតម្លៃផលប៉ះពាល់ គប្បីធ្វើការកំណត់ឲ្យបានច្បាស់លាស់នៅក្នុងមាត្រា៨៦ កថាខណ្ឌទី១។

ដំណើរការដែលដាក់ចេញនៅក្នុងមាត្រានេះទំនងជាថា នៅពេលទទួលបានអនុសាសន៍ពីគណៈកម្មាធិការគោលនយោបាយជាតិធនធានដីកសិកម្មហើយ ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលអំពីគម្រោងអភិវឌ្ឍន៍ជាក់លាក់ដែលអាចនាំដល់ការផ្ទេរដីកសិកម្មទៅឲ្យអ្នកអភិវឌ្ឍឯកជន សម្រាប់ប្រើប្រាស់លើវិស័យមិនមែនកសិកម្ម។ ផ្ទុយទៅនឹងគោលបំណងនៃមាត្រា៨៤ ដែលសំដៅលើកកម្ពស់ប្រយោជន៍សាធារណៈ មាត្រា៨៦ បែរជាអនុញ្ញាតឲ្យផ្ទេរដីសម្រាប់ផលប្រយោជន៍ឯកជនទៅវិញ ល្គឹកណាពួកគេសន្យា "ប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ ដែលផលប្រយោជន៍ជាអាទិភាពដល់សហគមន៍មូលដ្ឋាន មាត្រានេះរំលងចោលកាតព្វកិច្ចនៃការរៀបចំកិច្ចពិគ្រោះយោបល់ឬដើម្បីទទួលបានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពីអ្នកដែលរងផលប៉ះពាល់ ដែលអាចនឹងរងការរំលោភបំពានលើសិទ្ធិទ្រព្យសម្បត្តិរបស់ពួកគេ។ សូមមើលអនុសាសន៍របស់ ការិយាល័យOHCHR លើមាត្រា៨៤។ ដើម្បីធ្វើឲ្យប្រាកដថាគោលបំណងនៃ "ប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ ដោយផ្តល់ផលប្រយោជន៍ជាអាទិភាពសម្រាប់សហគមន៍មូលដ្ឋាន និងកាត់បន្ថយផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងប្រព័ន្ធអេកូឡូស៊ីបរិស្ថាន" ត្រូវបានវាយតម្លៃដោយត្រឹមត្រូវនិងចំគោលដៅនោះ លក្ខណៈវិនិច្ឆ័យលំអិតនីមួយៗនៃគោលគំនិតទាំងនេះត្រូវតែបង្កើតឡើងសម្រាប់វាស់ស្ទង់នូវអ្វីដែលអាចប្រមើលឃើញថាជាផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ ដូច្នេះគេនឹងធ្វើការសម្រេចចិត្តមួយដែលមានព័ត៌មានគ្រប់គ្រាន់។

មាត្រា៨៦ ចែងរំលងនីតិវិធីនៃការផ្តល់សំណងចំពោះការផ្ទេរដីនៃដីដែលកាន់កាប់ដោយបុគ្គល គ្រួសារ សហគមន៍ ឬសហគ្រាស។ មតិយោបល់ និងអនុសាសន៍របស់ការិយាល័យOHCHR លើមាត្រា៣៧ ដែលបានពន្យល់អំពីអភិក្រមសិទ្ធិមនុស្ស អំពីការផ្តល់សំណងចំពោះដីដែលពឹងអាស្រ័យដោយសហគមន៍ជនជាតិដើមភាគតិច ដែលអាចអនុវត្តមិនមែនត្រឹមតែចំពោះសហគមន៍ទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែអនុវត្តចំពោះបុគ្គលទាំងអស់ដែលរងការប៉ះពាល់ដោយសារការផ្ទេរដី។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ឲ្យ**កែសម្រួលមាត្រា៨៦ ឡើងវិញដោយដាក់បញ្ចូលចំណុចមួយចំនួនដូចខាងក្រោម៖

- *នីតិវិធីសម្រាប់កិច្ចពិគ្រោះយោបល់ជាសាធារណៈចំពោះអនុសាសន៍សម្រាប់ការផ្ទេរដីកសិកម្ម សម្រាប់ការប្រើប្រាស់ក្នុងគោលបំណងមិនមែនកសិកម្មដោយស្ថាប័នមួយ ដូចជាគណៈកម្មាធិការជាតិគោលនយោបាយធនធានដីកសិកម្ម។*
- *នីតិវិធីនៃការទទួលបាននូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពីម្ចាស់និងអ្នកកាន់កាប់ធនធានដីកសិកម្ម ដែលត្រូវបានស្នើឲ្យផ្ទេរទៅជាគម្រោងអភិវឌ្ឍន៍មិនមែនគោលបំណងកសិកម្ម*
- *លក្ខណៈវិនិច្ឆ័យពិស្តារអំពីការវាស់ស្ទង់លើ "ប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដោយផ្តល់ផលប្រយោជន៍ជាអាទិភាពសម្រាប់សហគមន៍មូលដ្ឋាន និងកាត់បន្ថយផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងប្រព័ន្ធអេកូឡូស៊ី"*
- *នីតិវិធីនៃការចូលរួមសម្រាប់ការកំណត់កម្រិតសំណងត្រឹមត្រូវយុត្តិធម៌ ចំពោះបុគ្គល គ្រួសារឬសហគមន៍ដែលរងផលប៉ះពាល់ដោយការផ្ទេរដី ដោយផ្អែកលើតម្លៃទីផ្សារចំពោះដីដែលបាត់បង់ដោយការផ្ទេរ និង*
- *បញ្ជាក់ពីការទទួលខុសត្រូវលើកិច្ចដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ដោយស្ថាប័នរដ្ឋណាមួយឲ្យច្បាស់លាស់ ក៏ដូចជាការតាមដានជាបន្តបន្ទាប់លើគម្រោង។*

## ជំពូកទី៨

## ការចូលរួម និងការផ្សព្វផ្សាយអប់រំ

មាត្រា ៨៩.-

រូបវន្តបុគ្គល ឬនីតិបុគ្គល កម្មសិទ្ធិករដីធ្លី ដែលកាន់កាប់និងប្រើប្រាស់ដីកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានករណីកិច្ចចូលរួមថែរក្សាគុណភាពដី អភិរក្សធនធាន ដីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ី សំរាប់និរន្តន៍ភាពនៃមត៌កកសិកម្មជាតិ។

**មតិយោបល់៖** មាត្រា៨៩ ពង្រឹងឡើងវិញការដាក់កាតព្វកិច្ចលើគ្រួសារកសិករឲ្យចូលរួមក្នុងការ "ថែរក្សាគុណភាពដី អភិរក្សធនធានដីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ី សំរាប់និរន្តន៍ភាពនៃមត៌កកសិកម្មជាតិ"។ វាបង្ហាញពីកាតព្វកិច្ចស្រដៀងគ្នានេះដែលបានកំណត់នៅក្នុងមាត្រា២៤ និងសំដៅទៅលើមាត្រា២៦ ដែលកំណត់អំពីធាតុផ្សំនៃ "ការអនុវត្តន៍កសិកម្មប្រកបដោយនិរន្តភាព"។ នៅក្នុងមតិយោបល់លើ មាត្រា៧ ការិយាល័យ OHCHR បានផ្តល់អនុសាសន៍ឲ្យ ផ្លាស់ប្តូរពី កាតព្វកិច្ច ទៅជាការលើកទឹកចិត្តវិញ។ សូមមើលមតិយោបល់របស់ការិយាល័ OHCHR លើមាត្រា ៧ និងមាត្រា ២៤។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍ថា** ក្នុងមាត្រា ៨៩ ពាក្យ "កាតព្វកិច្ច" ត្រូវជំនួសដោយ "ការលើកទឹកចិត្ត" និងសូមផ្តល់អនុសាសន៍បន្ថែមពាក្យនៅចុងឃ្លានៃមាត្រាដូចតទៅនេះ៖ "*...មត៌កកសិកម្មជាតិ ដែលស្របនិងមាត្រា២៤ និងមាត្រា២៦។ រូបវន្តបុគ្គល ឬនីតិបុគ្គល ឬកម្មសិទ្ធិករនៃដីអាចស្នើសុំការគាំទ្រពីក្រសួងដែលទទួលបន្ទុកវិស័យកសិកម្ម ដើម្បីសម្រេចគោលបំណងនេះ ស្របតាមមាត្រា៧។*"

មាត្រា ៩០.-

រដ្ឋលើកទឹកចិត្តការថែរក្សាគុណភាពដី អភិរក្សធនធានដីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ីបរិស្ថាន សម្រាប់និរន្តន៍ភាពនៃមត៌កកសិកម្មជាតិ តាមរយៈការចូលរួមរបស់សហគមន៍មូលដ្ឋានមូលដ្ឋាន និងការគាំទ្ររបស់អង្គការសង្គមពាក់ព័ន្ធ ក្នុងនោះការបញ្ជ្រាបយេនឌ័រ ត្រូវបានលើកទឹកចិត្តជាអាទិភាព។

ក្រសួងទទួលបន្ទុកវិស័យកសិកម្មត្រូវមានវិធានការសមស្របក្នុងការគ្រប់គ្រងធនធានដីកសិកម្មអចិន្ត្រៃយ៍ តាមរយៈការអនុវត្តកម្មវិធីផ្សព្វផ្សាយ អប់រំ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈចំពោះសហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើម ភាគតិច ប្រជាកសិករ និងអ្នកប្រើប្រាស់ដីកសិកម្មគ្រប់រូបភាព ដោយសហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ថ្នាក់ អង្គការជាតិ និងអន្តរជាតិ។

**មតិយោបល់៖** ការិយាល័យOHCHR ស្វាគមន៍ចំពោះគោលបំណងលើកទឹកចិត្តបញ្ជ្រាបយេនឌ័រជាអាទិភាពចំពោះការចូលរួមរបស់សហគមន៍មូលដ្ឋាននិងការគាំទ្ររបស់អង្គការសង្គមពាក់ព័ន្ធ ក្នុងការថែរក្សាគុណភាពដី ។ ទោះជាយ៉ាងណា ជាការផ្ទុយទៅនឹងអាទិភាពផ្សេងទៀត សកម្មភាពជាក់លាក់អំពីការបញ្ជ្រាបយេនឌ័រមិនត្រូវបានកំណត់ឡើយ ដែលជាហានិភ័យនោះ គឺមន្ត្រីមួយចំនួនអាចកាត់បន្ថយការគិតគូរពិចារណាដ៏សំខាន់អំពីយេនឌ័រនេះមកនៅត្រឹមជាការរាប់ចំនួននៃអ្នកចូលរួមជាស្ត្រីនៅក្នុងកម្មវិធី ជាជាងការគិតគូរបញ្ចូលយ៉ាងពេញលេញនូវទស្សនៈ កង្វល់ និងសំណើរដោះស្រាយរបស់ស្ត្រី។ ក្រសួងកិច្ចការនារីគួរតែមានលទ្ធភាពផ្តល់ការណែនាំ និងមតិយោបល់ជាក់លាក់ក្នុងការងារនេះ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**បន្ថែមប្រយោគថ្មីមួយនៅផ្នែកចុងបញ្ចប់នៃកថាខណ្ឌទី១ ដូចតទៅនេះ "*សកម្មភាពជាក់លាក់នៃការបញ្ជ្រាបយេនឌ័រ ត្រូវធានា និងកំណត់នៅក្នុងប្រកាសដោយឡែក*"។ ប្រកាសនឹងត្រូវបង្កើតឡើងរួមគ្នាជាមួយក្រសួងកិច្ចការនារី។ ជាជំរើសផ្សេងទៀតគឺលក្ខខណ្ឌតម្រូវអាចមានរៀបរាប់លំអិតនៅក្នុងមាត្រានេះផ្ទាល់ (និងយោងលក្ខខណ្ឌដែលពាក់ព័ន្ធមានក្នុងអត្ថបទច្បាប់ និងនៅក្នុងមាត្រា ៩១) និងមានកំណត់នៅក្នុងសន្ទានុក្រមនៃច្បាប់ផង។

## ជំពូកទី១០

## ភ្នាក់ងារដីកសិកម្ម និងការជំរុញអនុវត្តន៍ច្បាប់

មាត្រា ៩៩.-

បុគ្គលណាដែលមិនសុខចិត្តនិងវិធានការរបស់ភ្នាក់ងារដីកសិកម្មមានសមត្ថកិច្ច មានសិទ្ធិធ្វើលិខិតតវ៉ាជាលាយល័ក្ខអក្សរជូនក្រសួងទទួលបន្ទុកវិស័យកសិកម្មក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលកំណត់ហេតុត្រួតពិនិត្យ របស់ភ្នាក់ងារដីកសិកម្មមានសមត្ថកិច្ច។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យកសិកម្ម ត្រូវចាត់តាំងយន្តការស្រាវជ្រាវចំពោះករណីតវ៉ា លើការចាត់វិធានការរបស់ភ្នាក់ងារជំនាញកសិកម្មមានសមត្ថកិច្ច និងត្រូវចេញសេចក្តីសំរេចលើករណីតវ៉ានោះ ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ ដោយគិតចាប់ពី កាលបរិច្ឆេទទទួលលិខិតតវ៉ា។

ក្នុងករណី បុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យកសិកម្ម បុគ្គលនោះមានសិទ្ធិធ្វើលិខិតតវ៉ាទៅយន្តការផ្សេងទៀតរបស់រដ្ឋាភិបាល ឬធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី។

**មតិយោបល់៖** គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស បានបង្ហាញយ៉ាងច្បាស់ពីលក្ខណៈវិនិច្ឆ័យដែលគួរតែឆ្លុះបញ្ចាំងនៅក្នុងយន្តការបណ្តឹងក្រៅប្រព័ន្ធតុលាការ ដើម្បីធានាបាននូវប្រសិទ្ធិភាព។ យោងតាមគោលការណ៍ណែនាំ យន្តការបណ្តឹងដែលមានប្រសិទ្ធិភាពត្រូវមានចរិកលក្ខណៈ៖ ស្របច្បាប់ អាចប្រើប្រាស់បាន អាចព្យាករណ៍បាន សមធម៌ តម្លាភាព និងគាំទ្រសិទ្ធិមនុស្សជានិរន្ត។ យន្តការដែលជាប្រភពនៃការសិក្សាជាបន្ត និងដែលផ្អែកលើការចូលរួម និងកិច្ចពិភាក្សា។ ទាំងនេះគឺមានពន្យល់នៅក្នុងមតិយោបល់ និងអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា ៥៩។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឱ្យបំពេញបន្ថែមនៅចុងកថាខណ្ឌទី២ នៃមាត្រា ៩៩ នូវអត្ថបទដូចតទៅនេះ៖ "យន្តការនេះនឹងបំពេញតាមបទដ្ឋានអំពីវិធានដោះស្រាយវិវាទដែលមានចែងក្នុងមាត្រា៥៩ (ដែលកែសម្រួល)។ ក្នុងករណីអវត្តមាននៃការសម្រេចចិត្តក្នុងរយៈពេលដែលបានកំណត់ ភ្នាក់ងារជំនាញកសិកម្មមានសមត្ថកិច្ចត្រូវផ្អាកការចាត់វិធានការរបស់ខ្លួន រហូតដល់ការចេញសេចក្តីសម្រេចចុងក្រោយរបស់យន្តការ។"

## ជំពូកទី១១

## ទោសប្បញ្ញត្តិ

**មាត្រា ១១២.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ១០០០០០០០ (ដប់លាន)រៀល ដល់ ២០០០០០០០ (ម្ភៃលាន) រៀល ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល កម្មសិទ្ធិករ ឬអ្នក ប្រើប្រាស់ដីកសិកម្មដែលបានចាត់ថ្នាក់ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ សំរាប់ផលិតកម្មកសិកម្មគ្រួសារ ក្រោមតំបន់អភិវឌ្ឍន៍កសិកម្ម ឬក្រោមភតិសន្យាជួល ដើម្បីអនុវត្តផលិតកម្មកសិកម្ម ដោយប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើ ដូចខាងក្រោម៖

១- អនុវត្តការងារវិស្វកម្មកសិកម្ម តាមរយៈការឈូសឆាយ ការកកាយ ការភ្ជួរ ការចាក់លុប ការជីក ការពូនគំនរ ឬការងារផ្សេងទៀតក្នុងការរៀបចំដីកសិកម្ម ដែលបង្កអោយមានការហូរច្រោះ ការបាត់បង់ជីជាតិដីស្រទាប់លើ ការប្រែប្រួលវាយនភាព និងគុណភាពដី ការបង្កកំណដី ឬខ្សាច់នៅផ្នែកនៅផ្នែកខាងក្រោមខ្សែទឹក ការបាត់បង់ ប្រភពទឹក ការបាត់បង់

ដីវៈចម្រុះកសិកម្ម និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ឬបំផ្លាញប្រព័ន្ធ អេកូឡូស៊ី បរិស្ថានសំរាប់ផលិតកម្មកសិកម្ម។

២- អនុវត្តកិច្ចប្រតិបត្តិកសិកម្ម តាមរយៈការប្រើសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្មគ្រប់ប្រភេទ ដែលបង្កអោយពុលដីកសិកម្ម ពុលទឹកកសិកម្ម ខូចខាតគុណភាពដី បង្ក គ្រោះថ្នាក់ដល់ជីវៈចម្រុះកសិកម្ម និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ឬបំផ្លាញប្រព័ន្ធអេកូឡូស៊ី បរិស្ថានរួមក្នុងតំបន់ផលិតកម្មកសិកម្ម។

៣- ល្មើសនឹងបទហាមឃាត់ដូចមានចែងក្នុងមាត្រា ៧៣ និងមាត្រា៨១ នៃច្បាប់នេះ។

៤- ទុកដីអោយនៅទំនេរដោយមិនអនុវត្តផលិតកម្មកសិកម្ម ឬបង្កកដីដែលមានទំហំ លើសពី៥ (ប្រាំ) ហិកតាឡើងទៅ ក្នុងរយៈពេលលើសពី៣ (បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេរដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី។

**មតិយោបល់៖** ការិយាល័យOHCHR ទទួលស្គាល់ពីតម្រូវការមាននូវវិធីសាស្ត្រទូទៅស្មើឡើងដើម្បីណែនាំដល់ការដាក់ទណ្ឌកម្ម ចំពោះការខូចវិចវិលនៃដីកសិកម្ម និងការទុកដីអោយនៅទំនេរ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យOHCHR មានការព្រួយបារម្ភចំពោះការប្រព្រឹត្តដោយស្មើគ្នាចំពោះម្ចាស់ដីដែលកាន់កាប់ដីទំហំធំៗនិងដីកសិ-ឧស្សាហកម្មខ្នាតធំ និងម្ចាស់ដីដែលជាគ្រួសារកសិករតូចតាចនិងធ្វើកសិកម្មដើម្បីតែចិញ្ចឹមជីវិត និងប្រតិបត្តិករនៃកសិកម្មខ្នាតកណ្តាលទាំងអស់ដែលស្ថិតនៅចន្លោះកសិកម្មខ្នាតតូចនិងខ្នាតធំ។ ក្នុងករណីដែលគ្រួសារកសិករតូចតាចនិងធ្វើកសិកម្មដើម្បីតែចិញ្ចឹមជីវិត រងពិន័យពី ១០០០០០០០ (ដប់លាន) រៀល ទៅ ២០០០០០០០ (ម្ភៃលាន) រៀល អាចជាការដាក់ទណ្ឌកម្មដោយមិនសមហេតុផល ដោយប្រៀបធៀបជាមួយទំហំនៃការខូចខាតតិចតួចដែលពួកគេអាចបង្កឡើង និងជាក់ស្តែងចំនួនទឹកប្រាក់នេះហួសពីសមត្ថភាពរបស់ពួកគេក្នុងការបង់ពិន័យ ខណៈដែលវាមានកម្រិតទាបចំពោះកសិ-ឧស្សាហកម្មខ្នាតធំ សម្រាប់ជាការពិន័យពួកគេ។ ទណ្ឌកម្មគួរតែមានភាពសមហេតុផល សមាមាត្រទៅនឹងបទល្មើស និងផ្អែកលើការវាស់វែងច្បាស់លាស់លើទំហំនៃការខូចខាតដែលកើតឡើង។ ទាក់ទងទៅនឹងចំនុចដែលលើកឡើងខាងក្រោយ ពាក្យ "ផលប៉ះពាល់ធ្ងន់ធ្ងរ" នៅក្នុងកថាខណ្ឌទី២ តម្រូវអោយមានការកំណត់ឲ្យបានច្បាស់លាស់ ដែលរួមមានការវាស់វែងដើម្បីអាចបញ្ជាក់ពី "ផលប៉ះពាល់ធ្ងន់ធ្ងរ"នោះ បើមិនដូច្នោះទេ អវត្តមាននៃចំណុចនេះអាចនាំទៅដល់ការដាក់ទណ្ឌកម្មតាមតែទំនើងចិត្ត។

ទាក់ទងទៅនឹងកថាខណ្ឌទី៤ ការទប់ស្កាត់ម្ចាស់ដីពីការទុកដីចោលអោយនៅទំនេរ ឬ"បង្កក"ដី ដោយមិនអនុវត្តផលិតផលកសិកម្ម ជាការផ្ទុយទៅនឹងសិទ្ធិកាប់កាប់អចលនទ្រព្យដែលទទួលស្គាល់នៅក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា និងមាត្រា១៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ សូមមើលមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា ៣៥។ ប្រសិនជាកង្វល់ដែលបង្ហាញនៅផ្នែកនេះ គឺជាសេចក្តីត្រូវការដែលបានគិតទុកដើម្បីធានាថា ដីកសិកម្មទាំងអស់ត្រូវបានប្រើប្រាស់ជាក់ស្តែងសម្រាប់ផលិតផលកសិកម្ម ជាការសមស្រប ហើយក៏ជាការគោរពដល់សិទ្ធិនៃការកាន់កាប់អចលនទ្រព្យផងនោះ រដ្ឋាភិបាលត្រូវ

កំណត់អត្តសញ្ញាណដីទំនេរនិងផ្តល់ឲ្យមានការទិញដីទំនេរទាំងនោះក្នុងតំលៃទីផ្សារ។ បន្ទាប់មករដ្ឋាភិបាលដោយមានសិទ្ធិកម្មសិទ្ធិលើដីទាំងនោះ មានសិទ្ធិអំណាចកំណត់ថាតើដីទាំងនោះនឹងប្រើប្រាស់ដូចម្តេច។

ជាការកាន់តែទូលំទូលាយទៀត មាត្រាដែលមាននៅក្នុងជំពូកទោសប្បញ្ញត្តិ គួរត្រូវធ្វើវិសោធនកម្មដើម្បីកំណត់ច្បាស់លាស់ពីសកម្មភាពជាក់លាក់ ដែលបង្កើតបានជាបទល្មើសដែលនឹងរងនូវការដាក់ទណ្ឌកម្ម។ ជំពូកនេះគួរទទួលប្រយោជន៍ពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈវិធីសាស្ត្រដែលមានក្នុងក្រមដែលក្នុងនោះមានបញ្ជីបទល្មើសនីមួយៗនិងមានកំណត់និយមន័យច្បាស់លាស់ ហើយក៏មានការកម្រិតអតិបរិមានៃទោសសម្រាប់បទល្មើសនីមួយៗផង។ រាល់ពាក្យដែលមិនមានការយល់ច្បាស់លាស់ដោយបុគ្គល គួរតែពន្យល់នៅក្នុងសន្ទានុក្រម។

**មាត្រា១១៣.-**

ត្រូវផ្តន្ទាទោសជាក់ពន្ធនាគារ ពី១ (មួយ)ឆ្នាំដល់ ៥(ប្រាំ)ឆ្នាំ និង ឬត្រូវពិន័យជាប្រាក់ ពី ២៥០ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៥០០ ០០០ ០០០ (ហាសិបលាន)រៀល ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលកាន់កាប់និងប្រើប្រាស់ដីរដ្ឋ ដើម្បីអនុវត្ត ផលិតកម្មកសិកម្ម ក្រោមកិច្ចព្រមព្រៀងសម្បទាន ឬកតិសន្យាជួល ដោយប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

បង្កកទុកដីកសិកម្មសំរាប់គំរោងអាជីវកម្មអចលនទ្រព្យ ឬគំរោងអភិវឌ្ឍន៍ផ្សេងទៀត ក្រៅគោលបំណងផលិតកម្មកសិកម្ម ដោយផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ។

ផ្ទេរសិទ្ធិកាន់កាប់ដី លក់ ឬបញ្ចាំដីរដ្ឋ មួយផ្នែក ឬទាំងមូលអោយទៅតតីយជន ដោយសមគំនិត លួចលាក់ ឬបិតបាំងក្រោមរូបភាពផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី កសិកម្ម ឬតាមរយៈឧបាយកលផ្សេងៗទៀត។

**មតិយោបល់៖** ពាក្យមួយចំនួននៅក្នុងកថាខណ្ឌទី២ តម្រូវអោយមានការពន្យល់បកស្រាយ ដើម្បីអាចវាយតម្លៃយ៉ាងជាក់លាក់ នៅពេលស្វែងរកការដាក់ទណ្ឌកម្ម។ ដោយសារតែគ្មានបុគ្គលណា ឬស្ថាប័នណា មានសិទ្ធិអំណាចផ្លូវច្បាប់ដើម្បីដំណើរការផ្ទេរដីរដ្ឋ ក្រៅពីសម្បទានិកដំបូង ដូច្នេះមិនចាំបាច់តម្រូវអោយមានពាក្យបន្ថែមមិនច្បាស់លាស់ទាំងនេះ ដែលអាចជាការនាំទៅដល់ការជជែកដេញដោលមិនទទួលផ្លែផ្កានៅតុលាការដែលរួមមាន "ការបញ្ចាំ" "ការសមគំនិត" និង "ការប្រើឧបាយកល" ។ កថាខណ្ឌទី២ គួរត្រូវបានជំនួសដោយការហាមឃាត់ការផ្ទេរដីរដ្ឋដោយបុគ្គល ក្រៅតែពីភ្នាក់ងាររដ្ឋដែលទទួលស្គាល់ស្របច្បាប់និងផ្តល់អំណាចតាមច្បាប់ដើម្បីអនុវត្តការផ្ទេរដីរដ្ឋនេះ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យកែសម្រួលកថាខណ្ឌទី២ ឡើងវិញដូចតទៅនេះ៖ "*ការផ្ទេរសិទ្ធិកាន់កាប់ឬប្រើប្រាស់ដីទៅតតីយជននូវដីកសិកម្មរបស់រដ្ឋដែលបានផ្តល់ជាសម្បទាន ដោយគ្មានអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកជាអ្នកអនុវត្ត។*" លើសពីនេះទៀត ការកំណត់ជាក់លាក់អំពីប្រភេទឯកសារផ្លូវការដែលបញ្ជាក់ពី "អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុក" អនុវត្តការផ្ទេរដីកសិកម្ម ឬការផ្ទេរសិទ្ធិកាន់កាប់ ក្នុងនាមរដ្ឋនឹងជួយពង្រឹងមាត្រា ១១៣។

**សេចក្តីបន្ថែមនៃច្បាប់ស្តីពីដីកសិកម្ម៖** អនុសាសន៍បន្ថែមសម្រាប់បញ្ចូលទៅក្នុងសន្ទានុក្រម

នៅក្នុងការវិភាគបច្ចុប្បន្ន ការិយាល័យOHCHR បានផ្តល់អនុសាសន៍កែសម្រួលនិងតាក់តែងឡើងវិញនូវមាត្រាមួយចំនួនដោយឲ្យបញ្ចូលគំនិតថ្មីជាច្រើនដែលមានសារៈសំខាន់ចំពោះច្បាប់ស្តីពីដីកសិកម្ម និងការអនុវត្តន៍ច្បាប់នេះក្នុងលក្ខណៈមួយដែលស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា និងស្របទៅនឹងក្របខ័ណ្ឌច្បាប់ជាតិ និងគោលនយោបាយជាតិរបស់កម្ពុជា។ ដើម្បីឲ្យសន្ទានុក្រមដែលជាឧបសម្ពន្ធនៃសេចក្តីព្រាងច្បាប់នេះជាសេចក្តីយោងដែលមានអត្ថប្រយោជន៍ដែលជួយសម្រួលដល់ការយល់ដឹង ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍បន្ថែមនូវគំនិតថ្មីៗដូចខាងក្រោម៖

***ជនជាតិដើមភាគតិច ឬសហគមន៍ជនជាតិដើមភាគតិច៖***

*យោងតាមមាត្រា២៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់សម្តែងនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ន នេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ជាទូទៅពាក្យនេះត្រូវគ្នានឹងពាក្យ "ជនជាតិដើមភាគតិច" ដែលត្រូវបានប្រើជាទូទៅនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។*

***គោលការណ៍យល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC)៖***

*គោលការណ៍នេះមានចែងនៅក្នុងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដោយផ្អែកលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលយោងតាមច្បាប់ទាំងនេះ ការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចត្រូវធ្វើឡើងដោយ**សេរី** រួចផុតពីការបំភិតបំភ័យឬដោយបង្ខំ ត្រូវប្រព្រឹត្តធ្វើឡើង**ជាមុន** នៅមុនការបែងចែកដីសម្រាប់គំរោងជាក់លាក់ណាមួយ និង/ឬការអនុម័តគំរោងឬសកម្មភាពពាក់ព័ន្ធនឹងគំរោងដែលមានផលប៉ះពាល់ដល់ដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដោយផ្ទាល់ឬដោយប្រយោលក្តី និងដោយ**ទទួលបានព័ត៌មានគ្រប់គ្រាន់** និងអាចរកបាននូវព័ត៌មានពាក់ព័ន្ធទាំងអស់ (ពីរដ្ឋាភិបាល គំរោង និងប្រភពឯករាជ្យពីខាងក្រៅ និងការស្រាវជ្រាវ) ជាភាសា និងទម្រង់ដែលពួកគេយល់បាន ដើម្បីឈានទៅដល់ការ**យល់ព្រម**ដោយស្ម័គ្រចិត្ត។ គោលការណ៍នេះអនុវត្តនៅគ្រប់ពេលដែលមានវត្តមាននៃជនជាតិដើមភាគតិច ឬមានភាពពាក់ព័ន្ធជាសមូហភាពរបស់ពួកគេទៅនឹងទីតាំងគំរោង និងឬលើតំបន់ដែលទទួលរងឥទ្ធិពល ហើយត្រូវប្រព្រឹត្តិទៅដោយប្រសិទ្ធិភាពតាមរយៈនីតិវិធីពិគ្រោះយោបល់ដែលមានលក្ខណៈពិសេសនិងផ្សេងពីគេ ក្នុងគោលបំណងបង្កើនការចូលរួមប្រកបដោយអត្ថន័យបំផុតនៃជនជាតិដើមភាគតិច ក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។*

***ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស៖***

*នេះជាកាតព្វកិច្ចអន្តរជាតិរបស់ធុរកិច្ច និងរដ្ឋដើម្បីធានាថាពួកគេត្រូវធ្វើការកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀបដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សដែលបង្ករដោយប្រតិបត្តិ*

ការរបស់ពួកគេ (គោលការណ៍ណែនាំលេខ ១៧ ដល់លេខ២៤ នៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស)។ កាតព្វកិច្ចនេះមានគោលបំណងរួមចំនែកយ៉ាងសកម្ម និងទប់ស្កាត់ផលប៉ះពាល់ជាសក្តានុពលលើសង្គម បរិស្ថាន និងផលប៉ះពាល់សិទ្ធិមនុស្ស ហើយនិងការរក្សាទំនាក់ទំនងជាមួយបុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ តាមរយៈទំនាក់ទំនងផ្ទាល់។

**ការចូលរួមរបស់ភាគីពាក់ព័ន្ធប្រកបដោយអត្ថន័យ៖**

ផ្ទុយទៅនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធគ្រាន់តែជារូបភាព ការចូលរួមដ៏មានអត្ថន័យរបស់ភាគីពាក់ព័ន្ធក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសំរេចចិត្តទៅលើគំរោងឬសកម្មភាពពាក់ព័ន្ធដែលអាចមានផលប៉ះពាល់ដល់សហគមន៍ ជីវភាព ដីធ្លី និងបរិដ្ឋានធម្មជាតិរបស់ពួកគេ គឺមានលក្ខណៈ៖ បើកចំហរឲ្យមានការទទួលបានពត៌មានទាំងអស់ទាក់ទងនឹងគំរោងដែលពាក់ព័ន្ធ រួមមាន ការវាយតម្លៃផលប៉ះពាល់ទាំងអស់ ពត៌មានអំពីការប៉ះពាល់នៃគំរោងចំពោះសហគមន៍ដែលរងផលប៉ះពាល់ ពត៌មានផ្តល់ឲ្យជាភាសានិងទម្រង់ដែលក្រុមគោលដៅងាយយល់បាន ការបង្កើតជាមធ្យោបាយផ្សេងៗដើម្បីឲ្យព័ត៌មានបានទៅដល់បុគ្គលឬក្រុមដែលងាយរងគ្រោះដែលគេដាត់ចេញពីដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តដែលបង្កើតឡើង ឬប្រឈមនឹងហានិភ័យខ្លាំងបំផុតពីគម្រោងពាក់ព័ន្ធ (ដោយផ្តោតលើស្ត្រី ក្នុងចំនោមក្រុមដទៃ) ដើម្បីអោយពួកគេបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងមានជំហានជាក់លាក់ដើម្បីធានាភាពជាតំណាងនៃបុគ្គលឬក្រុមដែលរងផលប៉ះពាល់នៅក្នុងការពិគ្រោះយោបល់ និងយន្តការនៃការធ្វើសេចក្តីសម្រេចចិត្ត។

**គោលការណ៍នៃការចូលរួមជាសាធារណៈ៖**

ជាគោលការណ៍ ដែលក្នុងនេះ បុគ្គលទាំងឡាយណាដែលអាចរងនូវផលប៉ះពាល់ដោយសារសេចក្តីសម្រេចចិត្តណាមួយ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ប្រកបដោយអត្ថន័យ ទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន នៅមុនពេលនៃការសម្រេចចិត្តត្រូវបានធ្វើឡើង។ គោលការណ៍នេះទទួលស្គាល់ការពិតដែលថាសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម នាំមកនូវសេចក្តីសម្រេចចិត្តល្អប្រសើរដែលផ្អែកលើព័ត៌មាន បង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទាន់ពេលវេលាទៅនឹងកង្វល់និងការទាមទាររបស់សាធារណៈជនធ្វើអោយប្រសើរឡើងដល់ការទទួលយកបាននិងអនុលោមទៅតាមសេចក្តីសំរេចនោះ ហើយអាស្រ័យហេតុនេះជួយទប់ស្កាត់ជម្លោះពីការកើតឡើងតាមរយៈការកាត់បន្ថយផលប៉ះពាល់ដែលនឹងកើតមានឡើងតាំងពីដំបូង។

**គោលការណ៍នៃការទទួលពត៌មាន៖**

ជាគោលការណ៍ដែលក្នុងនេះ រូបវន្តបុគ្គល សហគមន៍ នីតិបុគ្គល និងសង្គមស៊ីវិលមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងគម្រោងដែលស្នើរឡើង និងផលប៉ះពាល់របស់គម្រោង រួមទាំងផលប៉ះពាល់លើបរិស្ថាននិងធនធានធម្មជាតិ។ ពត៌មានទាំងនោះត្រូវមាននូវពត៌មានអំពីសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានផ្តល់ប្រាក់កម្ចីជាតិនិងអន្តរជាតិដែលកំពុងគាំទ្រគម្រោងនោះ ឬសកម្មភាពពាក់ព័ន្ធតាមរយៈប្រាក់ជំនួយ ឥណទាន ឬជំនួយបច្ចេកទេស ការវាយតម្លៃនិងការកាត់បន្ថយផលប៉ះពាល់បរិដ្ឋាននិងសង្គម និងផែនការតាំងទីលំនៅថ្មី និងពត៌មានស្តីអំពីការដឹកជញ្ជូននិងប្រើប្រាស់នៃសម្ភារៈដែលគ្រោះថ្នាក់ និងអំពីប្រតិបត្តិការផ្សេងៗដែលបានគ្រោងអនុវត្តនៅក្នុងសហគមន៍។ ពត៌មានស្តីអំពីគម្រោងដែលស្នើឡើង និងផលប៉ះពាល់របស់គម្រោងនោះចំពោះកិច្ចការការពារបរិដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សាធារណជន

*ដើម្បីបង្កើតឱកាសជាអតិបរមាសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងការធ្វើផែនការ និងការសម្រេចចិត្ត ដែលបង្កផលប៉ះពាល់ដល់សង្គម និងបរិស្ថាន។*

### *គោលការណ៍នៃការទទួលបានការដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព៖*

*ជាគោលការណ៍ដែលប្រជាពលរដ្ឋ រូបវន្តបុគ្គល សហគមន៍ និងនីតិបុគ្គល មានសិទ្ធិទទួលបាននូវនីតិវិធីដោះស្រាយសមស្របតាមរយៈរដ្ឋបាល តុលាការ ឬនីតិវិធីដោះស្រាយដទៃទៀតដើម្បីធ្វើឲ្យមានដំណោះស្រាយចំពោះវិវាទទាក់ទងនឹងកម្មសិទ្ធិ កសិកម្ម និងបរិស្ថាន។ នីតិវិធីនិងដំណើរការដោះស្រាយប្រកបដោយភាពមិនលំអៀង ប្រសិទ្ធិភាព និងប្រសិទ្ធិផល ត្រូវបង្កើតឡើងដើម្បីអនុវត្តនូវនីតិវិធីត្រឹមត្រូវ ការផ្តន្ទាទោសចំពោះជនទាំងឡាយណាដែលបង្កការខូចខាត និងបង្កើតជាកម្មវិធីលើកទឹកចិត្តដែលជម្រុញដល់ការអនុលោមតាមច្បាប់។*

### *ការបញ្ជ្រាបយេនឌ័រ៖*

*ដំណើរការវាយតម្លៃជាបន្តបន្ទាប់នូវផលប៉ះពាល់នៃសកម្មភាពនានាដែលគ្រោងឡើងទៅលើស្ត្រី និងបុរស រួមមានទាំងការបង្កើតច្បាប់ គោលនយោបាយ ឬកម្មវិធីផ្សេងៗ។ ដំណើរការនេះមានគោលបំណងបញ្ចូលនូវកង្វល់និងបទពិសោធន៍របស់ស្ត្រី ក៏ដូចជាបទពិសោធន៏របស់បុរស ទៅក្នុងការរៀបចំ ការអនុវត្តន៏ ការតាមដាន និងការវាយតម្លៃគោលនយោបាយនិងកម្មវិធី ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីផ្តល់ប្រយោជន៍ដល់ស្ត្រី និងបុរសស្មើគ្នា។ ដំណើរការបញ្ជ្រាបនេះ រួមមានទាំងសកម្មភាពយេនឌ័រជាក់លាក់ និងសកម្មភាពវិជ្ជមាន ជាពិសេសនៅពេលដែលស្ត្រី ឬបុរសស្ថិតក្នុងស្ថានភាពដែលបាត់បង់ផលប្រយោជន៍។ កិច្ចអន្តរាគមន៍យេនឌ័រជាក់លាក់ អាចធ្វើឡើងសម្រាប់តែក្រុមគោលដៅជាស្ត្រីទាំងស្រុង អាចសម្រាប់ទាំងបុរសនិងស្ត្រី ឬក៏សម្រាប់តែបុរស ប៉ុន្តែត្រូវតែធ្វើយ៉ាងណាសំដៅដល់ការចូលរួមដោយស្មើភាពរបស់ពួកគេក្នុងការទទួលបានផលប្រយោជន៍ដោយស្មើភាពគ្នាពីការអភិវឌ្ឍនានា។ ដោយផ្តើមចេញពីមូលដ្ឋាននៃវិសមភាព ដំណើរការនេះផ្តោតលើការសន្និដ្ឋានថា កម្មវិធីអព្យាក្រឹតយេនឌ័រជាក់ស្តែងដែលមិនឆ្លុះបញ្ចាំងនូវទិដ្ឋភាពយេនឌ័រតែងតែជាការបន្តនូវវិសមភាពជាលទ្ធផល។*

## ឧបសម្ព័ន្ធ- បទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងដីសម្បទានដីសេដ្ឋកិច្ចៈ

បទប្បញ្ញត្តិមួយចំនួននៃច្បាប់កម្ពុជាដែលកំពុងអនុវត្តនាពេលបច្ចុប្បន្នដែលបានដាក់ទៅក្នុងមាត្រាជាច្រើននៃសេចក្តីព្រាងច្បាប់បច្ចុប្បន្ន ត្រូវបានរៀបរាប់ឡើងវិញដូចខាងក្រោម ដើម្បីងាយស្រួលធ្វើការយោង។

### ១. ច្បាប់ភូមិបាលឆ្នាំ ២០០១

**ជំពូកទី ៥ អំពីសម្បទានដី**

មាត្រា ៤៨.-

សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ចតាមអំណាចឆន្ទានុសិទ្ធិអោយរូបវន្តបុគ្គលឬនីតិបុគ្គលឬក្រុមមនុស្ស ដើម្បីកាន់កាប់ដីនិងប្រើប្រាស់ សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ។

មាត្រា ៤៩.-

សម្បទានដីត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គមឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។

សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតអោយអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋានឬនិងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីជានាការចិញ្ចឹមជីវិត។

សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច អនុញ្ញាតអោយអ្នកទទួលប្រយោជន៍កាប់ឆ្ការទាញយកផល ដោយធ្វើអាជីវកម្មកសិឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥០.-

សម្បទានអាចមានរូបភាពផ្សេងទៀតដូចជាការអនុញ្ញាតអោយប្រើប្រាស់ រៀបចំឬ ធ្វើអាជីវកម្មដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះជាភ្ជាប់ឬមិនភ្ជាប់ទៅនឹងការបំពេញសេវាសាធារណៈក៏ដោយ មានជាអាទិសម្បទានរ៉ែ សម្បទានកំពង់ផែ សម្បទានព្រលានយន្តហោះ សម្បទានរៀបចំតំបន់ឧស្សាហកម្ម សម្បទាននេសាទ។ សម្បទានទាំងនេះមិនឋិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះទេ។

មាត្រា៥១.-

សម្បទានដីមិនអាចប្រគល់អោយដោយឥតគិតថ្លៃទេ លើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ដែលប្រគល់អោយគ្រួសារក្រីក្រសំរាប់តាំងទីលំនៅ ឬនិងដាំដំណាំចិញ្ចឹមជីវិត។

មាត្រា ៥២.-

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យាដែលបានបង្កើតសម្បទាននោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ។

សម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិជាកម្មសិទ្ធិលើដីដែលបានផ្តល់ជាសម្បទានជាប្រយោជន៍ ដល់ សាមីជននោះទេ លើកលែងតែចំពោះសម្បទានដែលឆ្លើយតបទៅនិងប្រយោជន៍សង្គម។

មាត្រា ៥៣.-

សម្បទានដីមិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ។ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ដែលបានចេញមុនការកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ច គឺរដ្ឋ ឬសមូហភាពដែនដីសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលជាកម្មសិទ្ធិករនៃដីដែលត្រូវបានផ្តល់ជាសម្បទាន។ សម្បទានត្រូវចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា ៥៤.-

សម្បទានដីត្រូវមានលក្ខខណ្ឌ។ សម្បទានដីត្រូវតែអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដែលជាសណ្តាប់ធ្នាប់សាធារណៈ។

លិខិតសម្បទានអាចមាន ខដោយឡែកផ្សេងទៀតដែលមានតម្លៃជាកិច្ចសន្យា។

មាត្រា ៥៥.-

សម្បទានដីត្រូវបានដកហូតវិញដោយសេចក្តីសំរេចខាងរដ្ឋបាលក្នុងករណីលក្ខខណ្ឌច្បាប់មិនត្រូវបានគោរព។

ករណីនេះសម្បទានិកមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីដែលច្បាប់កំណត់។

សម្បទានដីអាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិកមិនគោរពខដោយឡែកដែលមានចែងក្នុងកិច្ចសន្យា។

មាត្រា ៥៦.-

សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងអំឡុងពេលនៃសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ ដូចជាកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ។ សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច។

សម្បទានិកអាចការពារដីដែលបានផ្តល់ជាសម្បទានអោយខ្លួនចំពោះការទន្ទ្រាន ឬការប៉ះពាល់ទោះជាតាម រូបភាពណាក៏ដោយ។

សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួនធ្វើការរៀបចំដាំដុះស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើអោយប៉ះពាល់ដល់របនាសម្ព័ន្ធធម្មជាតិនិងធ្វើអាជីវកម្ម ដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ។

មាត្រា ៥៧.-

ការផ្ទេរដីសម្បទានមិនអាចធ្វើឡើងតាមរយៈការផ្ទេរសិទ្ធិបានឡើយ។ ការផ្ទេរដីសម្បទាន អាចកើតឡើងតែ តាមរយៈការបង្កើតកិច្ចសន្យាថ្មីនៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ច ជាគុណប្រយោជន៍ដល់អ្នកទទួល សិទ្ធិសម្បទានថ្មី។

ក្នុងករណីដែលសម្បទាននិកទទួលមរណភាព ទាយាទទាំងឡាយរបស់ខ្មោចប្រសិនជាមានបំណងអាចនឹង បន្តប្រើប្រាស់សិទ្ធិទាំងនោះក្នុងរយៈពេលសម្បទានដែលនៅសល់។

មាត្រា ៥៨.-

សម្បទានដីអាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជន របស់រដ្ឋ។

សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សំរាប់ថែទាំក៏ដូចជា ផ្លូវទឹក ត្រពាំង បឹង និងដែនដីទឹកបំរុង ដែលមានប្រយោជន៍ដល់រស់នៅរបស់ប្រជាពលរដ្ឋឡើយ។

មាត្រា ៥៩.-

សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ ១០០០០ (មួយម៉ឺនហិកតា) ហិកតា។

សម្បទានដីដែលសំរេចហើយ ហើយមានទំហំលើសពីទំហំកំណត់ខាងលើជាកម្មវត្ថុនៃការកាត់បន្ថយ។ ប៉ុន្តែ ប្រសិនបើការកាត់បន្ថយននេះមានឥទ្ធិពលធ្វើអោយខូចប្រយោជន៍អាជីវកម្មដែលកំពុងដំណើរការ សម្បទានិក អាចនឹងទទួលបានការលើកលែងជាពិសេស។ នីតិវិធីនៃការកាត់បន្ថយ និងការលើកលែងជាពិសេសត្រូវកំណត់ដោយអនុក្រឹត្យ។

ត្រូវបានហាមឃាត់ការចេញលិខិតសម្បទានដីច្រើនកន្លែងអោយបុគ្គលតែម្នាក់ ឬអោយនីតិបុគ្គលច្រើនតែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែលៗ ដែលមានទំហំសរុបធំជាងទំហំដែលបានកំណត់នៅវាក្យខណ្ឌខាងលើ។

មាត្រា ៦០.-

នីតិវិធីនៃការផ្តល់សម្បទានដីសំរាប់ការសង់លំនៅឋាននិងសម្បទានដីកសិកម្មសំរាប់ការចិញ្ចឹមជីវិត ឬអាជីវកម្ម កសិឧស្សាហកម្មត្រូវកំណត់ដោយអនុក្រិត្យ។

មាត្រា ៦១.-

រយៈពេលនៃសម្បទានដីត្រូវកំណត់ ៩៩ (កៅសិបប្រាំបួន)ឆ្នាំ យ៉ាងច្រើន។

មាត្រា ៦២.-

រាល់សម្បទានដីសំរាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមអាជីវកម្មក្នុងរយៈពេល១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្តល់ សម្បទាន បើមិនដូច្នោះទេនឹងត្រូវទុកជាមោឃៈ។

ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី ១២ (ដប់ពីរ) ខែ នាំអោយមានមោឃភាពសម្បទាន ប្រសិនបើការខកខាននោះពុំមានមូលហេតុត្រឹមត្រូវ។

រាល់សម្បទានដីដែលបានផ្តល់អោយមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី ១២(ដប់ពីរ) ខែ ឡើងទៅ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបានធ្វើអាជីវកម្មនោះពុំមានមូលហេតុត្រឹមត្រូវ។

រាល់ការមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុកដោយសម្បទានិក នាំអោយមានការដកហូតសម្បទាន។ ក្នុងករណីនៃការដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយសម្បទានិក គ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ។

ក្នុងករណីនៃការដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយ សម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ។

## ២. អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (លេខ១៤៦/២០០៥)

មាត្រា ២.-

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ៖

- សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅអោយសម្បទានិក ដើម្បីប្រើប្រាស់សំរាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម
- ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់៖
    - ការដាំដំណាំស្បៀង ឬដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចំការឈើ
    - ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
    - ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃ វត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ឬ
    - សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តសិទ្ធិនោះតាមការផ្តល់សិទ្ធិ ប្រទានពីនាយករដ្ឋមន្ត្រី និងបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ
- ស្ថាប័នដាក់បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់អោយអនុវត្តនូវ វិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងលើសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដី សេដ្ឋកិច្ច
- លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច។

មាត្រា ៣.-

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឲ្យ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម៖

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ដែលតម្រូវអោយមានការវិនិយោគ ដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប
- សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈ សមស្រប និងប្រកបដោយចិរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ
- បង្កើតភាពមានការងារធ្វើនៅជនបទ ក្នុងក្របខ័ណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើអោយមានកាលា នុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងការក្របខ័ណ្ឌនៃការគ្រប់គ្រងធនធាន ធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប
- លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង
- បង្កើតចំណូលរដ្ឋ ឬចំណូលខេត្តក្រុង ឃុំសង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើ សេវាពាក់ព័ន្ធ។

មាត្រា ៤.-

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់អោយចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង៥ ដូចខាងក្រោម៖

- ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រង ដីរដ្ឋ និងអនុក្រិត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬ អនុក្រិត្យស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។
- ដីដែលមានផែនការប្រើប្រាស់ ដីអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ហើយការ ប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ។
- ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍន៍ដី សម្រាប់គម្រោងសម្បទាន។
- ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មី ស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំអោយធ្វើការតាំងទីលំនៅថ្មីដោយគ្មានការ

ស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន។

- ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរ ដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

## ៣. អនុក្រឹត្យស្តីពីការបញ្ចាំ និងការផ្ទេរសិទ្ធិចំពោះការជួលរយៈពេលវែង ឬសម្បទានដីសេដ្ឋកិច្ច (លេខ ១១៤/២០០៧)

គោលបំណងនៃអនុក្រឹត្យនេះ គឺចង់កំណត់គោលការណ៍ និងពេលវេលា និងល័ក្ខខ័ណ្ឌដើម្បីផ្តល់សិទ្ធិទៅអ្នកវិនិយោគ ដើម្បីកំណត់ពីសុវត្ថិភាព និងការផ្ទេរសិទ្ធិចំពោះការជួលរយៈពេលវែង ឬការជួលដីសម្បទានសេដ្ឋកិច្ច ដែលអំឡុងពេលនៃការជួលមិនអោយលើសពីរយៈពេលដែលបានកំណត់នៅក្នុងកិច្ចសន្យាជួលរយៈពេលវែង ឬកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។

ការបញ្ចាំ ឬការផ្ទេរសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិទៅលើសម្បទានដីសេដ្ឋកិច្ច មិនគួរត្រូវបានពន្យាពេលទៅលើកិច្ចសន្យាបញ្ចាំ ឬការផ្ទេរដីសម្បទាន ឬកិច្ចសន្យាជួលរយៈពេលវែង ដែលអ្នកវិនិយោគទទួលបានពីរដ្ឋ។ វិនិយោគិន មិនអាចផ្ទេរ ឬបញ្ចាំសិទ្ធិរបស់ពួកគេទៅលើកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចដែលមិនបានធ្វើការអភិវឌ្ឍន៍ទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាសម្ប ទានដីសេដ្ឋកិច្ច។ សម្បទានដីសេដ្ឋកិច្ចអាចបង្កើតសិទ្ធិក្នុងអំឡុងពេលជាក់លាក់នៃកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។

មានតែអចលនទ្រព្យដែលបានចុះបញ្ជី នៅក្នុងប្លង់មេតែប៉ុណ្ណោះ ដែលអាចជាកម្មវត្ថុនៃការជួលរយៈពេលវែង។ ក្នុងករណីការជួលត្រូវបានធ្វើឡើងជាមួយរដ្ឋាភិបាល និងដីដែលគ្មានប័ណ្ណកម្មសិទ្ធិ ការជួលត្រូវតែចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយនិងហត្ថលេខារបស់ រដ្ឋមន្ត្រីពាក់ព័ន្ធ ឬហត្ថលេខារបស់ប្រធានស្ថាប័ន ឬអភិបាលខេត្ត ដែលជាអាជ្ញាធរដែលអាចទុកចិត្តបាន នៃដីនោះ។ សម្បទានដី ឬការជួលរយៈពេលវែង គួរត្រូវបានលើកឡើងអំពីវិញ្ញាបនប័ត្រសំគាល់សិទ្ធិកាប់កាប់ នៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយ កម្ម និងសំណង់ ត្រូវចេញ "វិញ្ញាបនប័ត្រនៃការជួលរយៈពេលវែង" ឬ "វិញ្ញាបនប័ត្រនៃសម្បទានដី សេដ្ឋកិច្ច"។ អ្នកជួល ឬសម្បទានិក ត្រូវមានសិទ្ធិលើការបញ្ចាំ ឬការផ្ទេរសិទ្ធិរបស់ពួកគេទៅលើការ ជួលរយៈពេលវែង ឬដីសម្បទាន ក៏ដូចជាអគារ ហើយនិងឬអចលនទ្រព្យផ្សេងទៀតដែលពួកគេបាន សាងសង់នៅលើដី បើមិនដូច្នោះលើកលែងតែកិច្ចសន្យាជួលដែលមានចែងជាក់លាក់ ឬកិច្ចសន្យា សម្បទានដីសេដ្ឋកិច្ច ឬក៏កំណត់ដោយច្បាប់។ រូបវន្តបុគ្គល ឬនីតិបុគ្គល ឬក៏មនុស្សមួយក្រុម ត្រូវបានអនុញ្ញាតអោយជួលដីពីរដ្ឋ អាចធ្វើកិច្ចសន្យាជួលបន្ត ទៅអោយភាគីទីបីបានដោយមានការអនុញ្ញាត ពីអាជ្ញាធរមានសមត្ថកិច្ច។

តម្លៃសំរាប់ការចេញវិញ្ញាបនប័ត្រនៃកិច្ចសន្យាជួលរយៈពេលវែងនិងសម្បទានដីសេដ្ឋកិច្ចគួរត្រូវបានកំណត់ដោយប្រកាសរួម របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០១១ )

### ជំពូកទី៩៖ សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី

៣០៧. សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី

បទប្បញ្ញត្តិស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍ក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត *ដូចគ្នាផងដែរ* ចំពោះសិទ្ធិលើដីដែលត្រូវបានបង្កើតឡើងដោយសម្បទាន ក្នុងទំហំនៃល័ក្ខខ័ណ្ឌនៃសម្បទាន លើកលែងតែករណី ដែលមានកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស។